ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce

# របាយការណ៍
# បូកសរុបការងារពាណិជ្ជកម្មឆ្នាំ២០១៤
# និង
# ទិសដៅអនុវត្តការងារពាណិជ្ជកម្មឆ្នាំ២០១៥

ឆ្នាំ២០១៤

# មាតិកា


| ខ្លឹមសារ | | ទំព័រ |
|---|---|---|
| I/ | **សេចក្តីផ្តើម** | |
| ១. | កំណែទម្រង់ | 2 |
| ១.១ | កំណែទម្រង់រចនាសម្ព័ន្ធចាត់តាំង | 2 |
| ១.២ | កំណែទម្រង់ធនធានមនុស្ស | 3 |
| ១.៣ | កំណែទម្រង់ក្នុងការផ្តល់សេវាសាធារណៈ | 3 |
| ១.៣.១ | សេវានាំចេញ-នាំចូល | 3 |
| ១.៣.២ | ការចុះបញ្ជីពាណិជ្ជកម្ម | 5 |
| ១.៣.៣ | ការផ្តល់សេវាកម្មសិទ្ធិបញ្ញា | 6 |
| ១.៣.៤ | ការផ្តល់សេវានៅថ្នាក់ក្រោមជាតិ | 6 |
| ១.៤ | កំណែទម្រង់រដ្ឋបាល - ហិរញ្ញវត្ថុ | 6 |
| ១.៥ | ការងារស្ថិតិ និងព័ត៌មានពាណិជ្ជកម្ម | 7 |
| ១.៦ | ការងារកាំកុងត្រូល | 7 |
| II/ | **សកម្មភាពពាណិជ្ជកម្មដើម្បីចូលរួមយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣** | |
| ២ | សកម្មភាពពាណិជ្ជកម្មដើម្បីចូលរួមយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ | 8 |
| ២.១ | លទ្ធផលនៃការបម្រើសេវាសាធារណៈ | 8 |
| ២.១.១ | ការងារកម្មសិទ្ធិបញ្ញា | 8 |
| ២.១.២ | ការចុះបញ្ជីពាណិជ្ជកម្ម និងការផ្តល់សេវាពាក់ព័ន្ធ | 8 |
| ២.១.៣ | ការផ្តល់សេវានាំចេញ-នាំចូល | 9 |
| ២.២ | ការងារសមាហរណកម្មសេដ្ឋកិច្ចតំបន់ អនុតំបន់ និងដៃគូ | 10 |
| ២.២.១ | អាស៊ាន-ចិន | 10 |
| ២.២.២ | អាស៊ាន-កូរ៉េ | 11 |
| ២.២.៣ | អាស៊ាន-ជប៉ុន | 12 |
| ២.២.៤ | អាស៊ាន-ឥណ្ឌា | 12 |
| ២.២.៥ | អាស៊ាន-អូស្ត្រាលី-ណូវ៉ែលហ្សេឡង់ | 13 |
| ២.២.៦ | អាស៊ាន-ហុងកុង | 13 |
| ២.២.៧ | ភាពជាដៃគូសេដ្ឋកិច្ចទូលំទូលាយតំបន់ (RCEP) | 13 |
| ២.២.៨ | អាស៊ាន-រុស្ស៊ី | 14 |
| ២.២.៩ | អាស៊ានបូក៣ | 14 |
| ២.២.១០ | អាស៊ាន-អាមេរិក | 14 |
| ២.២.១១ | អាស៊ាន-កាណាដា | 15 |

២.២.១២ សហប្រតិបត្តិការសេដ្ឋកិច្ចអាស៊ីបូព៌ា ..... 15
២.២.១៣ អាស៊ាន-សហភាពអឺរ៉ុប ..... 16
២.២.១៤ ការងារអនុតំបន់ ..... 16
២.២.១៥ ការងារទ្វេភាគី ..... 17
២.២.១៦ ការងារសមាហរណកម្មសេដ្ឋកិច្ចអាស៊ាន(AEC) ..... 17
២.២.១៧ សហគមន៍សេដ្ឋកិច្ចអាស៊ាន ..... 18
២.២.១៨ ពាណិជ្ជកម្មទំនិញ ..... 18
២.២.១៩ ពាណិជ្ជកម្មសេវា ..... 20
២.២.២០ វិនិយោគអាស៊ាន ..... 21
២.៣ កិច្ចសហប្រតិបត្តិការពាណិជ្ជកម្មជាមួយអឺរ៉ុប មជ្ឈឹមបូព៌ា និងអាហ្វ្រិក ..... 21
២.៤ កិច្ចសហប្រតិបត្តិការពាណិជ្ជកម្មជាមួយទ្វីបអាមេរិក ..... 22
២.៥ ការងារសមាហរណកម្មសាកល ..... 23
២.៦ ការងារកសាងបញ្ញត្តិច្បាប់ពាណិជ្ជកម្ម ..... 24
២.៧ ការងារអភិវឌ្ឍន៍វិស័យឯកជន ..... 26
២.៨ ការចងក្រង និងផ្តល់ព័ត៌មានពាណិជ្ជកម្ម ..... 28
២.៩ ការងារសហប្រតិបត្តិការអន្តរជាតិ និងគ្រប់គ្រងជំនួយ ..... 29
២.៩.១ ការងារគ្រប់គ្រងជំនួយ ..... 29
២.៩ .២ ការងារសហប្រតិបត្តិការកម្មសិទ្ធិបញ្ញា ..... 30
២.១០ ការងារជំរុញពាណិជ្ជកម្ម ..... 30
២.១០.១ ការរៀបចំពិព័រណ៍ពាណិជ្ជកម្ម ..... 30
២.១០.២ ការងារពង្រឹងដៃគូពាណិជ្ជកម្ម ..... 31
២.១០.៣ ការងារការស្វែងរកទីផ្សារ ..... 31
២.១០.៤ ការងារអភិវឌ្ឍន៍ទីផ្សារ ..... 32
២.១០.៥ ការអភិវឌ្ឍន៍ផលិតផល ..... 34
២.១០.៦ ការអភិវឌ្ឍន៍ស្ថាប័នពាណិជ្ជកម្ម ..... 34
២.១០.៧ ការងារអភិវឌ្ឍន៍គោលនយោបាយពាណិជ្ជកម្ម ..... 35
២.១១ ការងារត្រួតពិនិត្យ បង្ក្រាបការក្លែងបន្លំ និងការពារអ្នកប្រើប្រាស់ ..... 36
២.១១.១ ការពង្រឹងប្រសិទ្ធភាពនៃការត្រួតពិនិត្យការនាំចេញ-នាំចូល តាមច្រកព្រំដែន ..... 36
២.១១.២ ពង្រឹងប្រសិទ្ធភាពនៃការឃ្លាំពិនិត្យទីផ្សារ ទប់ស្កាត់គ្រោះថ្នាក់សុខមាលភាព សុវត្ថិភាពអ្នកប្រើប្រាស់ ពាក់ព័ន្ធនឹងផលិតផល ..... 37
២.១១.៣ ពង្រឹងស្ថាប័ន ធ្វើឱ្យប្រសើរ និងមានប្រសិទ្ធភាពចំពោះកិច្ចការពារអ្នកប្រើប្រាស់ ..... 37
២.១១.៤ លើកកម្ពស់ការយល់ដឹងសាធារណៈ ..... 37
២.១១.៥ ទប់ស្កាត់ការក្លែងបន្លំ ..... 38
២.១១.៦ បញ្ជរទំនាក់ទំនងអំពីអនាម័យ និងភូតគាមអនាម័យ (SPS Enquiry Points) ..... 38
២.១១.៧ ការងារពាក់ព័ន្ធ ACCSQ, ATFC, ARASFF, ARASCP, ACOST, ACCP ..... 39

២.១១.៨ ការងារគណៈកម្មាធិការ Codex ជាតិ ....... 39
២.១១.៩ ការកសាងច្បាប់ និងបទប្បញ្ញត្តិបច្ចេកទេស ....... 39
២.១១.១០ ការងារមន្ទីរពិសោធន៍ ....... 39
២.១២ ការងារមន្ត្រី បណ្តុះបណ្តាល និងអភិវឌ្ឍន៍ធនធានមនុស្ស ....... 40
២.១៣ រដ្ឋបាលទូទៅ និងហិរញ្ញវត្ថុ ....... 44
២.១៤ ការងារសន្តិសុខស្បៀង និងសន្តិធិអាស៊ាន ....... 46
២.១៥ ការងារអធិការកិច្ច និងសវនកម្ម ....... 47
២.១៥.១ ការងារអធិការកិច្ច ....... 47
២.១៥.២ ការងារសវនកម្មផ្ទៃក្នុង ....... 48
២.១៦ ការងារសង្គមកិច្ច និងសម្ព័ន្ធភាព ....... 48
២.១៧ ការងារយេនឌ័រ ....... 49
២.១៨ សកម្មភាពការងារមន្ទីរពាណិជ្ជកម្មរាជធានី-ខេត្ត ....... 50
២.១៨.១ ការងារអាជីវកម្ម ....... 50
២.១៨.២ ការងារជំរុញពាណិជ្ជកម្ម ....... 50
III/ **ទិសដៅការងារ**
៣. ទិសដៅការងារពាណិជ្ជកម្មឆ្នាំបន្ត ....... 51
**ឧបសម្ព័ន្ធ**

ស្មោះត្រង់ រាំងស្កាត់ការផលិត និងការចែកចាយផលិតផលក្លែងក្លាយ និងផលិតផលគ្មានគុណភាព ឬខូចគុណភាព។

ឆ្លើយតបទៅនឹងយន្តការអភិវឌ្ឍន៍វិស័យពាណិជ្ជកម្ម ដែលព្រះរាជាណាចក្រកម្ពុជាបាននឹងកំពុងធ្វើសកលភាវូបនីយកម្មក្នុងតំបន់ និងពិភពលោក ហើយក៏បានកំពុងត្រៀមខ្លួនចូលក្នុងសហាគមន៍សេដ្ឋកិច្ចអាស៊ាន និងភាពជាដៃគូសេដ្ឋកិច្ចទូលំទូលាយតំបន់ឆ្នាំ២០១៥ ខាងមុខនេះផងដែរ កត្តាទាំងនេះតម្រូវឲ្យកម្ពុជាខិតខំធ្វើការប្រកួតប្រជែងដ៏ខ្លាំងក្លាក្នុងវិស័យពាណិជ្ជកម្ម និងវិនិយោគជាមួយបណ្តាប្រទេសសមាជិកដទៃទៀត។ ផ្តើមចេញពីមូលហេតុខាងលើក្រសួងពាណិជ្ជកម្ម បានខិតខំពង្រឹងសមត្ថភាព និងប្រសិទ្ធភាពការងាររបស់ខ្លួន តាមរយៈការធ្វើកំណែទម្រង់រចនាសម្ព័ន្ធ អភិវឌ្ឍន៍ស្ថាប័ន ពង្រឹងធនធានមនុស្សក្នុងគោលដៅអនុវត្តការងារ ប្រកបដោយប្រសិទ្ធភាព ដើម្បីជំរុញវិស័យពាណិជ្ជកម្ម ទៅជាឧបករណ៍ដ៏មានសារៈសំខាន់ នៅក្នុងចំណោមវិស័យសំខាន់ៗ នៃសេដ្ឋកិច្ចជាតិ រួមចំណែកអភិវឌ្ឍ និងធានាបានការរីកចម្រើនជាបន្តបន្ទាប់ឥតឈប់ឈរ។

## ១. កំណែទម្រង់

### ១.១ កំណែទម្រង់រចនាសម្ព័ន្ធចាត់តាំង

ក្រសួងពាណិជ្ជកម្ម បានរៀបចំកែសម្រួល រចនាសម្ព័ន្ធចាត់តាំង ដូចមានខ្លឹមសារក្នុងអនុក្រឹត្យលេខ ៩១ អនក្រ បក ចុះថ្ងៃទី០១ ខែសីហា ឆ្នាំ២០០៧ ក្នុងមូលហេតុ និងគោលបំណងដូចខាងក្រោម៖

- **ក.** ការផ្តល់សេវាសាធារណៈរបស់ក្រសួងពាណិជ្ជកម្មកន្លងមក នៅរាយប៉ាយស្ទើតែគ្រប់ អគ្គ-នាយកដ្ឋាន មិនទាន់បានឆ្លើយតបទៅនឹងកិច្ចសម្រួលពាណិជ្ជកម្ម បែបបទរដ្ឋបាលមានភាពស្មុគស្មាញច្រើនលំដាប់ថ្នាក់ កត្តាទាំងនេះហើយដែលតម្រូវឲ្យ ក្រសួងចាំបាច់ត្រូវកែសម្រួលរចនាសម្ព័ន្ធចាត់តាំង ធ្វើការប្រមូលផ្តុំសេវាគ្រប់ប្រភេទឲ្យមកនៅរួមគ្នា ក្នុងអគ្គនាយកដ្ឋានតែមួយ ដើម្បីងាយស្រួលគ្រប់គ្រង និងបង្កើនភាពងាយស្រួល ការផ្តល់សេវាសាធារណៈ ជូនទៅអាជីវករ ពាណិជ្ជករ
- **ខ.** នាយកដ្ឋានជំរុញពាណិជ្ជកម្ម កន្លងមកទទួលភារកិច្ច គ្រប់គ្រងវិស័យពាណិជ្ជកម្មទាំងក្នុងប្រទេសផង និងទាំងក្រៅប្រទេសផង ធ្វើឲ្យការបែងចែកការទទួលខុសត្រូវ មិនគ្រប់ជ្រុងជ្រោយចន្លោះប្រហោងដោយការងារមានទំហំធំ ភារៈកិច្ចមួយចំនួនត្រូវតែពង្រឹងបន្ថែមពិសេសការងារពាណិជ្ជកម្ម នៅរដ្ឋបាលថ្នាក់ក្រោមជាតិ
- **គ.** ក្រសួងពាណិជ្ជកម្មត្រូវត្រៀមលក្ខណៈសម្បត្តិគ្រប់បែបយ៉ាង សម្រាប់ការប្រកួតប្រជែងជាមួយបណ្តាប្រទេសអាស៊ានឆ្នាំ២០១៥ និងដោយសារមុខជំនាញ និងភារកិច្ចទាំងនេះមានភាពដោយឡែកពីគ្នា ធ្វើឲ្យការគ្រប់គ្រងពុំទាន់មានលក្ខណៈស៊ីជម្រៅ ពុំអាចជំរុញការងារឲ្យវិវត្តន៍ទាន់តម្រូវការ នៃសភាពការណ៍ចំពោះមុខ និងទៅអនាគតបាន

កំណែទម្រង់នេះត្រូវបានគាំទ្រ និងឯកភាពពីប្រមុខរាជរដ្ឋាភិបាលកម្ពុជា ដូចមានក្នុងអនុ-ក្រឹត្យ លេខ១៣១.អនក្រ.បក ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១៤ ចែកចេញជា ១៦ជំពូក និង ៣៥មាត្រា ដូចខាងក្រោម៖

- ខុទ្ទកាល័យរដ្ឋមន្ត្រី (រក្សាទុកដដែល)
- នាយកដ្ឋានសវនកម្មផ្ទៃក្នុង (រក្សាទុកដដែល) - អគ្គាធិការដ្ឋាន (រក្សាទុកដែល)
- អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ មាននាយកដ្ឋានចំណុះចំនួន ៣ (រក្សាទុកដដែល)
- អគ្គនាយកដ្ឋានពាណិជ្ជកម្មអន្តរជាតិ មាននាយកដ្ឋានចំណុះចំនួន ៥ (បង្កើតថ្មីចំនួន ១នាយកដ្ឋាន ប្តូរឈ្មោះចំនួន ២ នាយកដ្ឋាន រក្សាឈ្មោះដដែល ២ នាយកដ្ឋាន និងមាននាយកដ្ឋាន ២ ផ្ទេរទៅជាអគ្គនាយកដ្ឋានផ្សេង
- អគ្គនាយកដ្ឋានពាណិជ្ជកម្មក្នុងប្រទេស មាននាយកដ្ឋានចំណុះចំនួន ៤ (រក្សាឈ្មោះដដែល ២ នាយកដ្ឋាន និងស្នើសុំបង្កើតថ្មី ២ នាយកដ្ឋាន)
- អគ្គនាយកដ្ឋានសេវាពាណិជ្ជកម្ម មាននាយកដ្ឋានចំណុះចំនួន ៣ និងតំបន់សេដ្ឋកិច្ចពិសេស (រក្សាឈ្មោះដដែល ២ នាយកដ្ឋាន ស្នើសុំបង្កើតថ្មី ១ នាយកដ្ឋាន និងតំបន់សេដ្ឋកិច្ចពិសេស)
- អគ្គនាយកដ្ឋានជំរុញពាណិជ្ជកម្ម មាននាយកដ្ឋានចំណុះចំនួន ៣ (បង្កើតថ្មី ៣ នាយកដ្ឋាន ដោយបំបែកនាយកដ្ឋានដែលផ្ទេរពីអគ្គនាយកដ្ឋានផ្សេង១ ហើយ ដូរឈ្មោះថ្មីទាំងអស់)
- អង្គភាពមូលដ្ឋាន (មន្ទីរពាណិជ្ជកម្មរាជធានី - ខេត្ត រក្សាទុកដដែល)
- អគ្គនាយកដ្ឋានកម្ពុជាពិនិត្យ ទំនិញ នីហវ័ណ អាហារ័ណ និងបង្ក្រាបការក្លែងបន្លំ (កាំកុងត្រូល) (រក្សាទុកដដែល) - សហគ្រាសសាធារណៈ (ក្រុមហ៊ុនហ្គ្រីនត្រេដ - រក្សាទុកដដែល)
- អង្គភាពត្រួតពិនិត្យហិរញ្ញវត្ថុ (រក្សាទុកដដែល)

សរុបមកអគ្គនាយកដ្ឋាន ២ និងនាយកដ្ឋានចំនួន ៩ ត្រូវបានបង្កើតថ្មី។

## ១.២ កំណែទម្រង់ធនធានមនុស្ស

- ការប្រលងជ្រើសរើសមន្ត្រីរាជការ ចូលបម្រើការងារក្នុងក្របខ័ណ្ឌ ក្រសួងពាណិជ្ជកម្មឆ្នាំ២០១៤ បានប្រព្រឹត្តដោយតម្លាភាព និងយុត្តិធម៌ដោយមានកិច្ចសហការយ៉ាងជិតស្និត និងចូលរួមពិនិត្យផ្ទាល់ដោយអង្គភាពប្រឆាំងអំពើពុករលួយ។ ជាលទ្ធផលក្រសួងជ្រើសរើសបាន មន្ត្រីមានសមត្ថភាពចំនួន ៦០រូប និងបានបែងចែកទៅបម្រើការងារតាមអង្គភាពជំនាញរួចហើយ
- តែងតាំងតម្លើងឋានៈ និងសម្រួលភារៈកិច្ច មន្ត្រីចាប់ពីថ្នាក់ប្រធាននាយកដ្ឋានឡើងទៅចំនួន ៣១ នាក់ ក្នុងនោះមានស្ត្រីចំនួន ៥នាក់ តាមរយៈការធ្វើសម្ភាសន៍ពីថ្នាក់ដឹកនាំក្រសួង តាមការដាក់ពិន្ទុរៀងៗខ្លួន និងវាយតម្លៃរួមគ្នារវាងរដ្ឋលេខាធិការទាំងអស់ និងរដ្ឋមន្ត្រីផ្ទាល់ ដើម្បីជ្រើសរើសយកមន្ត្រីដែលមានសមត្ថភាពពិតប្រាកដ ដោយមិនមានបក្សពួក ឬតាមរយៈការផ្តាំផ្ញើ ឬមនោសញ្ចេតនាផ្ទាល់ខ្លួនឡើយ
- ធ្វើការចាប់ឆ្នោតផ្លាស់ប្តូរប៉ុស្តិ៍មន្ត្រីសាខាកាំកុងត្រូល ប្រកបដោយតម្លាភាព និងយុត្តិធម៌ដែលការចាប់ឆ្នោតនេះ ធ្វើឡើងដោយសាមីខ្លួនផ្ទាល់។

## ១.៣ កំណែទម្រង់ក្នុងការផ្តល់សេវាសាធារណៈ

### ១.៣.១ សេវានាំចេញ-នាំចូល

- កែសម្រួលការចុះបញ្ជី សុំសិទ្ធិនាំចេញក្រោមប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម ដែលតម្រូវឲ្យអ្នកនាំចេញមកស្នើសុំជារៀងរាល់ឆ្នាំ ដោយជំនួសវិញនូវការចុះបញ្ជីតែមួយលើកប៉ុណ្ណោះ

- លុបចោលការតម្រូវឲ្យមកសុំវិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញ (CO) ពីក្រសួងសម្រាប់ការនាំចេញក្នុងករណីប្រទេសនាំចូលមិនតម្រូវឲ្យមាន
- អនុវត្តសាកល្បងការចេញវិក្កយបត្រប្រតិវេទន៍បញ្ជាក់ប្រភពដើមទំនិញដោយខ្លួនឯងក្នុងក្របខណ្ឌអាស៊ាន
- បានប្រគល់បន្ថែមសិទ្ធិជូនដល់ថ្នាក់អគ្គនាយក ឲ្យចុះហត្ថលេខាលើវិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញ ដើម្បីកាត់បន្ថយពេលវេលាឲ្យបានកាន់តែលឿនជាងមុនថែមទៀត
- ក្រុមហ៊ុនចុះឈ្មោះប្រើប្រាស់ប្រព័ន្ធស្វ័យប្រវត្តិកម្ម គិតត្រឹមថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០១៤ មានក្រុមហ៊ុនចំនួន ៩១៥ ក្រុមហ៊ុន តែបានស្នើសុំវិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញ (CO) ប្រើប្រាស់ប្រព័ន្ធស្វ័យប្រវត្តិកម្មនេះចំនួនត្រឹមតែ ២២១ ក្រុមហ៊ុនប៉ុណ្ណោះ
- ដើម្បីកាត់បន្ថយពេលវេលា និងនីតិវិធីពុំចាំបាច់ក្នុងកិច្ចសម្រួលពាណិជ្ជកម្ម ក្រសួងកំពុងរៀបចំប្រព័ន្ធទូទាត់កម្រៃសេវាតាមប្រព័ន្ធអេឡិចត្រូនិក E-Payment និង E-Banking សម្រាប់ការបង់កម្រៃសេវានានា ដោយវិស័យឯកជន ឲ្យមានលក្ខណៈងាយស្រួល និងងាយបញ្ជូនថវិកាទៅរតនាគារជាតិក្នុងរយៈពេលតែមួយថ្ងៃប៉ុណ្ណោះ
- កំណត់តម្លៃគ្រប់គ្រងការនាំចេញ (Export Management Fee) មុខទំនិញថ្មីៗ ហើយបានបញ្ជូនទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីអនុម័តកម្រៃថ្មីនេះ
- បង្កើតគេហទំព័រ http://ico.moc.gov.kh សម្រាប់ក្រុមហ៊ុនស្នើសុំវិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញ (CO) តាមប្រព័ន្ធស្វ័យប្រវត្តិកម្ម ដែលគ្រោងនឹងដាក់ឲ្យដំណើរការនៅត្រីមាសទី២ ឆ្នាំ២០១៥។ បច្ចុប្បន្ននេះ តាមរយៈប្រព័ន្ធបច្ចេកវិទ្យាបណ្តោះអាសន្នមួយ យើងទទួលបានពាក្យសុំ C/O ប្រមាណ ៧០% ដែលបានដាក់បញ្ជូនតាមប្រព័ន្ធនេះ មកក្រសួងពាណិជ្ជកម្ម ហើយប្រព័ន្ធនេះបានជួយកាត់បន្ថយពេលវេលាក្នុងការចេញ C/O នេះបាន២ថ្ងៃថែមទៀត សម្របសម្រួលជាមួយសមាគមរោងចក្រកាត់ដេរនៅកម្ពុជា (GMAC) ក្នុងការកាត់បន្ថយកម្រៃសមាជិកភាពចំនួន ២០% ក្នុងមួយឆ្នាំ ដោយណែនាំឲ្យរោងចក្រយកប្រាក់ ២០% នេះទៅប្រើប្រាស់សម្រាប់ជាប្រយោជន៍ដល់កម្មករ កម្មការិនី
- កំពុងរៀបចំបែបបទ ដែលអនុញ្ញាតឲ្យអ្នកនាំចេញ បញ្ចូលទិន្នន័យសម្រាប់យកមកបោះពុម្ពវិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញ ដោយខ្លួនឯង ករណីក្រុមហ៊ុនមិនទាន់រៀបចំខ្លួនស្រេចបាច់សម្រាប់ចូលប្រព័ន្ធស្វ័យប្រវត្តិកម្ម
- ចុះហត្ថលេខាជាមួយអង្គការ ILO លើអនុស្សរណៈ ស្តីពីកម្មវិធីរោងចក្រកាន់តែប្រសើរនៅកម្ពុជា (Batter Factories Cambodia-BFC) ដែលនឹងជួយលើកស្ទួយស្តង់ដារការងារជូនកម្មករ កម្មការិនី
- បង្កើតខ្សែទូរស័ព្ទទាន់ហេតុការណ៍ និងប្រព័ន្ធទំនាក់ទំនងសង្គម (Facebook) របស់ក្រសួងពាណិជ្ជកម្ម សម្រាប់ឲ្យពាណិជ្ជករ និងប្រជាពលរដ្ឋសាកសួរព័ត៌មាន និងតវ៉ារាល់បញ្ហាអសកម្មដែលជួបប្រទះក្នុងការងារពាក់ព័ន្ធសេវាពាណិជ្ជកម្ម។ ដែលគិតមកដល់ថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៤ មានអ្នកគាំទ្រចំនួន ២៦៥.០០០ នាក់ បានចូលរួមក្នុងប្រព័ន្ធទំនាក់ទំនងសង្គមរបស់ក្រសួងពាណិជ្ជកម្ម
- ចុះកិច្ចសន្យាជាមួយក្រុមហ៊ុនក្រីមសុនឡូជីក (CRIMSONLOGICS) របស់ប្រទេសសិង្ហបុរីមករៀបចំប្រព័ន្ធស្វ័យប្រវត្តិកម្ម សម្រាប់ការចេញវិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញ នៅក្នុងខែកញ្ញា ឆ្នាំ២០១៤។

## ១.៣.២ ការចុះបញ្ជីពាណិជ្ជកម្ម

- បង្កើតបញ្ជរតែមួយ លើការងារស្វែងរកឈ្មោះក្រុមហ៊ុនសម្រាប់ចុះបញ្ជីពាណិជ្ជកម្ម និងសម្រួលដំណើរការនៃការចុះបញ្ជីពាណិជ្ជកម្ម ដែលនឹងជួយកាត់បន្ថយនីតិវិធីពុំចាំបាច់ និងសោហ៊ុយចំណាយក្រៅផ្លូវការ និងកំណត់ពេលវេលាសម្រាប់ការចុះបញ្ជីក្រុមហ៊ុន សហគ្រាសមិនឲ្យលើសពី៥ថ្ងៃធ្វើការ
- ក្រសួងពាណិជ្ជកម្មក៏បានផ្តួចផ្តើមរៀបចំផងដែរ នូវប្រព័ន្ធនៃការចុះបញ្ជីតាម **អនឡាញ** ដែលគ្រោងនឹងបញ្ចប់នាចុងឆ្នាំ២០១៥ ខាងមុខនេះ ហើយប្រព័ន្ធនេះនឹងប្រើប្រាស់ពេលវេលាយ៉ាងយូរបំផុត ១ម៉ោង ក្នុងការចុះបញ្ជីក្រុមហ៊ុន
- កែសម្រួលបន្ថែមទូរក្នុងឃ្លាំងតម្កល់ឯកសារ និងរៀបចំទៅតាមលក្ខណៈបច្ចេកទេសដើម្បីបង្កភាពងាយស្រួលក្នុងការរក្សាទុក និងស្វែងរកឯកសារដែលបានចុះបញ្ជីរួច
- កាត់បន្ថយនីតិវិធី បែបបទតម្រូវការឯកសារដែលមិនចាំបាច់ និងគំរូពាក្យស្នើសុំឲ្យកាន់តែខ្លី និងមានភាពងាយស្រួល
- ចំពោះការសុំចុះបញ្ជីក្រុមហ៊ុនថ្មី និងការលក់ ឬផ្ទេរភាគហ៊ុន មិនតម្រូវឲ្យអ្នកស្នើសុំចុះបញ្ជី ឬម្ចាស់ហ៊ុន ឬអភិបាលមកបង្ហាញខ្លួននៅ ចំពោះមុខមន្ត្រីក្រសួងទៀតទេ ដោយគ្រាន់តែមានការបញ្ជាក់អំពីមេធាវី ឬសារការី ឬសាក្សីស្របច្បាប់តែប៉ុណ្ណោះ
- រៀបចំក្រុមការងារបច្ចេកទេសចម្រុះរវាងអគ្គនាយកដ្ឋានពន្ធដារ និងនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្មដើម្បីផ្តល់ព័ត៌មានទៅវិញទៅមក ក្នុងការតាមដានស្ថានភាពសហគ្រាស-ក្រុមហ៊ុនក្រោយការចុះបញ្ជី
- បានកែសម្រួលគំរូពាក្យសុំចុះបញ្ជីពាណិជ្ជកម្មសម្រាប់ការចុះបញ្ជីថ្មី ការកែប្រែ និងគំរូប្រតិវេទន៍ប្រចាំឆ្នាំឲ្យកាន់តែខ្លី ងាយយល់ និងងាយស្រួលដល់ពាណិជ្ជករក្នុងការបំពេញ។ គំរូពាក្យសុំចុះបញ្ជីពាណិជ្ជកម្មសម្រាប់ការចុះបញ្ជីថ្មីត្រូវបានដាក់ឲ្យប្រើជាផ្លូវការ កាលពីដើមខែកញ្ញា ឆ្នាំ២០១៤
- ការភ្ជាប់លិខិតតម្កល់ដើមទុននៅធនាគារសម្រាប់ការសុំចុះបញ្ជីពាណិជ្ជកម្មក្រុមហ៊ុនថ្មី អាចភ្ជាប់តែ០១ច្បាប់ដើម ដែលមុនតម្រូវឲ្យភ្ជាប់ ០២ច្បាប់ដើម
- កំពុងសហការជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និង ACU រៀបចំកំណត់បន្ថែមនូវកម្រៃសេវានៃការចុះបញ្ជីពាណិជ្ជកម្មលើជំពូកផ្សេងៗទៀតដែលពុំទាន់បានកំណត់ពីមុនមក និងកែសម្រួលរួមបញ្ចូលគ្នានូវកម្រៃសេវាខ្លះ ដើម្បីឲ្យស្របតាមមាត្រាច្បាប់ផង និងដើម្បីកាត់បន្ថយពេលវេលា និងបែបបទ
- កំពុងរៀបចំ និងចងក្រងជាប្រកាសរួមថ្មីមួយ ស្តីពីការដាក់ឲ្យប្រើប្រាស់វិធានស្តីពីការចុះបញ្ជីពាណិជ្ជកម្ម និងការគ្រប់គ្រងសមត្ថភាពពាណិជ្ជកម្ម សហគ្រាស-ក្រុមហ៊ុនសំដៅកាត់បន្ថយបែបបទ និងតម្រូវការឯកសារនានា ដែលមិនចាំបាច់
- ក្រុមការងារសិក្សាប្រព័ន្ធស្វ័យប្រវត្តិកម្ម ការចុះបញ្ជីពាណិជ្ជកម្ម ដឹកនាំដោយឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម បានចុះទៅទស្សនៈកិច្ចសិក្សានៅប្រទេសញូហ្ស៊ីឡែនដើម្បីដកស្រង់បទពិសោធន៍ ស្តីពីការអនុវត្តល្អក្នុងការប្រើប្រាស់ប្រព័ន្ធស្វ័យប្រវត្តិកម្មរបស់ប្រទេសនេះ។

### ១.៣.៣ ការផ្តល់សេវាកម្មសិទ្ធិបញ្ញា

- បានរៀបចំកែសម្រួលប្រព័ន្ធចុះបញ្ជីម៉ាកតាមប្រព័ន្ធស្វ័យប្រវត្តិកម្ម ដើម្បីកាត់បន្ថយពេលវេលាក្នុងការចុះបញ្ជី និងសម្រួលការស្វែងរកម៉ាកដែលបានចុះបញ្ជីរួចនៅកម្ពុជា និងអាស៊ានតាមរយៈគេហទំព័រ www.cambodiaip.gov.kh
- ត្រៀមរៀបចំចូលក្នុង ប្រព័ន្ធចុះបញ្ជីម៉ាកជាលក្ខណៈអន្តរជាតិ (Madrid Protocol) ដើម្បីឆ្លើយតបទៅនឹងកាតព្វកិច្ចតម្រូវរបស់សហគមន៍អាស៊ាន និងអង្គការកម្មសិទ្ធិបញ្ញាពិភពលោក (WIPO)
- បង្កើតបញ្ជរព័ត៌មានឆ្លើយតប ការងារពាក់ព័ន្ធនឹងកម្មសិទ្ធិបញ្ញា និងកែសម្រួលគេហទំព័រកម្មសិទ្ធិបញ្ញា សំដៅផ្តល់ព័ត៌មានឆាប់រហ័សដល់សាធារណៈជន ក្នុងការស្រាវជ្រាវ និងយល់ដឹងអំពីការចុះបញ្ជីកម្មសិទ្ធិបញ្ញា
- ត្រៀមបញ្ចប់នីតិវិធី និងបែបបទក្នុងការចុះបញ្ជីម៉ាកសមូហភាព និងម៉ាកបញ្ជាក់ពីចរិកលក្ខណៈទំនិញ និងសេវា ដើម្បីសម្រួលដល់ការចុះបញ្ជីម៉ាកទាំងពីរប្រភេទនេះ ដល់ក្រុមផលិតករ និងបុគ្គលពាក់ព័ន្ធ

### ១.៣.៤ ការផ្តល់សេវានៅថ្នាក់ក្រោមជាតិ

- ធ្វើប្រតិភូកម្មការងារចេញ វិញ្ញាបនបត្រប្រកបអាជីវកម្មគ្រឿងអលង្ការ ត្បូងថ្ម លោហៈធាតុមានតម្លៃ ពីថ្នាក់ក្រសួងទៅ ថ្នាក់រាជធានី-ខេត្ត បង្កលក្ខណៈងាយស្រួលដល់អាជីវករក្នុងការ ស្នើសុំសេវា នៅមូលដ្ឋានផ្ទាល់បានងាយស្រួល និងចំណេញពេលវេលា
- ធ្វើប្រតិភូកម្មការចេញវិញ្ញាបនបត្រប្រកបអាជីវកម្ម សេវាកម្ម ជូនការិយាល័យច្រកចេញ-ចូលតែមួយនៅគ្រប់ខ័ណ្ឌក្នុងរាជធានីភ្នំពេញ ចំពោះផ្ទៃក្រឡាប្រកបអាជីវកម្មទំហំតូចជាង៥ម៉ែត្រការ៉េ។

## ១.៤ កំណែទម្រង់រដ្ឋបាល - ហិរញ្ញវត្ថុ

- បើកគណនីជូនមន្ត្រីរាជការក្រសួងពាណិជ្ជកម្មចំនួន ១.៥៩២នាក់ ដែលក្នុងនោះមានថ្នាក់រដ្ឋបាលកណ្តាល និងថ្នាក់រាជធានី-ខេត្ត ហើយមន្ត្រីបានធ្វើការបើកប្រាក់បៀវត្សចំនួន ១.១៣៩នាក់ តាមប្រព័ន្ធធនាគារកាណាឌីយ៉ា
- រៀបចំកែលម្អទីធ្លា សួនច្បារ និងគំនូសចរាចរ និងចំណតរថយន្តក្នុងបរិវេណទីស្តីការក្រសួង និងជួសជុលការិយាល័យថ្នាក់ដឹកនាំ និងនាយកដ្ឋានមួយចំនួនដើម្បីឲ្យមានសោភណ័ភាព
- កែសម្រួលកម្រៃសេវា និងប្រាក់រង្វាន់លើកទឹកចិត្តជូនមន្ត្រីរាជការឲ្យបានសមរម្យ ដែលពីមុនធ្លាប់រក្សាទុកតាមនាយកដ្ឋានជំនាញរៀងៗខ្លួន មកប្រមូលផ្តុំក្នុងកញ្ចប់រួមតែមួយ ដោយធ្វើការបែងចែកជូនត្រលប់ទៅវិញ ទៅតាមប្រភេទឋានានុក្រម និងកម្រិតសកម្មការងារ ហើយធានាបាននូវការផ្តល់ជូនប្រាក់រង្វាន់មន្ត្រីបានសមស្រប និងធានាបានប្រសិទ្ធិភាពក្នុងការប្រមូលចំណូលមកវិញ ដែលបានបែងចែកជូនដល់មន្ត្រីគ្រប់លំដាប់ថ្នាក់តាំងពីរដ្ឋបាលកណ្តាលរហូតដល់ថ្នាក់ក្រោមជាតិ
- រៀបចំបញ្ជរបង់ប្រាក់តែមួយកន្លែង ដើម្បីសម្រួលការងារដល់ផ្នែកឯកជន ក្នុងការមកស្នើសុំសេវាសាធារណៈ ក៏ដូចជាងាយស្រួលប្រមូលផ្តុំគ្រប់គ្រង និងបូកសរុបចំណូលសេវានេះ

- បំពាក់ម៉ាស៊ីនស្កេនម្រាមដៃនៅគ្រប់នាយកដ្ឋាន ដើម្បីពង្រឹងវិន័យការងារ របស់មន្ត្រីរាជការក្នុងទីស្តីការក្រសួង និងក៏ជាមូលដ្ឋានសម្រាប់ការគណនា និងវាយតម្លៃកម្រិតសកម្មផ្តល់រង្វាន់ជូនមន្ត្រីរាជការឲ្យបានសុក្រឹតបន្ថែមទៀត
- ខិតខំប្រឹងប្រែងរកចំណូលទិញបន្ថែមរថយន្តថ្មីចំនួន ០២គ្រឿង សម្រាប់សម្រួលដល់ការដឹកជញ្ជូនមន្ត្រីរាជការ ដែលមានទីលំនៅនៅឆ្ងាយ និងសម្រាប់បំពេញការងារផ្សេងៗ
- ចែករំលែកថវិកាពីការសន្សំខ្ទង់ចំណូលប្រាក់រង្វាន់របស់ក្រសួង ផ្តល់ជូនគ្រប់មន្ទីររាជធានី-ខេត្ត ជាសម្ភារៈដូចជា៖ ម៉ាស៊ីនកុំព្យូទ័រ ព្រីនធើ និងម៉ាស៊ីនថតចម្លង ដើម្បីសម្រួលការងាររដ្ឋបាលនៅថ្នាក់ក្រោមជាតិ។

## ១.៥ ការងារស្ថិតិ និងព័ត៌មានពាណិជ្ជកម្ម

- តម្លើង និងតភ្ជាប់ប្រព័ន្ធព័ត៌មានវិទ្យា (ICT) តាមបណ្តាមន្ទីរពាណិជ្ជកម្មរាជធានី-ខេត្ត និងតំបន់សេដ្ឋកិច្ចពិសេសចំនួន ៣៣ កន្លែង ដើម្បីសម្រួលដល់ការផ្តល់ព័ត៌មានពាណិជ្ជកម្ម និងសម្រួលការងារប្រតិភូកម្មដែលបានផ្តល់ជូនមូលដ្ឋានទាំងនោះ
- កំពុងរៀបចំនីតិវិធី និងបញ្ញត្តិច្បាប់សម្រាប់បង្កើតក្រុមការងារ អនុវត្តផែនការវេបសាយព័ត៌មានពាណិជ្ជកម្ម ដើម្បីភ្ជាប់ទៅនឹងវេបសាយព័ត៌មានពាណិជ្ជកម្មថ្នាក់ជាតិ តាមតម្រូវការរបស់សហគមន៍អាស៊ាន
- រៀបចំកែសម្រួលព្រឹត្តិបត្រព័ត៌មានពាណិជ្ជកម្ម របស់ក្រសួងដោយបន្ថែមខ្លឹមសារ និងមាតិកាសំខាន់ៗ មួយចំនួនដើម្បីផ្តល់ព័ត៌មានឲ្យកាន់តែមានប្រសិទ្ធិភាពដល់ធុរជន និងទាក់ទាញការផ្សព្វផ្សាយពាណិជ្ជកម្មផ្សេងៗ ដោយរៀបចំអត្ថបទអំពីសកម្មភាពរបស់ ឯកឧត្តមទេសរដ្ឋមន្ត្រីជាពីរភាសា គឺភាសាខ្មែរ និងភាសាអង់គ្លេស ដែលពីមុនយើងមានតែភាសាខ្មែរប៉ុណ្ណោះហើយក្រសួងនឹងខិតខំបន្ថែមទៀត ដើម្បីអោយសៀវភៅនេះទាំងមូល បានបកប្រែជាពីរភាសាទាំងស្រុងឲ្យស្របទៅតាមការចង់បានរបស់អ្នកប្រើប្រាស់ ក៏ដូចជាបណ្តាអង្គទូតនានាប្រចាំនៅ ព្រះរាជាណាចក្រកម្ពុជាយើងផងដែរ។

## ១.៦ ការងារកាំកុងត្រូល

- កែសម្រួលនីតិវិធី និងបែបបទការងារត្រួតពិនិត្យផលិតផលទំនិញសម្លៀកបំពាក់ និងវាយនភ័ណ្ឌនាំចេញ ដោយត្រួតពិនិត្យរូបវន្តមិនលើសពី ២% ស្របតាមការកំណត់របស់ប្រមុខរាជរដ្ឋាភិបាល
- ធ្វើប្រតិភូកម្មអំណាចឲ្យសាខាកាំកុងត្រូលរាជធានី-ខេត្ត ដើម្បីទទួលខុសត្រូវ ចំពោះការនាំចេញត្រឡប់ទៅវិញនូវវត្ថុធាតុដើម និងផលិតផលសម្រេចដែលពីមុនការសម្រេចស្ថិតនៅថ្នាក់កណ្តាល
- ដំណើរការរៀបចំផ្លាស់ប្តូរមន្ត្រីនៅតាមការិយាល័យ និងសាខាកាំកុងត្រូលទៅតាមទិសដៅកំណត់ដោយការចាប់ឆ្នោត ធ្វើឡើងដោយសាមីខ្លួនផ្ទាល់ ប្រកបដោយតម្លាភាព និងប្រសិទ្ធភាព។

## ២. សកម្មភាពពាណិជ្ជកម្មដើម្បីចូលរួមយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣

### ២.១ លទ្ធផលនៃការបម្រើសេវាសាធារណៈ

#### ២.១.១ ការងារកម្មសិទ្ធិបញ្ញា

- សហការពិនិត្យជាមួយក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ក្នុងការផ្តល់សន្តតិកម្ម បទចំរៀងរបស់តារាចំរៀងឯក **ស៊ីន ស៊ីសាមុត** ឲ្យទៅសមាជិកគ្រួសារ ហើយ **សម្តេចតេជោនាយករដ្ឋមន្ត្រី** បានឯកភាពជាគោលការណ៍នៅថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០១៤
- បានចូលជាសមាជិក (Associate Member) នៃអង្គការអន្តរជាតិ OriGIn ក្រោមការឧបត្ថម្ភរបស់ទីភ្នាក់ងារបារាំងដើម្បីការអភិវឌ្ឍន៍ (AFD) និងអង្គការស្បៀងអាហារ និងកសិកម្មពិភពលោក (Food and Agriculture of the United Nation, FAO)
- សិក្សាស្រាវជ្រាវទំនិញសក្តានុពលចំនួន ០៣មុខ គឺអង្ករបាត់ដំបង ស្ករត្នោតកំពង់ស្ពឺ និងធុរេនកំពត ជាម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ និងបានរៀបចំឯកសារស្នើសុំចុះបញ្ជីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ "ម្រេចកំពត" នៅសហគមន៍អឺរ៉ុប។ ជាលទ្ធផលសហគមន៍អឺរ៉ុប បានទទួលពាក្យស្នើសុំចុះបញ្ជីម្រេចកំពតរបស់កម្ពុជារួចហើយ
- ទទួលពាក្យស្នើសុំចុះបញ្ជីម៉ាកបានចំនួន ៥.៤៣៤ម៉ាក និងបានចុះបញ្ជីម៉ាកចំនួន ៣.៧៦៩ម៉ាក ប្រៀបធៀបនឹងឆ្នាំ២០១៣ មានការកើនឡើង ០,២% ចំពោះការទទួលពាក្យ និងថយចុះ ១៨,៨% ចំពោះការចុះបញ្ជីម៉ាក
- ទទួលការដាក់ពាក្យបញ្ជាក់ភាពប្រើប្រាស់ ឬមិនបានប្រើប្រាស់ម៉ាក ក្រោយចុះបញ្ជីចំនួន ១.៨១៥ ម៉ាក ការផ្លាស់ប្តូរផ្សេងៗ ១.២២៩ម៉ាក ចុះបញ្ជីសារឡើងវិញ ១.៤២៤ម៉ាក ទទួលស្គាល់សិទ្ធិផ្តាច់មុខ ៥៤ម៉ាក ស្នើសុំកត់ត្រាអាជ្ញាប័ណ្ណ ២៥ម៉ាក និងការធ្វើទុតិយតាវិញ្ញាបនបត្រ ៤១២ម៉ាក
- ព្រឹត្តិប័ត្រផ្លូវការ (Official Gazette) ការងារកម្មសិទ្ធិបញ្ញាត្រូវបានបង្ហោះតាមគេហទំព័រ www.cambodiaip.gov.kh ជំនួសឲ្យការបោះពុម្ពដែលធ្លាប់ធ្វើកន្លងមក
- ទទួលពាក្យបណ្តឹងទប់ស្កាត់ការរំលោភបំពានបានចំនួន ៤៦ករណី ហើយដោះស្រាយបាន ៣៤ករណី បើប្រៀបធៀបនឹងឆ្នាំ២០១៣ មានការថយចុះចំនួន ៤១,៦៦%
- ទទួលពាក្យបណ្តឹងលុបម៉ាកបានចំនួន ៥៧ករណី ហើយលុបម៉ាកចេញពីបញ្ជីបានចំនួន ១៨ករណី នៅ ៣៩ករណី ទៀតបន្តដោះស្រាយនៅឆ្នាំបន្ទាប់។

#### ២.១.២ ការចុះបញ្ជីពាណិជ្ជកម្ម និងការផ្តល់សេវាពាក់ព័ន្ធ

- ចុះបញ្ជីថ្មីក្រុមហ៊ុន ការិយាល័យតំណាងពាណិជ្ជកម្ម និងសាខាក្រុមហ៊ុនបរទេសបានចំនួន ៣.៦១៨ក្រុមហ៊ុន មានកំណើន ៣១,១៨% ធៀបនឹងឆ្នាំ២០១៣
- ចុះបញ្ជីថ្មីសហគ្រាសឯកបុគ្គលមានចំនួន ៧៨៦សហគ្រាស មានកំណើន ៣៩,៣៦% ធៀបនឹងឆ្នាំ២០១៣
- ចុះបញ្ជីការកែប្រែក្រុមហ៊ុន ការិយាល័យតំណាងពាណិជ្ជកម្ម សាខាក្រុមហ៊ុនបរទេស មានចំនួន ២.៩៩៨ក្រុមហ៊ុន មានកំណើន ២៤,៩១% ធៀបនឹងឆ្នាំ២០១៣
- ចុះបញ្ជីកែប្រែរបស់សហគ្រាសឯកបុគ្គលចំនួន ៣៤៣សហគ្រាស មានកំណើន ៤០៤,៤១%ធៀបនឹងឆ្នាំ២០១៣

- លុបឈ្មោះចេញពីបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន ការិយាល័យតំណាងពាណិជ្ជកម្ម សាខាក្រុមហ៊ុនបរទេសចំនួន ៥៥ក្រុមហ៊ុន មានកំណើន ១៦១,៩% ធៀបនឹងឆ្នាំ២០១៣
- ប្តូរវិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្មចំនួន ២.០៦២ក្រុមហ៊ុន មានកំណើន ៣៦,២៨% ធៀបនឹងឆ្នាំ២០១៣
- តម្កល់ប្រតិវេទន៍ប្រចាំឆ្នាំចំនួន ៩.៥៨១ក្រុមហ៊ុន មានកំណើន ២៧,៩២% ធៀបនឹងឆ្នាំ២០១៣
- បានថតចម្លងឯកសារចុះបញ្ជីពាណិជ្ជកម្មបានចំនួន ២៣៧ច្បាប់ មានកំណើន ៦០,១៣% ធៀបនឹងឆ្នាំ២០១៣។

## ២.១.៣ ការផ្តល់សេវានាំចេញ-នាំចូល

- ចុះបញ្ជីផ្តល់សិទ្ធិនាំចេញក្រោមប្រព័ន្ធអនុគ្រោះពន្ធដូចតទៅ ៖
  - ➢ រោងចក្រ ឬក្រុមហ៊ុនកាត់ដេរសម្លៀកបំពាក់ ចំនួន : ៧៦ ក្រុមហ៊ុន
  - ➢ រោងចក្រផលិតស្បែកជើង ចំនួន : ០៨ ក្រុមហ៊ុន
  - ➢ រោងចក្រផ្សេងៗ ចំនួន : ១៦១ ក្រុមហ៊ុន

រោងចក្រកាត់ដេរសម្លៀកបំពាក់ ស្បែកជើង ទោចក្រយាន និងរោងចក្រផលិតមុខទំនិញផ្សេងៗ ដំណើរការចំនួន ៧៣៧រោងចក្រ បានប្រើប្រាស់កម្លាំងពលកម្មសរុបចំនួន ៥៨៧.៣០០នាក់ (កម្មការិនីចំនួន ៥០៩.៧៣១នាក់) ស្រូបបានបៀវត្សប្រមាណជាង ៩៩,១១លានដុល្លារក្នុងមួយខែ។ ក្នុងនោះរោងចក្រកាត់ដេរសម្លៀកបំពាក់ និងវាយនភ័ណ្ឌចំនួន ៥៩២រោងចក្រ មានកម្លាំងកម្មករបម្រើការងារចំនួន ៩៦៧.២៥៥នាក់ (កម្មការិនីចំនួន ៤០២.៥៧៨នាក់) ស្រូបបានបៀវត្សប្រមាណជាង ៧៨,៤៥លានដុល្លារក្នុងមួយខែ និងរោងចក្រផលិតស្បែកជើងចំនួន ៦៦រោងចក្រ មានកម្លាំងកម្មករបម្រើការងារសរុបចំនួន ៨៦.៦៧០នាក់ (កម្មការិនីចំនួន ៧៧.៥៧៨នាក់) ស្រូបបានបៀវត្សប្រមាណជាង ១៣,៨៧លានដុល្លារក្នុងមួយខែ

- ការផ្តល់វិញ្ញាបនបត្រប្រភពបញ្ជាក់ប្រភពដើមទំនិញ និងអាជ្ញាប័ណ្ណសម្រាប់នាំចេញលើមុខទំនិញសំខាន់ៗរួមមាន: សម្លៀកបំពាក់ ស្បែកជើង អង្ករ កសិផល ទោចក្រយាន និងផលិតផលផ្សេងៗទៀតក្នុងឆ្នាំ២០១៩៖
  - ➢ ទីផ្សារសហរដ្ឋអាមេរិក: មានទឹកប្រាក់សរុបចំនួន ១.៧២៥,០២លានដុល្លារអាមេរិក បើធៀបនឹងរយ:ពេលដូចគ្នាក្នុងឆ្នាំកន្លងទៅ មានការថយចុះ ១៦,៦១%
  - ➢ ទីផ្សារកាណាដា: មានទឹកប្រាក់សរុបប្រមាណ ៥៩៩,១១លានដុល្លារអាមេរិក បើធៀបនឹងរយ:ពេលដូចគ្នាក្នុងឆ្នាំកន្លងមក មានការកើនឡើង ២២,៨៨%
  - ➢ ទីផ្សារផ្សេងៗក្រៅពីសហរដ្ឋអាមេរិក និងកាណាដា: មានទឹកប្រាក់សរុប ១៥៣,០៩លានដុល្លារអាមេរិក បើធៀបនឹងរយ:ពេលដូចគ្នាក្នុងឆ្នាំកន្លងមក មានការកើនឡើង ២៧,៤៣%
  - ➢ នាំចេញទៅសហគមន៍អឺរ៉ុប (EU): មានទឹកប្រាក់សរុបប្រមាណ ២.៣៥៣,៤៩លានដុល្លារអាមេរិក បើធៀបនឹងរយ:ពេលដូចគ្នាក្នុងឆ្នាំកន្លងមក មានការកើនឡើង ១១,០៦%
  - ➢ នាំចេញទៅក្រៅសហគមន៍អឺរ៉ុប (NON-EU): មានទឹកប្រាក់សរុបប្រមាណ ១០២,១៦លានដុល្លារអាមេរិក បើធៀបនឹងរយ:ពេលដូចគ្នាក្នុងឆ្នាំកន្លងមក មានការថយចុះ ៦,៥៩%
  - ➢ នាំចេញទៅទ្វីបអាហ្វ្រិក: មានទឹកប្រាក់សរុបប្រមាណ ១៩,៤៧លានដុល្លារអាមេរិក បើធៀបនឹងរយ:ពេលដូចគ្នាក្នុងឆ្នាំកន្លងមក មានការថយចុះ ៤៧,៩៨%

- ការនាំចេញទៅទ្វីបអាស៊ី និងអូសេអានី: មានទឹកប្រាក់សរុបចំនួន ៨៣៩,៥៩លានដុល្លារអាមេរិក បើធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំកន្លងទៅ មានការកើនឡើង ០,៣៦% (ក្នុងនោះកសិផលនាំចេញទៅសាធារណរដ្ឋសង្គមនិយមវៀតណាម ក្រោមប្រព័ន្ធអនុគ្រោះពន្ធអាត្រាសូន្យភាគរយពីវៀតណាម មានទឹកប្រាក់សរុប ៤៩,៨០លានដុល្លារអាមេរិក បើធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំកន្លងមក មានការថយចុះ ៣០,៧៨%)
- បានចេញអាជ្ញាប័ណ្ណនាំចេញ មានទឹកប្រាក់សរុបប្រមាណ ៧៣,៣៦លានដុល្លារអាមេរិក បើធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំកន្លងមក មានការកើនឡើង ៧៧,៣៥%
- បានចេញអាជ្ញាប័ណ្ណនាំចូល មានទឹកប្រាក់សរុបប្រមាណ ០,៤៩លានដុល្លារអាមេរិក បើធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំកន្លងមក មានការកើនឡើង ១៦០%
- បានចេញលិខិតជូនដំណឹង ស្តីពីការដឹកជញ្ជូនឆ្លងកាត់ផលិតផលហាមឃាត់ តាមកិច្ចព្រមព្រៀងស្តីពីការដឹកជញ្ជូនឆ្លងកាត់រវាង ព្រះរាជាណាចក្រកម្ពុជា - សាធារណរដ្ឋសង្គមនិយមវៀតណាមបានចំនួន ១៤ច្បាប់

- ការងារធ្វើអធិការកិច្ចពាក់ព័ន្ធនឹងការនាំចេញ: បានបញ្ចូល និងបានធ្វើការកាត់សន្និធិវត្ថុធាតុដើមជូនរោងចក្រផលិតទំនិញទាំងអស់ សម្រាប់ការនាំចេញទៅកាន់ទីផ្សារពិភពលោក
- សហការឆ្លើយបំភ្លឺជាប្រចាំនូវរាល់បញ្ហា ឬចម្ងល់នានា របស់មន្ត្រីគយនៃប្រទេសនាំចូល ពីសហគមន៍អឺរ៉ុប ក្រៅសហគមន៍អឺរ៉ុប និងប្រទេសនាំចូលដទៃទៀត ចំពោះវិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញចេញដោយក្រសួងពាណិជ្ជកម្ម
- ការចេញវិញ្ញាបនបត្រនាំចូល-នាំចេញ ត្បូងថ្មមិនទាន់កែច្នៃតាមប្រព័ន្ធ Kimberly Process អនុវត្តបានចំនួន ១៨វិញ្ញាបនបត្រ។

## ២.២ ការងារសមាហរណកម្មសេដ្ឋកិច្ចតំបន់ អនុតំបន់ និងដៃគូ

### ២.២.១ អាស៊ាន-ចិន

- ចូលរួមកិច្ចប្រជុំគណៈកម្មាធិការចម្រុះ ស្តីពីកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ាន-ចិន (ACFTA JC) លើកទី៥ និងលើកទី៦ ដើម្បីពិភាក្សាលើការអនុវត្ត និងចរចាបង្កើនកម្រិតកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ាន-ចិន។ ជាលទ្ធផលកិច្ចប្រជុំរដ្ឋមន្ត្រីសេដ្ឋកិច្ចអាស៊ាន-ចិនលើកទី១១ នៅថ្ងៃទី២៦ ខែសីហា ឆ្នាំ ២០១៤ នៅទីក្រុងណៃពិដោ បានអនុម័តលើឯកសារគោលសម្រាប់បង្កើនកម្រិតកិច្ចព្រមព្រៀងតំបន់ពាណិជ្ជកម្មសេរីអាស៊ាន-ចិន និងឯកសារពាក់ព័ន្ធ និងផ្តល់សិទ្ធិឲ្យគណៈកម្មាធិការចម្រុះស្តីពីតំបន់ពាណិជ្ជកម្មសេរីអាស៊ាន-ចិន ចាប់ផ្តើមចរចាការបង្កើនកម្រិត។ រដ្ឋមន្ត្រីបានជំរុញឲ្យក្រុមជំនាញបញ្ចប់ការចរចាជំពូក ស្តីពីនីតិវិធីគយ និងសម្រួលពាណិជ្ជកម្ម និងបញ្ចប់គោលការណ៍ សម្រាប់ផ្ទេរតារាងកាត់បន្ថយពន្ធគយ ក្រោមកិច្ចព្រមព្រៀងទំនិញអាស៊ាន-ចិន ឲ្យបានឆាប់។ កិច្ចប្រជុំ ACFTA JC លើកទី៦ នៅក្នុងខែកញ្ញា ឆ្នាំ២០១៤ បានបង្កើតឡើងវិញនូវក្រុមការងារសេវាកម្ម ដើម្បីចរចាកញ្ចប់សន្យាសេវាទី៣ ក្រោមកិច្ចព្រមព្រៀងពាណិជ្ជកម្មសេវាអាស៊ាន-ចិន និងក្រុមការងារវិនិយោគ ដើម្បីពិភាក្សាកែលម្អកិច្ចព្រមព្រៀងវិនិយោគអាស៊ាន-ចិន
- ពិធីសារដើម្បីបញ្ចូលរបាំងបច្ចេកទេសលើពាណិជ្ជកម្ម និងវិធានការអនាម័យ និងភូតគាមអនាម័យទៅក្នុង កិច្ចព្រមព្រៀងទំនិញអាស៊ាន-ចិន ដែលបានចុះហត្ថលេខានៅក្នុង ខែវិច្ឆិកា

ឆ្នាំ២០១២ នៅទីក្រុងភ្នំពេញ ត្រូវបានសភាជាតិកម្ពុជាផ្តល់សច្ចាប័ន និងដាក់ឲ្យប្រើប្រាស់ដោយព្រះរាជក្រមចុះថ្ងៃទី០៩ ខែមករា ឆ្នាំ២០១៤

- រដ្ឋមន្ត្រីសេដ្ឋកិច្ចអាស៊ាន-ចិនលើកទី១១ បានកត់សម្គាល់ការអភិវឌ្ឍន៍ថ្មីៗ នៃផែនទីវិថីសហប្រតិបត្តិការសេដ្ឋកិច្ចតាមឈូងសមុទ្រ Pan-Beibu ក្រោមការឧបត្ថម្ភពី ADB ដើម្បីជំរុញសហប្រតិបត្តិការសេដ្ឋកិច្ចរវាងខេត្តតាមឆ្នេរសមុទ្ររបស់ប្រទេសចិន និងប្រទេសសមាជិកអាស៊ាននីមួយៗ។ ប្រទេសកម្ពុជាបានគាំទ្រដល់ផែនទីវិថីនេះ ព្រោះវាមានសារៈសំខាន់សម្រាប់ការតភ្ជាប់របស់កម្ពុជា
- រដ្ឋមន្ត្រីសេដ្ឋកិច្ចអាស៊ានបានស្វាគមន៍ ចំពោះគំនិតផ្តួចផ្តើមរបស់ចិន ក្នុងការបង្កើតធនាគារវិនិយោគហេដ្ឋារចនាសម្ព័ន្ធអាស៊ី ដើម្បីផ្តល់នូវការគាំទ្រហិរញ្ញវត្ថុ សម្រាប់គម្រោងហេដ្ឋារចនាសម្ព័ន្ធតំបន់ ដោយផ្តោតជាអាទិភាពទៅលើការតភ្ជាប់អាស៊ាន
- ភាគីចិនបានដាក់ជូនអាស៊ាន ពិចារណានូវគំនិតផ្តួចផ្តើម ស្តីពីផ្លូវសូត្រសមុទ្រសតវត្សទី២១ (Initiative of the 21st Century Maritime Silk Road)។ គំនិតផ្តួចផ្តើមទាំងនេះ ទោះជាមិនមានការគាំទ្រពីសមាជិកអាស៊ានមួយចំនួន ប៉ុន្តែកម្ពុជាបានសម្តែងនូវការគាំទ្រពេញទំហឹង ព្រោះមានសារៈប្រយោជន៍សម្រាប់ការកសាងហេដ្ឋារចនាសម្ព័ន្ធ និងការតភ្ជាប់របស់កម្ពុជា។

## ២.២.២ អាស៊ាន-កូរ៉េ

- ចូលរួមកិច្ចប្រជុំគណៈកម្មាធិការអនុវត្ត កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ាន-កូរ៉េ (AKFTA IC) ដើម្បីពិភាក្សាការអនុវត្ត និងចរចាបង្កើនកម្រិតនៃកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីស៊ាន-កូរ៉េ។ រដ្ឋមន្ត្រីសេដ្ឋកិច្ចអាស៊ាន-កូរ៉េ បានដាក់ទិសដៅឲ្យបញ្ចប់នូវការងារសេរីភាវូបនីយកម្មបន្ថែម និងកែលម្អ AKFTA នៅត្រឹមឆ្នាំ២០១៥ ដើម្បីផ្តល់នូវកម្លាំងជំរុញថ្មីដល់ពាណិជ្ជកម្ម និងវិនិយោគអាស៊ាន-កូរ៉េ។ ពិធីសារទី២នៃការធ្វើវិសោធនកម្មកិច្ចព្រមព្រៀងទំនិញអាស៊ាន-កូរ៉េ ត្រូវបានសភាជាតិផ្តល់សច្ចាប័ន និងដាក់ឲ្យប្រើប្រាស់ដោយព្រះរាជក្រមចុះថ្ងៃទី៩ ខែមករា ឆ្នាំ២០១៤។ នីតិវិធីប្រតិបត្តិវិញ្ញាបនបត្រប្រភពដើមទំនិញកែសម្រួលថ្មី ត្រូវបានចាប់អនុវត្តពីថ្ងៃទី០១ ខែ មករា ឆ្នាំ២០១៤
- ចូលរួមក្រុមការងារសេវាកម្មដើម្បីចរចាកញ្ចប់ទី២ នៃការសន្យាសេវាកម្មក្រោម កិច្ចព្រមព្រៀងពាណិជ្ជកម្មសេវាអាស៊ាន-កូរ៉េ។ ការសិក្សា ស្តីពីការជះឥទ្ធិពលនៃកិច្ចព្រមព្រៀងពាណិជ្ជកម្មសេវាអាស៊ាន-កូរ៉េ ត្រូវបានធ្វើបញ្ចប់។ ក្រុមការងារ ស្តីពីវិនិយោគ ត្រូវបានបង្កើតឡើងវិញ ក្នុងខែតុលា ឆ្នាំ២០១៤ និងបានចាប់ផ្តើមចរចាកែលម្អកិច្ចព្រមព្រៀងវិនិយោគអាស៊ាន-កូរ៉េ
- ប្រមុខដឹកនាំអាស៊ានបានស្វាគមន៍ចំពោះការស្នើបង្កើតក្រុមប្រឹក្សាពាណិជ្ជកម្មអាស៊ាន-កូរ៉េ នៅក្នុងឆ្នាំ២០១៤ ដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចអាស៊ាន-កូរ៉េ។ ក្រុមប្រឹក្សាពាណិជ្ជកម្មអាស៊ាន - កូរ៉េ បានបើកកិច្ចប្រជុំកំពូលរបស់ខ្លួន និងកិច្ចប្រជុំកំពូលប្រធានប្រតិបត្តិក្រុមហ៊ុនអាស៊ាន-កូរ៉េ នៅថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៤។ តាមអនុសាសន៍ដ៏ខ្ពង់ខ្ពស់របស់ **សម្តេចតេជោនាយករដ្ឋមន្ត្រី ហ៊ុន សែន** ឯកឧត្តម ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម បានចូលរួមថ្លែងសុន្ទរកថាស្តីពីការប្រមើរមើលសេដ្ឋកិច្ចពិភពលោក និងតួនាទីរបស់តំបន់អាស៊ី នៅក្នុងកិច្ចប្រជុំកំពូលប្រធានប្រតិបត្តិក្រុមហ៊ុនអាស៊ាន-កូរ៉េ នោះផងដែរ។

### ២.២.៣ អាស៊ាន-ជប៉ុន

- ចូលរួមកិច្ចប្រជុំគណៈកម្មាធិការចម្រុះ ស្តីពីភាពជាដៃគូសេដ្ឋកិច្ចទូលំទូលាយអាស៊ាន-ជប៉ុន ដោយចរចាកែលម្អជំពូកស្តីពីពាណិជ្ជកម្ម និងសេវា វិនិយោគ និងកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច។ កម្ពុជាបានចរចាជាមួយជប៉ុនស្ទើរតែបញ្ចប់នូវការផ្ទេរតារាងបញ្ជីពន្ធគយពី HS ២០០២ មក HS ២០០៧ នៅក្នុងខែកញ្ញា ឆ្នាំ២០១៤។ កម្ពុជានឹងចាប់ផ្តើមធ្វើការផ្ទេរតារាងកាត់បន្ថយពន្ធគយពី HS ២០០៧ មក HS ២០១២ នៅក្នុងឆ្នាំ២០១៥។ ការចរចាជំពូក ស្តីពីវិនិយោគក៏ស្ទើរតែត្រូវបានបញ្ចប់ផងដែរ ហើយបានដាក់ទិសដៅបញ្ចប់នៅចុងដើមឆ្នាំ២០១៥
- ចូលរួមចរចាពាណិជ្ជកម្មសេវា នៅក្រោមកិច្ចព្រមព្រៀងតំបន់ពាណិជ្ជកម្មសេរីអាស៊ាន-ជប៉ុន ដោយបានបញ្ចប់អត្ថបទជំពូកស្តីពីបម្លាស់ទីរូបវន្តបុគ្គល និងជំពូក ស្តីពីពាណិជ្ជកម្មសេវា ដោយរួមបញ្ចូលនូវឧបសម្ព័ន្ធស្តីពីសេវាហិរញ្ញវត្ថុ និងឧបសម្ព័ន្ធស្តីពីសេវាទូរគមនាគមន៍ ផងដែរ នៅក្នុងខែតុលា ឆ្នាំ២០១៤។ អាស៊ាន និងជប៉ុន បាននិងកំពុងពិភាក្សាលើពិធីសារ ដើម្បីធ្វើវិសោធនកម្មកិច្ចព្រមព្រៀង AJCEP សម្រាប់បញ្ចូលការផ្ទេរតារាងបញ្ជីពន្ធគយ ជំពូកស្តីពីពាណិជ្ជកម្មសេវា ជំពូកស្តីពីបម្លាស់ទីរូបវន្តបុគ្គល និងជំពូក ស្តីពីវិនិយោគទៅក្នុងកិច្ចព្រមព្រៀងមេ AJCEP ដើម្បីដាក់ជូនចុះហត្ថលេខានៅឯ កិច្ចប្រជុំរដ្ឋមន្ត្រីសេដ្ឋកិច្ចអាស៊ាន-ជប៉ុន ចុះហត្ថលេខានៅក្នុងខែសីហា ឆ្នាំ២០១៤
- កិច្ចប្រជុំ AJCEP លើកទី១២ នៅក្នុងខែតុលាឆ្នាំ២០១៤ បានអនុម័តជាគោលការណ៍ផ្តល់ទឹកប្រាក់ជាង ៤០ ម៉ឺនដុល្លារអាមេរិក សម្រាប់អនុវត្តគម្រោងស្នើដោយកម្ពុជាសម្រាប់សិក្ខាសាលាបណ្តុះបណ្តាល ស្តីពីឱកាសនៃការអភិវឌ្ឍជួយកាត់បន្ថយឧស្ម័នកាបូនិចដោយព្រៃឈើ ដែលនឹងត្រូវសម្របសម្រួលអនុវត្តដោយនាយកដ្ឋានអាស៊ានទីស្តីការគណៈរដ្ឋមន្ត្រី
- កិច្ចប្រជុំរដ្ឋមន្ត្រីសេដ្ឋកិច្ចអាស៊ាន-ជប៉ុនលើកទី២០ នាថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១៤ បានអនុម័តលើការកែលម្អផែនទីវិថី ស្តីពីសហប្រតិបត្តិការសេដ្ឋកិច្ចយុទ្ធសាស្ត្រ ១០ឆ្នាំ អាស៊ាន-ជប៉ុន និងលើកទឹកចិត្តឲ្យប្រទេសសមាជិកអាស៊ានដាក់សំណើគម្រោងដើម្បីសុំមូលនិធិ និងអនុវត្ត។

### ២.២.៤ អាស៊ាន-ឥណ្ឌា

- ចូលរួមកិច្ចប្រជុំគណៈកម្មាធិការចរចាពាណិជ្ជកម្ម អាស៊ាន-ឥណ្ឌា (AITNC) ដើម្បីចរចាបញ្ចប់កិច្ចព្រមព្រៀងពាណិជ្ជកម្មសេវា និងកិច្ចព្រមព្រៀងវិនិយោគអាស៊ាន-ឥណ្ឌា។ ជាលទ្ធផល រដ្ឋមន្ត្រីសេដ្ឋកិច្ចអាស៊ានបានចុះហត្ថលេខាលើកិច្ចព្រមព្រៀង ស្តីពីពាណិជ្ជកម្មសេវាអាស៊ាន-ឥណ្ឌា និងកិច្ចព្រមព្រៀងវិនិយោគអាស៊ាន-ឥណ្ឌា នៅឯកិច្ចប្រជុំរដ្ឋមន្ត្រីសេដ្ឋកិច្ចលើកទី៤៦ នៅថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១៤ នៅក្រុងណៃពិដោ ប្រទេសមីយ៉ាន់ម៉ា ហើយគ្រោងនឹងចាប់ផ្តើមអនុវត្តនៅក្នុងខែកក្កដាឆ្នាំ២០១៤ ដែលធ្វើឲ្យតំបន់ពាណិជ្ជកម្មសេរីអាស៊ាន-ឥណ្ឌា មានរូបរាងពេញលេញនៅក្នុងឆ្នាំ២០១៥
- រដ្ឋមន្ត្រីបានឯកភាពឲ្យគណៈកម្មាធិការចរចាពាណិជ្ជកម្មអាស៊ាន-ឥណ្ឌារៀបចំការងារ ដើម្បីចាប់ផ្តើមចរចាបង្កើនកម្រិត កិច្ចព្រមព្រៀងតំបន់ពាណិជ្ជកម្មសេរីអាស៊ាន-ឥណ្ឌា ជាពិសេសកិច្ចព្រមព្រៀងពាណិជ្ជកម្មទំនិញ ដើម្បីបង្កើនពាណិជ្ជកម្ម និងវិនិយោគនៃតំបន់ទាំងពីរ

• រដ្ឋមន្ត្រីសេដ្ឋកិច្ចអាស៊ានបានឯកភាព លើសំណើឥណ្ឌាសុំបង្កើតមជ្ឈមណ្ឌលពាណិជ្ជកម្ម និងវិនិយោគអាស៊ាន-ឥណ្ឌា ប្រសិនបើភាគីឥណ្ឌាផ្ដល់មូលនិធិទាំងស្រុង និងជាអចិន្ត្រៃយ៍ដល់មជ្ឈមណ្ឌលនេះ ហើយការចូលរួមរបស់អាស៊ានក្នុងមជ្ឈមណ្ឌលនេះតាមការស្ម័គ្រចិត្ត។

## ២.២.៥ អាស៊ាន-អូស្ត្រាលី-ណូវែ៉លហ្សេឡង់

• ចូលរួមកិច្ចប្រជុំគណៈកម្មាធិការចម្រុះ ស្តីពីកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ាន-អូស្ត្រាលី និងវ៉ែលហ្សេឡង់ (AANZFTA JC) ដើម្បីពិភាក្សាកែលម្អកិច្ចព្រមព្រៀង AANZFTA។ ជាលទ្ធផលរដ្ឋមន្ត្រីសេដ្ឋកិច្ចអាស៊ានបានចុះហត្ថលេខាលើពិធីសារទីមួយដើម្បីធ្វើវិសោធនកម្មកិច្ចព្រមព្រៀងបង្កើតពាណិជ្ជកម្មសេរីអាស៊ាន - អូស្ត្រាលី - ណូវ៉ែលហ្សេឡង់នៅឯកិច្ចប្រជុំរដ្ឋមន្ត្រីសេដ្ឋកិច្ចលើកទី៤៦ នៅថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១៤ នៅក្រុងណៃពិដោ ប្រទេសមីយ៉ាន់ម៉ា
• រដ្ឋមន្ត្រីសេដ្ឋកិច្ចអាស៊ាន - អូស្ត្រាលី - ណូវ៉ែលហ្សេឡង់ បានស្វាគមន៍ ចំពោះការអនុម័តលើក្របខ័ណ្ឌបញ្ជាក់ជំនាញអាស៊ាន នៅឯកិច្ចប្រជុំរដ្ឋមន្ត្រីសេដ្ឋកិច្ចអាស៊ានលើកទី ៤៦។ ក្របខ័ណ្ឌបញ្ជាក់ជំនាញអាស៊ាននេះ ត្រូវបានរៀបចំឡើងដោយក្រុមការងារ ស្តីពីក្របខ័ណ្ឌបញ្ជាក់ជំនាញអាស៊ាន និងឧបត្ថម្ភដោយអូស្ត្រាលី និងណូវ៉ែលហ្សេឡង់ នឹងជួយធ្វើឲ្យមានការប្រៀបធៀបនូវជំនាញទូទាំងប្រទេសជាសមាជិកអាស៊ាន ដែលជាជំហានមួយទៀតនៅក្នុងការជួយជំរុញគោលដៅលំហូរដោយសេរីពលកម្មជំនាញនៃសហគមន៍សេដ្ឋកិច្ចអាស៊ាន។

## ២.២.៦ អាស៊ាន-ហុងកុង

ចូលរួមកិច្ចប្រជុំចរចា កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ានហុងកុងលើកទី១ នៅក្នុងខែកក្កដា ឆ្នាំ២០១៤។ ភាគីទាំងពីរបានឯកភាពលើ កម្មវិធីបណ្ដោះអាសន្នកំណត់ការបរិច្ឆេទបញ្ចប់ការចរចាកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ាន-ហុងកុងនៅឆ្នាំ២០១៦ និងបានបង្កើតក្រុមការងារចំនួន ៧ (ច្បាប់ បញ្ហាស្ថាប័ន វិធានប្រភពដើមទំនិញ នីតិវិធីគយ កិច្ចសម្រួលពាណិជ្ជកម្ម វិធានអនាម័យ និងភូតគាមអនាម័យ ស្តង់ដា បញ្ញត្តិបច្ចេកទេស នីតិវិធីវាយតម្លៃអនុលោមភាព ពាណិជ្ជកម្មទំនិញ និងវិនិយោគ)។ ក្រុមការងារ៣គឺ ពាណិជ្ជកម្ម សេវាវិធានប្រភពដើមទំនិញ និងវិនិយោគបានចាប់ផ្តើមចរចា នៅក្នុងកិច្ចប្រជុំគណៈកម្មាធិការចរចាពាណិជ្ជកម្មសេរី អាស៊ាន-ហុងកុង ក្នុងខែវិច្ឆិកា ឆ្នាំ២០១៤ នៅទីក្រុងបាងកក ប្រទេសថៃ។

## ២.២.៧ ភាពជាដៃគូសេដ្ឋកិច្ចទូលំទូលាយតំបន់ ( RCEP )

ចូលរួមក្នុងកិច្ចប្រជុំចរចា កិច្ចព្រមព្រៀងពាណិជ្ជកម្មសេវា និងចូលរួមកិច្ចប្រជុំចរចាផ្សេងៗទៀតនៃភាពជាដៃគូសេដ្ឋកិច្ចទូលំទូលាយតំបន់ (RCEP)។ កិច្ចប្រជុំរដ្ឋមន្ត្រី RCEP លើកទី២ បានកត់សម្គាល់ និងពិភាក្សាលើលទ្ធផលនៃការចរចា ៥លើក ស្តីពីភាពជាដៃគូសេដ្ឋកិច្ចទូលំទូលាយតំបន់ (RCEP) និងបានជំរុញឲ្យមន្ត្រីខិតខំផ្តល់នូវភាពទន់ភ្លន់ទៅវិញទៅមកឲ្យបានជាអតិបរមាពិសេស លើនីតិវិធីនៃការសន្យាលើផ្នែកទំនិញ សេវា និងវិនិយោគ ដើម្បីបញ្ចប់ការចរចា RCEP នៅចុងឆ្នាំ២០១៥ តាមទិសដៅ។ កិច្ចប្រជុំគណៈកម្មាធិការចរចា (TNC ) ស្តីពី RCEP បានបើកកិច្ចប្រជុំលើកទី៦ នៅថ្ងៃទី១-៥ ខែធ្នូ ឆ្នាំ២០១៤ និងបានបន្តការចរចាជាពិសេស លើនីតិវិធីនៃការផ្តល់ការសន្យាផ្នែកទំនិញ និងនីតិវិធីនៃការសន្យាផ្នែកសេវាកម្ម និងចរចាលើបញ្ហាផ្សេងៗទៀតដូចជា៖ វិធាន

ប្រភពដើមទំនិញ របាំងមិនមែនពន្ធគយ និងរបាំងបច្ចេកទេសលើពាណិជ្ជកម្ម អនាម័យនិងភូតគាម អនាម័យ វិនិយោគ បញ្ញាច្បាប់ និងស្ថាប័ន កម្មសិទ្ធិបញ្ញា គោលនយោបាយប្រកួតប្រជែង ពាណិជ្ជកម្មតាមអេឡិចត្រូនិច លទ្ធកម្មសាធារណៈ ពាណិជ្ជកម្មពាក់ព័ន្ធបរិស្ថាននិងពលកម្ម សហប្រតិបត្តិការសេដ្ឋកិច្ច។ល។ កិច្ចប្រជុំ RCEP TNC លើកទី៧ នឹងធ្វើនៅថ្ងៃទី៩-១៣ ខែកុម្ភៈ ឆ្នាំ២០១៥ នៅទីក្រុងបាងកក ប្រទេសថៃ។

## ២.២.៨ អាស៊ាន-រុស្ស៊ី

ចូលរួមកិច្ចប្រជុំ ស្តីពីកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចអាស៊ាន-រុស្ស៊ី ដោយសហការជាមួយសមភាគីអាស៊ាន ស្វែងរកយន្តការសម្រាប់ការអនុវត្ត កម្មវិធីការងារនៅក្នុងផែនទីបង្ហាញផ្លូវ ដើម្បីធ្វើកិច្ចសហប្រតិបត្តិការវិនិយោគ និងពាណិជ្ជកម្មអាស៊ាន-រុស្ស៊ី។ កិច្ចប្រជុំរដ្ឋមន្ត្រីសេដ្ឋកិច្ចអាស៊ាន-រុស្ស៊ី នៅក្នុងខែសីហា ឆ្នាំ២០១៤ បានឯកភាពឲ្យឧត្តមមន្ត្រីអាស៊ាន-រុស្ស៊ី ធ្វើជាយន្តការពិគ្រោះយោបល់ ដើម្បីសម្របសម្រួល និងតាមដានការអនុវត្តផែនទីវិថីសហប្រតិបត្តិការ វិនិយោគ និងពាណិជ្ជកម្មអាស៊ាន។

## ២.២.៩ អាស៊ានបូក៣

- ចូលរួមកិច្ចប្រជុំពិភាក្សា អំពីសហប្រតិបត្តិការនៅក្នុងក្របខ័ណ្ឌអាស៊ានបូក ៣ ដើម្បីពិភាក្សាបញ្ហាមួយចំនួន ដូចជាការពិនិត្យឡើងវិញ និងការវាយតម្លៃរបស់ក្រុមចក្ខុវិស័យ ស្តីពីអាស៊ីបូព៌ាពាក់ព័ន្ធនឹងសេដ្ឋកិច្ចជាដើម។ កិច្ចប្រជុំ AEM បូក៣ ក្នុងខែសីហា ឆ្នាំ២០១៤ បានយល់ស្របថាការសម្របសម្រួលឲ្យកាន់តែជិតស្និទ្ធ និងពង្រឹងកម្លាំងឲ្យបានកាន់តែខ្លាំងក្លារវាងប្រទេសអាស៊ានបូក៣ នឹងជំរុញឲ្យមានការអភិវឌ្ឍន៍សេដ្ឋកិច្ចក្នុងតំបន់។ រដ្ឋមន្ត្រីបានស្នើឲ្យក្រុមចក្ខុវិស័យរាយការណ៍នូវលទ្ធផលចុងក្រោយនៃការពិនិត្យឡើងវិញ និងការវាយតម្លៃនេះ ជូនប្រមុខដឹកនាំនៅឯកិច្ចប្រជុំកំពូលអាស៊ានបូក៣ ក្នុងខែវិច្ឆិកា ឆ្នាំ២០១៥
- រដ្ឋមន្ត្រីបានស្វាគមន៍ ចំពោះការកើនឡើងការប្រើប្រាស់សេវាមជ្ឈមណ្ឌលអាស៊ាន-ចិន, អាស៊ាន-កូរ៉េ, អាស៊ាន-ជប៉ុន ដោយអាជីវករក្នុងស្រុក ដើម្បីទទួលបានព័ត៌មាន ស្តីពីអាជីវកម្ម និងស្វែងរកឱកាសអាជីវកម្មក្នុងអាស៊ាន។ រដ្ឋមន្ត្រីបានកត់សម្គាល់លើសកម្មភាពកសាងសមត្ថភាពសម្រាប់ SME ហើយបានជំរុញឲ្យមជ្ឈមណ្ឌលទាំង៣ បង្កើតចំណងទាក់ទងជាមួយអង្គការពាណិជ្ជកម្មពាក់ព័ន្ធក្នុងតំបន់ដូចជា៖ ក្រុមប្រឹក្សាពាណិជ្ជកម្មអាស៊ីបូព៌ា និងក្រុមប្រឹក្សាពិគ្រោះយោបល់ពាណិជ្ជកម្មអាស៊ានជាដើម។

## ២.២.១០ អាស៊ាន-អាមេរិក

តាមដាន និងចូលរួមកិច្ចប្រជុំ ស្តីពីសហប្រតិបត្តិការអាស៊ាន-អាមេរិក ដែលបានអនុវត្តក្រោមក្របខ័ណ្ឌអាស៊ាន-សហរដ្ឋអាមេរិក និងគំនិតផ្តួចផ្តើម ស្តីពីកិច្ចសម្រួលពាណិជ្ជកម្មរួមមាន៖ ១-កម្មវិធីច្រកចេញ-ចូលតែមួយអាស៊ាន ២-ការអភិវឌ្ឍន៍សហគ្រាសខ្នាតតូច និងមធ្យម និង ៣-កិច្ចសហប្រតិបត្តិការលើវិស័យស្តង់ដារ និងភាពស្របគ្នា ក្រោមគម្រោងជំនួយអាមេរិកហៅថាការតភ្ជាប់តាមរយៈពាណិជ្ជកម្ម និងវិនិយោគ។ កិច្ចប្រជុំរដ្ឋមន្ត្រីសេដ្ឋកិច្ចអាស៊ាន២០១៤ នៅក្នុងខែ

សីហា បានកត់សម្គាល់លើសកម្មភាពដែលបានអនុវត្តនៅក្រោម TIFA និង E3 ក្នុងឆ្នាំ២០១៤ និងបានសម្តែងអំណរគុណដល់អាមេរិកដែលបន្តជួយនៅក្នុងវិស័យសម្រួលពាណិជ្ជកម្ម។

### ២.២.១១ អាស៊ាន-កាណាដា

- សម្របសម្រួលការងារ និងចូលរួមកិច្ចប្រជុំ ស្តីពីកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចអាស៊ាន-កាណាដា។ កិច្ចប្រជុំរដ្ឋមន្ត្រីសេដ្ឋកិច្ចអាស៊ាន-កាណាដា នៅក្នុងខែសីហា ឆ្នាំ២០១៤ បានកត់សម្គាល់នូវភាពជឿនលឿនដ៏ប្រសើនូវគោលដៅការងារឆ្នាំ២០១២-២០១៥ ដើម្បីអនុវត្តសេចក្តីថ្លែងការណ៍រួមអាស៊ាន-កាណាដា ស្តីពីពាណិជ្ជកម្ម និងវិនិយោគ។ រដ្ឋមន្ត្រីបានប្រគល់ការងារឲ្យឧត្តមមន្ត្រីចាប់ផ្តើមរៀបចំផែនការការងារអាស៊ាន-កាណាដាសម្រាប់ឆ្នាំ២០១៦-២០២០។ រដ្ឋមន្ត្រីបានជួបពិគ្រោះយោបល់ជាមួយ ក្រុមប្រឹក្សាពាណិជ្ជកម្មអាស៊ាន-កាណាដា និងបានថ្លែងសរសើរចំពោះការដើរតួយ៉ាងសកម្មរបស់ក្រុមប្រឹក្សានេះ នៅក្នុងការជំរុញពាណិជ្ជកម្ម និងវិនិយោគរវាងអាស៊ាន និងកាណាដា
- រដ្ឋមន្ត្រីបានថ្លែងអំណរគុណកាណាដា ចំពោះការរៀបចំទស្សនកិច្ចផ្សព្វផ្សាយរដ្ឋមន្ត្រីសេដ្ឋកិច្ចអាស៊ាននៅប្រទេសកាណាដា ពីថ្ងៃទី១-៤ ខែមិថុនា ឆ្នាំ២០១៤ នៅទីក្រុង Vancouver និង Toronto ដែលជាឱកាសដ៏ល្អសម្រាប់រដ្ឋមន្ត្រី និងឧត្តមមន្ត្រី ផ្សារភ្ជាប់នូវទំនាក់ទំនងជាមួយដៃគូ និងសហគមន៍អាជីវករ។ ទស្សនកិច្ចផ្សព្វផ្សាយនេះ ទទួលបានលទ្ធផលល្អ ហើយរដ្ឋមន្ត្រីបានឯកភាពតាមដាននូវសកម្មភាព មួយចំនួន សំដៅបង្កើនឱកាសអាជីវកម្ម និងកិច្ចសហប្រតិបត្តិការទាំងក្នុងអាស៊ាន និងកាណាដា។ រដ្ឋមន្ត្រីបានស្វាគមន៍ការប្រកាសរបស់រដ្ឋាភិបាលកាណាដាតែងតាំងអគ្គរាជទូតប្រចាំនៅអាស៊ាន និងបង្កើតការិយាល័យតំណាងនៅប្រទេសកម្ពុជា និងឡាវ ដែលនឹងជួយបង្កើននូវទំនាក់ទំនងសេដ្ឋកិច្ចរវាងអាស៊ាន និងកាណាដាបន្ថែមទៀត។

### ២.២.១២ សហប្រតិបត្តិការសេដ្ឋកិច្ចអាស៊ីបូព៌ា

សម្របសម្រួល និងចូលរួមកិច្ចប្រជុំឧត្តមមន្ត្រី និងរដ្ឋមន្ត្រីសេដ្ឋកិច្ចប្រទេសអាស៊ីបូព៌ា។ រដ្ឋមន្ត្រីសេដ្ឋកិច្ចអាស៊ីបូព៌ាកាលពីថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៤ បានផ្លាស់ប្តូរយោបល់អំពីការអភិវឌ្ឍន៍សេដ្ឋកិច្ចតំបន់ និងសកលលោក រួមមាន៖ ការតភ្ជាប់វិស័យសហប្រតិបត្តិការអាទិភាពសម្រាប់កសាង AEC និងកិច្ចសហការជាមួយ APEC។ រដ្ឋមន្ត្រីបានបញ្ជាក់ពីភាពចាំបាច់រក្សាការកិច្ចប្រឹងប្រែងធ្វើសមាហរណកម្មសេដ្ឋកិច្ចរបស់ខ្លួន និងប្តេជ្ញាជំរុញសមាហរណកម្មសេដ្ឋកិច្ចទូលំទូលាយនៅក្នុងតំបន់អាស៊ីបូព៌ា និងអាស៊ីប៉ាស៊ីហ្វិក។ រដ្ឋមន្ត្រីបានកត់សម្គាល់ថា ទីផ្សារបើកចំហរសម្រាប់ពាណិជ្ជកម្មនិងការវិនិយោគ នយោបាយ កម្មសិទ្ធិបញ្ញារឹងមាំ ការសម្រួលអាជីវកម្មឆ្លងដែន ការយល់ដឹងល្អពីនយោបាយឧស្សាហកម្ម ច្រកចូលទៅក្នុងសង្វាក់តម្លៃតំបន់ និងសាកលលោក រួមជាមួយនឹងហេដ្ឋារចនាសម្ព័ន្ធដែលបានកែលម្អ នឹងមានតួនាទីយ៉ាងសំខាន់ក្នុងការបង្កើត និងជោគជ័យការតភ្ជាប់របស់អាជីវកម្ម។ ការសិក្សា អំពីចង្កោមឧស្សាហកម្មរបស់វិទ្យាស្ថានស្រាវ ERIA អាចជាមូលដ្ឋានមួយល្អសម្រាប់ ការការអនុវត្តន៍ឲ្យបានល្អប្រសើរ និងយល់ដឹងអំពីការអភិវឌ្ឍន៍សេដ្ឋកិច្ចតំបន់ជាមួយ និងកិច្ចសហប្រតិបត្តិការជាមួយគំនិតផ្តួចផ្តើមនានា។ រដ្ឋមន្ត្រីបានស្វាគមន៍ចំពោះរបាយការណ៍បច្ចុប្បន្នភាពនានារបស់ ERIA រួមមាន៖ ការសិក្សា ស្តីពីនយោបាយចង្កោមឧស្សាហកម្ម ភាពស៊ីសង្វាក់គ្នាបទបញ្ញត្តិ ថាមពលធ្យូងថ្មប្រើបច្ចេកវិទ្យាស្អាត ការអភិវឌ្ឍន៍ SME

ការគ្រប់គ្រងមហន្តរាយ ការកែសម្រួលផែនការអភិវឌ្ឍអាស៊ី ទូលំទូលាយ ការបង្កើតគោលការណ៍ណែនាំពីភាពជាដៃគូរវាងវិស័យសាធារណៈ និងវិស័យឯកជន សំណើរសម្រាប់សហគមន៍ក្រោយឆ្នាំ២០១៥ និងការជួយគាំទ្រគំនិតផ្តួចផ្តើមសេដ្ឋកិច្ចតំបន់។

## ២.២.១៣ អាស៊ាន-សហភាពអឺរ៉ុប

សម្របសម្រួលការងារ និងចូលរួមកិច្ចប្រជុំអាស៊ាន-សហភាពអឺរ៉ុប។ ការចរចាពាណិជ្ជកម្មសេរីអាស៊ាន-សហភាពអឺរ៉ុបត្រូវបានផ្អាក។ សហភាពអឺរ៉ុបបានកំពុងចរចាពាណិជ្ជកម្មពាណិជ្ជកម្មសេរីទ្វេភាគីជាមួយប្រទេសអាស៊ានមួយចំនួន។ សហភាពអឺរ៉ុបបានបញ្ចប់ការចរចា ជាមួយសឹង្ហបូរី និងកំពុងចរចាជាមួយប្រទេសវៀតណាម ប្រទេសម៉ាឡេស៊ី និងប្រទេសថៃ និងកំពុងពិភាក្សាជាមួយប្រទេសឥណ្ឌូនេស៊ី ហ្វីលីពីន។ សហភាពអឺរ៉ុប មានបំណងបន្តចរចា ASEAN-EU FTA បន្ទាប់ពីសហគមន៍សេដ្ឋកិច្ចអាស៊ានចូលជាធរមាន។ ការអនុវត្តកម្មវិធីការងារអាស៊ាន-សហភាពអឺរ៉ុបឆ្នាំ២០១៣-២០១៤ មានភាពជឿនលឿន។ ការងារកសាងសមត្ថភាពសម្រាប់មន្ត្រីចរចា FTA ត្រូវបានបញ្ចប់ ដោយមានអ្នកចូលរួម ពីបណ្តាប្រទេសអាស៊ានចំនួន ៣៥0នាក់។ អាស៊ានបាន និងកំពុងចរចាស្នើឲ្យបណ្តាប្រទេសសមាជិកសហភាពអឺរ៉ុបបន្តផ្តល់នូវ GSP ដើម្បីឲ្យអាស៊ានអាចបូកបន្តធាតុផ្សំតំបន់នៅទូទាំងអាស៊ានសម្រាប់ផលិតផល ដើម្បីទទួលបាននូវប្រព្រឹត្តកម្មអនុគ្រោះពន្ធគយពីសហភាពអឺរ៉ុប ពីប្រទេសសមាជិកសហភាពអឺរ៉ុប។

## ២.២.១៤ ការងារអនុតំបន់

- បំពេញការងារប្រកបដោយជោគជ័យ ក្នុងនាមជាលេខាធិការដ្ឋានឧត្តមមន្ត្រី និងរដ្ឋមន្ត្រីមហាអនុតំបន់មេគង្គ (GMS) មេគង្គ-ជប៉ុន, CLMV, AMBDC, ACMES, CLT និងលេខាធិការដ្ឋានជាតិតំបន់ត្រីកោណអភិវឌ្ឍន៍កម្ពុជា-វៀតណាម-ឡាវ (CLV) លើកទី៨ ប្រកបដោយជោគជ័យ
- សម្របសម្រួលការងារ និងរៀបចំឯកសារជូន និងអមដំណើរ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ចូលរួមកិច្ចប្រជុំកំពូល GMS កិច្ចប្រជុំកំពូលមេគង្គ ជប៉ុន កិច្ចប្រជុំកំពូល-CLMV និងកិច្ចប្រជុំកំពូល CLV
- សម្របសម្រួលការងារ និងធ្វើជាម្ចាស់ផ្ទះប្រកបដោយជោគជ័យ នូវកិច្ចប្រជុំអនុគណៈកម្មការ កិច្ចប្រជុំឧត្តមរដ្ឋមន្ត្រី និងគណៈកម្មាធិការសម្របសម្រួលចម្រុះនៃតំបន់ត្រីកោណអភិវឌ្ឍន៍ (CLV) លើកទី៩ នៅទីក្រុងសៀមរាប ពីថ្ងៃទី៩-១២ ខែសីហា ឆ្នាំ២០១៤
- ចូលរួមកិច្ចប្រជុំឧត្តមមន្ត្រី កម្ពុជា ឡាវ មីយ៉ាន់ម៉ា និងវៀតណាម (CLMV) ដើម្បីពិភាក្សាធ្វើផែនការសកម្មភាពឆ្នាំ២០១៥ នៅក្រោមសហប្រតិបត្តិការសេដ្ឋកិច្ច CLMV ដែលត្រូវបានអនុម័តដោយរដ្ឋមន្ត្រីសេដ្ឋកិច្ច CLMV នៅថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១៤។ រដ្ឋមន្ត្រីបានឯកភាពស្នើកម្ពុជាទទួលវេនជាប្រធានឧត្តមមន្ត្រី និងរដ្ឋមន្ត្រីសេដ្ឋកិច្ច CLMV ឆ្នាំ២០១៥
- សម្របសម្រួល និងចូលរួមកិច្ចប្រជុំរដ្ឋមន្ត្រីសេដ្ឋកិច្ចមេគង្គ-ជប៉ុនលើកទី៦ រដ្ឋមន្ត្រីសេដ្ឋកិច្ចមេគង្គ-ជប៉ុន នៅថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១៤។ រដ្ឋមន្ត្រីសេដ្ឋកិច្ចបានអនុម័តផែនទីវិថីកែសម្រួលស្តីពីការអភិវឌ្ឍន៍មេគង្គ ហើយបានឯកភាពអភិវឌ្ឍរួមគ្នា នូវចក្ខុវិស័យអភិវឌ្ឍន៍ឧស្សាហកម្មមេគង្គ និងស្នើឲ្យមានការពិគ្រោះយោបល់ជាមួយ ក្រសួងស្ថាប័នពាក់ព័ន្ធវិស័យឧស្សាហកម្ម និងគ្រឹះស្ថានសិក្សានៅតំបន់មេគង្គ និងជប៉ុន

- ចូលរួមកិច្ចប្រជុំសហប្រតិបត្តិការសេដ្ឋកិច្ចអាស៊ាន និងអាងទន្លេមេគង្គ (AMBDC)។ កិច្ចប្រជុំរដ្ឋមន្ត្រី (AMBDC) កាលពីខែសីហា ឆ្នាំ ២០១៤ បានឯកភាពឲ្យមានកិច្ចសហការរវាងប្រទេសអាស៊ាន និងប្រទេសក្នុងអាងទន្លេមេគង្គ និងដៃគូអភិវឌ្ឍន៍នៅក្នុងការអនុវត្តគម្រោងនៅក្រោម AMBDC។

## ២.២.១៥ ការងារទ្វេភាគី

- បំពេញការងារប្រកបដោយជោគជ័យ ក្នុងនាមជាលេខាធិការដ្ឋានឧត្តមមន្ត្រី និងរដ្ឋមន្ត្រីទ្វេភាគីជាមួយបណ្តាប្រទេសនៅក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិក
- ចូលរួមកិច្ចប្រជុំទ្វេភាគី ដើម្បីពិភាក្សាធ្វើកិច្ចព្រមព្រៀងថ្មី ស្តីពីពាណិជ្ជកម្មឆ្លងកាត់ព្រំដែនទ្វេភាគីរវាងកម្ពុជានិងវៀតណាម
- ចូលរួមអមដំណើរទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម បំពេញទស្សនកិច្ចផ្លូវការនៅទីក្រុងប៉េកាំង និងជួបពិភាក្សាការងារពាណិជ្ជកម្មជាមួយឯកឧត្តមរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម និងឯកឧត្តមរដ្ឋមន្ត្រីទទួលបន្ទុកអាជ្ញាធរត្រួតពិនិត្យ និងចត្តាឡីស័កនៃសាធារណរដ្ឋប្រជាមានិតចិន ដើម្បីបើកច្រកទីផ្សារសម្រាប់ផលិតផលកម្ពុជា ជាពិសេសផលិតផលកសិកម្ម។ ហើយបានចូលរួមធ្វើជាសាក្សីក្នុងការចុះហត្ថលេខាលើអនុស្សរណៈ ស្តីពីការទិញអង្ករកម្ពុជាចំនួន ១០ម៉ឺនតោន រវាងក្រុមហ៊ុនហ្គ្រីនត្រេដ និងក្រុមហ៊ុនចិន
- ចូលរួមជាមួយឯកឧត្តមទេសរដ្ឋមន្ត្រី ជួបពិភាក្សាការងារជាមួយ គណៈប្រតិភូក្រុមប្រឹក្សាពាណិជ្ជកម្មអាមេរិក ដឹកនាំដោយលោក Alexander Feldman ប្រធាន និងនាយកប្រតិបត្តិ នៃក្រុមប្រឹក្សាពាណិជ្ជកម្មអាស៊ាន-អាមេរិក និងចូលរួមដោយតំណាងក្រុមហ៊ុន ដូចជា Google, Microsoft, GM, City Bank, syngenta, ebay inc. និង UPS ជាដើម
- ជួបពិភាក្សាជាមួយឯកឧត្តម Alexey V.Ulyukaev រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍សេដ្ឋកិច្ចសហព័ន្ធរុស្ស៊ី ដោយស្នើឲ្យប្រទេសរុស្ស៊ីជួយនាំចូលផលិតផលតាមរយៈភាពអនុគ្រោះមិនជាប់ពន្ធគយ និងមិនជាប់កូតាលើទំនិញ ៣.០០០មុខ ដែលរុស្ស៊ីបានផ្តល់ឲ្យប្រទេសកម្ពុជា នៅពេលដែលរុស្ស៊ីចូលជាសមាជិកអង្គការ WTO។ សមភាគីរុស្ស៊ីបានស្នើឲ្យភាគីកម្ពុជា ធ្វើទស្សនកិច្ចនៅរុស្ស៊ីដើម្បីចុះអនុស្សរណៈយោគយល់គ្នាផងដែរ។

## ២.២.១៦ ការងារសមាហរណកម្មសេដ្ឋកិច្ចអាស៊ាន(AEC)

- បំពេញការងារជាលេខាធិការដ្ឋានឧត្តមមន្ត្រីសេដ្ឋកិច្ចអាស៊ាន លេខាធិការដ្ឋានរដ្ឋមន្ត្រីសេដ្ឋកិច្ចអាស៊ាន និងលេខាធិការដ្ឋានជាតិសហគមន៍សេដ្ឋកិច្ចអាស៊ាន ប្រកបដោយជោគជ័យ
- ចូលរួមក្នុងកិច្ចប្រជុំឧត្តមមន្ត្រីសេដ្ឋកិច្ចអាស៊ាន កិច្ចប្រជុំរួមរវាងឧត្តមមន្ត្រីនយោបាយ-សន្តិសុខអាស៊ាន កិច្ចប្រជុំឧត្តមមន្ត្រីសេដ្ឋកិច្ចអាស៊ាន កិច្ចប្រជុំឧត្តមមន្ត្រីសង្គម-វប្បធម៌អាស៊ាន និងកិច្ចប្រជុំគណៈកម្មាធិការសហគមន៍ទាំង៣ នៃសហគមន៍អាស៊ាន
- រៀបចំឯកសារ និងចូលរួមកិច្ចប្រជុំចង្អៀតរដ្ឋមន្ត្រីសេដ្ឋកិច្ចអាស៊ានលើកទី២០ ពីថ្ងៃទី២៦-២៧ ខែកុម្ភៈ ឆ្នាំ២០១៤ នៅសិង្ហបុរី, ចូលរួមកិច្ចប្រជុំរដ្ឋមន្ត្រីសេដ្ឋកិច្ចអាស៊ានលើកទី ៤៦ និងកិច្ចប្រជុំពាក់ព័ន្ធ និងកិច្ចប្រជុំ AECC លើកទី១២ នៅថ្ងៃទី២៥-២៨ ខែសីហា ឆ្នាំ២០១៤ នៅរដ្ឋធានីណៃពិដោ ប្រទេសមីយ៉ាន់ម៉ា

- រដ្ឋមន្ត្រីសេដ្ឋកិច្ចអាស៊ានកម្ពុជា បានចុះហត្ថលេខាលើ កិច្ចព្រមព្រាងអាស៊ាន ស្តីពីមគ្គុទេសន៍ឧបករណ៍បរិក្ខាពេទ្យ នៅក្នុងកិច្ចប្រជុំកំពូលអាស៊ានលើកទី ២៥ កាលពីថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០១៤ នៅក្រុងណៃពិដោ ប្រទេសមីយ៉ាន់ម៉ា
- រៀបចំឯកសារជំនួយស្មារតីសម្រាប់ **សម្តេចតេជោនាយករដ្ឋមន្ត្រី** ចូលរួមកិច្ចប្រជុំកំពូលអាស៊ានលើកទី២៤ នៅថ្ងៃទី១០-១១ ខែឧសភា ឆ្នាំ២០១៤ និងកិច្ចប្រជុំកំពូលអាស៊ានលើកទី២៥ និងកិច្ចប្រជុំកំពូលពាក់ព័ន្ធពីថ្ងៃទី១២-១៣ នៅទីក្រុងណៃពិដោ ប្រទេសមីយ៉ាន់ម៉ា និងចូលរួមកិច្ចប្រជុំកំពូលរំលឹកខួបលើកទី២៥ នៃទំនាក់ទំនងអាស៊ាន-សាធារណរដ្ឋកូរ៉េ និងកិច្ចប្រជុំកំពូលពាក់ព័ន្ធពីថ្ងៃទី១០-១២ ខែធ្នូ ឆ្នាំ២០១៤ នៅទីក្រុងប៊ូសាន ប្រទេសកូរ៉េ។

## ២.២.១៧ សហគមន៍សេដ្ឋកិច្ចអាស៊ាន

- ចូលរួមអនុវត្តវិធានការនានា ក្រោមផែនការលម្អិតសហគមន៍សេដ្ឋកិច្ចអាស៊ាន (AEC)។ យោងតាមការវាយតម្លៃរបស់លេខាធិការដ្ឋានអាស៊ាន បានបង្ហាញថា អាស៊ាន អនុវត្តបាន ៨២,១% នៃវិធានការសំខាន់ៗ ចំនួន ២២៩ ដែលបានដាក់ចុះសម្រាប់ធ្វើបញ្ចប់នៅក្នុងឆ្នាំ២០១៣។ កម្ពុជាអនុវត្តសម្រេចបាន ៨៦% នៃវិធានការដែលបានដាក់ចុះនៅក្នុងឆ្នាំ២០១៣។ ជាមួយនេះ គិតត្រឹមខែសីហា ឆ្នាំ២០១៤ វិធានការសំខាន់ៗ ៤២ទៀត ដែលបានដាក់ចុះសម្រាប់ធ្វើបញ្ចប់នៅក្នុងឆ្នាំ ២០១៤ ត្រូវបានអនុវត្ត។ ការសម្រេចបាននេះ គឺស្របទៅនឹងរបៀបវារៈភ្នំពេញឆ្នាំ ២០១២។ កិច្ចប្រជុំរដ្ឋមន្ត្រីសេដ្ឋកិច្ចអាស៊ានលើកទី៤៦ នាខែសីហា ឆ្នាំ២០១៤ បានឯកភាពថា ការងារអាទិភាពនៅក្នុងឆ្នាំ២០១៥ ដែលជាឆ្នាំចុងក្រោយ គឺត្រូវអនុវត្តឲ្យបានលឿននូវវិធានការដែលអាចសម្រេចបាន ជាពិសេសវិធានការនានា ដែលជះឥទ្ធិពលខ្ពស់លើលទ្ធផលសមាហរណកម្មសេដ្ឋកិច្ចអាស៊ាន និងត្រូវធ្វើបញ្ចប់នូវរបៀបវារៈសម្រាប់ឆ្នាំ ២០១៥-២០២៦ ដោយដាក់បញ្ចូលវិធានការដែលមិនអាចបញ្ចប់នៅចុងឆ្នាំ២០១៥ ទៅក្នុងរបៀបវារៈនោះផងដែរ។ រដ្ឋមន្ត្រីបានអះអាងឡើងវិញនូវការសន្យាគាំទ្រដល់កិច្ចខិតខំអនុវត្តផែនការលម្អិត AEC និងធ្វើទំនាក់ទំនងជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ ដើម្បីឆ្ពោះទៅសម្រេច AEC នៅចុងឆ្នាំ២០១៥
- ចូលរួមកិច្ចប្រជុំក្រុមការងារជាន់ខ្ពស់ ស្តីពីសមាហរណកម្មសេដ្ឋកិច្ចអាស៊ាន (HLTF-EI) និងក្រុមការងារ ស្តីពីចក្ខុវិស័យសហគមន៍សេដ្ឋកិច្ចអាស៊ានក្រោយឆ្នាំ២០១៥។ HLTF-EI បាននិងកំពុងធ្វើបញ្ចប់នូវឯកសារក្របខ័ណ្ឌ ស្តីពីសហគមន៍សេដ្ឋកិច្ចអាស៊ានក្រោយឆ្នាំ២០១៥ ហើយគ្រោងរាយការណ៍ជូនរដ្ឋមន្ត្រីសេដ្ឋកិច្ចអាស៊ាន និងប្រមុខដឹកនាំអាស៊ាននៅក្នុងឆ្នាំ២០១៥។

## ២.២.១៨ ពាណិជ្ជកម្មទំនិញ

ចូលរួមកិច្ចប្រជុំគណៈកម្មាធិការសម្របសម្រួលទំនិញអាស៊ាន (CCA) ដើម្បីពិភាក្សាកែលម្អកិច្ចព្រមព្រៀងពាណិជ្ជកម្មទំនិញអាស៊ាន (ATIGA)។ កិច្ចប្រជុំរដ្ឋមន្ត្រីសេដ្ឋកិច្ច លើកទី៤៦ នៅថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១៤ បានស្វាគមន៍ចំពោះភាពជឿនលឿននៃសេរីភាវូបនីយកម្មពន្ធគយអាស៊ាន ដែលពន្ធនាំចូលចំនួន ៨៩% នៃបន្ទាត់ពន្ធគយត្រូវបានលុបបំបាត់ ហើយនឹងត្រូវលុបបំបាត់បន្ថែមទៀត ដើម្បីឈានទៅសម្រេចបាន AEC នៅឆ្នាំ២០១៥ ដោយផ្តល់នូវភាពទន់ភ្លន់ដល់ប្រទេសកម្ពុជា ឡាវ មីយ៉ាន់ម៉ា និងវៀតណាម រហូតដល់ឆ្នាំ ២០១៨ ។ ពិធីសារធ្វើវិសោធនកម្មកិច្ចព្រមព្រៀងសេដ្ឋកិច្ចអាស៊ានមួយចំនួន ពាក់ព័ន្ធពាណិជ្ជកម្មទំនិញ ត្រូវបានត្រូវចុះហត្ថលេខាដោយ

រដ្ឋមន្ត្រីសេដ្ឋកិច្ចអាស៊ាននៅក្នុងឆ្នាំ២០១៣។ ពិធីសារទាំងនេះ ត្រូវបានសភាកម្ពុជាផ្តល់សច្ចាប័ន ហើយកម្ពុជាបានជូនដំណឹងទៅ លេខាធិការដ្ឋានអាស៊ាន នៅថ្ងៃទី៤ ខែមេសា ឆ្នាំ២០១៤។

**វិធានការមិនមែនពន្ធគយ**

ចូលរួមសហការធ្វើការងារ ស្តីពីវិធានការមិនមែនពន្ធគយ (NTM)។ នៅពេលដែលពន្ធនាំចូលក្នុងតំបន់អាស៊ានត្រូវបានលុបចោលស្ទើរទាំងស្រុង ប្រទេសអាស៊ានមួយចំនួនបានដាក់ NTM ដើម្បីការពារផលិតផលក្នុងស្រុករបស់ខ្លួន។ ដើម្បីដោះស្រាយបញ្ហា NTM និងជួយសម្រួលពាណិជ្ជកម្ម គំនិតផ្តួចផ្តើមជាច្រើនត្រូវបានអនុវត្តរួមមាន: (១) ការធ្វើឱ្យស្របគ្នារវាងទិន្នន័យ NTM អាស៊ានស្របនឹងណាត់ថ្នាក់ថ្មីរបស់ UNCTAD (២) ការបង្កើតស្ថាប័នអន្តរក្រសួងនៅកម្រិតជាតិនៅក្នុងប្រទេសសមាជិកនីមួយៗ ដើម្បីពង្រឹងការសម្របសម្រួល ការខិតខំថ្នាក់ជាតិដោះស្រាយបញ្ហា NTM និង (៣) វិធានការដោះស្រាយបញ្ហា NTM ជាក់ស្តែង ដែលអាជីវកម្មជួបប្រទះ។ ប្រទេសថៃបានដាក់វិធានការ NTM មកលើការនាំចេញពោត ដំឡូង កម្ពុជា ហើយប្រទេសវៀតណាម បានដាក់ NTM មកលើការនាំចេញ សន្លឹកថ្នាំជក់របស់កម្ពុជា។ ដើម្បីដោះស្រាយបញ្ហានេះ រាជរដ្ឋាភិបាលបានចេញអនុក្រឹត្យ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការជាតិសម្រាប់វិធានការមិនមែនពន្ធ (លេខ ២៥៧ អនក្រ.បក) ចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១៤ ដែលមានក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុជាប្រធាន ក្រសួងពាណិជ្ជកម្ម និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជាអនុប្រធាន និងក្រសួង-ស្ថាប័នពាក់ព័ន្ធមួយចំនួនជាសមាជិក។

**ការបង្កើតនិហិដ្ឋានជាតិព័ត៌មានពាក់ព័ន្ធនឹងពាណិជ្ជកម្ម**

បន្តចូលរួមសហការជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុរៀបចំការបង្កើតនិហិដ្ឋានជាតិព័ត៌មានពាក់ព័ន្ធនឹងពាណិជ្ជកម្ម ដើម្បីដាក់ឲ្យដំណើរការនៅក្នុងខែមីនា ឆ្នាំ២០១៥។ ដើម្បីធ្វើឲ្យមានលំហូរដោយសេរីពាណិជ្ជកម្មទំនិញ នៅក្នុងមាត្រាទី១៣ នៃកិច្ចព្រមព្រៀងពាណិជ្ជកម្មទំនិញអាស៊ាន តម្រូវឲ្យអាស៊ានបង្កើតនិហិដ្ឋានព័ត៌មានពាក់ព័ន្ធនឹងពាណិជ្ជកម្មអាស៊ាន (NTR) ហើយប្រទេសជាសមាជិកតម្រូវឲ្យបង្កើតនិហិដ្ឋានជាតិព័ត៌មានពាក់ព័ន្ធនឹងពាណិជ្ជកម្មសិន មុននឹងអាចបង្កើតនិហិដ្ឋានព័ត៌មានពាក់ព័ន្ធនឹងពាណិជ្ជកម្មអាស៊ាន។ ការបង្កើតនិហិដ្ឋានជាតិព័ត៌មានពាក់ព័ន្ធនឹងពាណិជ្ជកម្ម គឺដើម្បីផ្តល់តម្លាភាពលើព័ត៌មានសម្រាប់ការធ្វើពាណិជ្ជកម្ម និងវិនិយោគនៅក្នុងអាស៊ានដល់សាធារណជន។ រាជរដ្ឋាភិបាលបានចេញអនុក្រឹត្យ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃនិហិដ្ឋានជាតិព័ត៌មានពាក់ព័ន្ធនឹងពាណិជ្ជកម្ម (លេខ ២៥៨ អនក្រ.បក) ចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១៤ ដែលមានក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាប្រធាន និងក្រសួងពាណិជ្ជកម្មជាអនុប្រធាន។ គេហទំព័រនិហិដ្ឋានជាតិព័ត៌មានពាក់ព័ន្ធនឹងពាណិជ្ជកម្ម ដែលមានក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុជាអ្នកទទួលខុសត្រូវបញ្ចូលព័ត៌មាន ហើយក្រសួងពាណិជ្ជកម្ម ជាអ្នកគ្រប់គ្រងគេហទំព័រ ត្រូវបានគ្រោងដាក់ឲ្យដំណើរការនៅក្នុងខែកញ្ញា ឆ្នាំ២០១៤ តែត្រូវបានពន្យាពេលដោយសារក្រុមហ៊ុន Software វៀតណាម ហើយបច្ចុប្បន្នធនាគារពិភពលោកបានស្នើប្រើប្រាស់ Software ដែលខ្លួនបានធ្វើសម្រាប់ប្រទេសឡាវ យកមកប្រើប្រាស់សម្រាប់កម្ពុជា និងគ្រោងដាក់ឲ្យដំណើរការនៅខែមីនា ឆ្នាំ២០១៥។

**ការចេញវិញ្ញាបនបត្រដោយអ្នកនាំចេញ**

បន្តសហការរៀបចំការងារ ស្តីពីការចេញវិញ្ញាបនប័ត្រប្រភពដើមទំនិញដោយអ្នកនាំចេញ។ នៅឯកិច្ចប្រជុំសេដ្ឋកិច្ចអាស៊ានលើកទី៤៦ រដ្ឋមន្ត្រីបានកោតសរសើរនូវការអនុវត្តគម្រោងសាកល្បង ទី១ និង ទី២ នៃការចេញវិញ្ញាបនបត្រដោយអ្នកនាំចេញបានយ៉ាងរលូន និងបានស្វាគមន៍ដល់ ប្រទេសកម្ពុជា និងមីយ៉ាន់ម៉ា ដែលសម្រេចចូលរួមនៅក្នុងគម្រោងសាកល្បងទី១ និងប្រទេសថៃ និងវៀតណាម ចូលរួមក្នុងគម្រោងសាកល្បងទី២។ រដ្ឋមន្ត្រីបានសង្កត់ធ្ងន់ថា នេះគឺជាគំនិតផ្តួចផ្តើមមួយ នៃគំនិតផ្តួចផ្តើម ស្តីពីការសម្រួលពាណិជ្ជកម្ម ដែលនឹងជួយកាត់បន្ថយនូវចំណាយអាជីវកម្ម និងបង្កើននូវការសម្រួលដល់ការ ធ្វើអាជីវកម្មនៅក្នុងអាស៊ាន ជាពិសេសសម្រាប់សហគ្រាសតូច និងមធ្យម។ មន្ត្រីអាស៊ាននឹងចាប់ផ្តើមពិភាក្សាពីចំណុចដូចគ្នា និងខុសគ្នានៃ គម្រោងសាកល្បងទាំងពីរ ដើម្បីឈានទៅអនុវត្តឲ្យបានពេញលេញការចេញវិញ្ញាបនបត្រ ដោយអ្នកនាំចេញនៅទូទាំងអាស៊ាននៅចុងឆ្នាំ២០១៥។

**ច្រកចេញ-ចូលតែមួយអាស៊ាន**

ចូលរួមតាមដានការចរចា និងអនុវត្តច្រកចេញចូលតែមួយអាស៊ាន (ASEAN Single Window-ASW)។ ប្រទេសអាស៊ានចំនួន ៧ បានបញ្ចប់ដោយជោគជ័យការសាកល្បងការអនុវត្ត ច្រកចេញតាមរយៈការផ្លាស់ប្តូរ អាស៊ានមួយចូលតែ-វិញ្ញាបនបត្រទម្រង់ D និងឯកសារប្រតិវេទ៍គយ អាស៊ាន។ អាស៊ានកំពុងពិភាក្សាលើពិធីសារ ស្តីពីក្របខ័ណ្ឌច្បាប់ ដើម្បីអនុវត្តឲ្យស្របគ្នា ASW រវាងប្រទេសសមាជិក។ ដោយកត់សម្គាល់លើសារៈសំខាន់ច្រកចេញចូលតែមួយរបស់អាស៊ាន នៅក្នុងកិច្ចប្រជុំលើកទី៤៦ បានជំរុញឲ្យសមាជិកដែលមិនទាន់បានអនុវត្ត ឲ្យពន្លឿនការអភិវឌ្ឍន៍ និងអនុវត្តឲ្យបានទាន់ពេលវេលា។

## ២.២.១៩ ពាណិជ្ជកម្មសេវា

**កិច្ចព្រមព្រៀងក្របខ័ណ្ឌអាស៊ានស្តីពីសេវាកម្ម**

- ចូលរួមកិច្ចប្រជុំគណៈកម្មាធិការសម្របសម្រួល អាស៊ាន ស្តីពីសេវាកម្ម លើកទី៧៨ និង៧៩ ដើម្បីចរចាបញ្ចប់សន្យាសេវាទី៩ នៃកិច្ចព្រមព្រៀងក្របខ័ណ្ឌអាស៊ាន ស្តីពីសេវាកម្ម។ ជាលទ្ធផល រដ្ឋមន្ត្រីសេដ្ឋកិច្ចអាស៊ាននៅថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១៤ បានចុះហត្ថលេខាលើ ពិធីសារដើម្បីអនុវត្តកញ្ចប់សន្យាទី៩ ក្រោមកិច្ចព្រមព្រៀងក្របខ័ណ្ឌអាស៊ាន ស្តីពីសេវាកម្ម និងចុះហត្ថលេខាលើកិច្ចព្រមព្រៀងទទួលស្គាល់ទៅវិញទៅមកស្តីពីសេវាគណនេយ្យអាស៊ាន នៅឯកិច្ចប្រជុំរដ្ឋមន្ត្រីសេដ្ឋកិច្ចលើកទី៤៦ នៅថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១៤ នៅទីក្រុងណៃពិដោ ប្រទេសមីយ៉ាន់ម៉ា។ រដ្ឋមន្ត្រីបានណែនាំឲ្យ CCS ខិតខំចរចាបញ្ចប់កញ្ចប់សន្យាសេវាទី១០ ក្រោម AFAS នៅឆ្នាំ២០១៥
- កម្ពុជាបានបញ្ចប់នូវ នីតិវិធីច្បាប់ក្នុងស្រុក និងបានជូនដំណឹងទៅ លេខាធិការដ្ឋានអាស៊ាន នៅថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៤ នូវពិធីសារដើម្បីអនុវត្តកញ្ចប់សន្យាសេវាកម្មចំនួន៥ នៅក្រោមកិច្ចព្រមព្រៀងក្របខ័ណ្ឌអាស៊ានស្តីពីសេវាកម្ម។

**<u>កិច្ចព្រមព្រៀងស្តីពីសេវាកម្មអាស៊ាន</u>**

ចូលរួមចរចាកិច្ចព្រមព្រៀង ស្តីពីសេវាកម្មអាស៊ាន ATISA ដើម្បីបញ្ចប់កិច្ចព្រមព្រៀងនេះ នៅក្នុងឆ្នាំ២០១៥ ដែលនឹងត្រូវជំនួសកិច្ចព្រមព្រៀង AFAS និងជាកិច្ចព្រមព្រៀងដែលមានភាពទូលំទូលាយ ដែលនឹងបង្កើននូវ សមាហរណកម្មសេវាអាស៊ានកាន់តែទូលំទូលាយ និងស៊ីជ្រៅ ព្រមទាំងសមាហរណកម្មអាស៊ានទៅក្នុងចង្វាក់តម្លៃពិភពលោក។

### ២.២.២០ វិនិយោគអាស៊ាន

ចូលរួមពិភាក្សានិងតាមដានការងារ ស្តីពីវិនិយោគអាស៊ាន។ ជាលទ្ធផល រដ្ឋមន្ត្រីសេដ្ឋកិច្ចអាស៊ានបានការចុះហត្ថលេខាលើ ពិធីសារដើម្បីធ្វើវិសោធនកម្ម កិច្ចព្រមព្រៀងវិនិយោគទូលំទូលាយអាស៊ាននៅឯ កិច្ចប្រជុំរដ្ឋមន្ត្រីសេដ្ឋកិច្ចលើកទី៤៦ នៅថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១៤ នារដ្ឋធានីណៃពិដោ ប្រទេសមីយ៉ាន់ម៉ា។

## ២.៣ កិច្ចសហប្រតិបត្តិការពាណិជ្ជកម្មជាមួយអឺរ៉ុប មជ្ឈឹមបូព៌ា និងអាហ្វ្រិក

- ចូលរួមជាមួយថ្នាក់ដឹកនាំក្រសួង ក្នុងការទទួលជួបជាមួយបណ្តាឯកអគ្គរដ្ឋទូតប្រចាំព្រះរាជាណាចក្រកម្ពុជារួមមាន៖ ឯកអគ្គរដ្ឋទូតអូទ្រីស ទុយនេស៊ី រុស្ស៊ី តួកគី ចក្រភពអង់គ្លេស និងបារាំង ដើម្បីពិភាក្សាអំពីកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច កម្មវិធីកសាងសមត្ថភាព និងកម្មវិធីជំនួយឧបត្ថម្ភផ្សេងៗ ជាពិសេសលើវិស័យពាណិជ្ជកម្ម និងវិនិយោគ
- ចូលរួមប្រជុំនៅក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិជាមួយអន្តរក្រសួង ដើម្បីពិនិត្យមើលសេចក្តីព្រាងសេចក្តីថ្លែងការណ៍ប្រធានអង្គប្រជុំ សម្រាប់កិច្ចប្រជុំកំពូលអាស៊ី-អឺរ៉ុប លើកទី១០ ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី១៦-១៧ ខែតុលា ឆ្នាំ២០១៤ នៅទីក្រុងមីឡង់ ប្រទេសអ៊ីតាលី
- ចូលរួមប្រជុំជាមួយគណៈកម្មាធិការចម្រុះពិសេសអន្តរក្រសួង រួមទាំងតំណាងសហភាពអឺរ៉ុបនៅកម្ពុជា ដើម្បីពិនិត្យមើលសេចក្តីព្រាង ឯកសារគោលពាក់ព័ន្ធនឹងយន្តការដោះស្រាយសំណងចំពោះអ្នកទទួលរងនូវការប៉ះពាល់ដោយបញ្ហាដីសម្បទានសេដ្ឋកិច្ចចំពោះការដាំអំពៅ
- រៀបចំបង្កើតអនុក្រឹត្យលេខ ២៨១អនក្រ.បក ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការជាតិ សម្រាប់កិច្ចសហប្រតិបត្តិការពាណិជ្ជកម្ម និងសេដ្ឋកិច្ចកម្ពុជា-បេឡារុស យោងទៅតាមសេចក្តីប្រកាសរួម (Joint Communique) របស់នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និងនាយករដ្ឋមន្ត្រីនៃសាធារណៈរដ្ឋបេឡារុស ចុះថ្ងៃទី២៣ ខែមេសា ឆ្នាំ២០១៤ នៅទីក្រុងមីនស្ក
- រៀបចំឱ្យមានជំនួបទ្វេភាគី រវាងថ្នាក់ដឹកនាំក្រសួងពាណិជ្ជកម្ម ដឹកនាំដោយឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម និងឯកឧត្តម Alexey Ulyukayev រដ្ឋមន្ត្រីអភិវឌ្ឍន៍សេដ្ឋកិច្ចនៃសហព័ន្ធរុស្ស៊ី នៅថ្ងៃទី២៨ ខែសីហា ឆ្នាំ ២០១៤ នៅទីក្រុងណៃពិដោរ ប្រទេសមីយ៉ាន់ម៉ា ដើម្បីពិភាក្សា អំពីការនាំចេញផលិតផលកសិកម្មកម្ពុជា ទៅកាន់សហព័ន្ធរុស្ស៊ី
- រៀបចំបេសកកម្មពាណិជ្ជកម្មទៅកាន់រដ្ឋគូវ៉ែត ពីថ្ងៃទី៣០ ខែវិច្ឆិកា ដល់ថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១៤ ដោយមានការចូលរួមពីវិស័យឯកជនរួមមាន៖ សហព័ន្ធអង្ករនៃកម្ពុជា និងក្រុមហ៊ុនឯកជនដទៃទៀត។ បេសកកម្មពាណិជ្ជកម្មនេះរួមមាន៖ កម្មវិធីផ្គូរផ្គងធុរជន សិក្ខាសាលាផ្សព្វផ្សាយ និងជំនួបទ្វេភាគី

- ចូលរួមជាមួយតំណាងក្រសួងពាណិជ្ជកម្ម ក្នុងកិច្ចប្រជុំត្រួតពិនិត្យចុងក្រោយ សម្រាប់ប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ដើម្បីពិនិត្យ និងពិភាក្សាលើ សេចក្តីព្រាងអនុក្រឹត្យស្តីពីគណៈកម្មាធិការជាតិសម្រាប់វិធានការមិនមែនពន្ធ មជ្ឈមណ្ឌលជាតិព័ត៌មានពាក់ព័ន្ធនឹងពាណិជ្ជកម្ម និងការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការសម្របសម្រួលនាវាចរណ៍មេគង្គកម្ពុជា
- ចូលរួមសន្និសីទពិភពលោករបស់អង្គការ TPO (Trade Promotion Oganization) ពីថ្ងៃទី០៣-០៦ ខែវិច្ឆិកា ឆ្នាំ២០១៤ នៅទីក្រុងឌូបៃ ប្រទេសអារ៉ាប់រួម ស្តីពី (១) ការលើកកម្ពស់នូវតួនាទីរបស់អង្គការជំរុញពាណិជ្ជកម្មក្នុងការជួយសហគ្រាសខ្នាតតូច និងមធ្យម ដើម្បីធ្វើសមាហរណកម្មនៅក្នុងសង្វាក់តម្លៃ និងការផ្គត់ផ្គង់សាកល (២) ការផ្តល់ជ័យលាភីចំពោះអង្គការជំរុញពាណិជ្ជកម្ម និង (៣) ការរៀបចំសន្និសីទនេះនៅឆ្នាំ២០១៦
- ចូលរួមជាវាគ្មិន នៅក្នុងសិក្ខាសាលា ស្តីពីការលើកកម្ពស់ការប្រើប្រាស់កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីដោយសហគ្រាសធុនតូច និងមធ្យម នៅថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៤ ដែលរៀបចំដោយវិទ្យាស្ថានស្រាវជ្រាវ និងបណ្តុះបណ្តាលពាណិជ្ជកម្ម នៅក្រសួងពាណិជ្ជកម្ម
- បាននិងកំពុងសិក្សាស្រាវជ្រាវព័ត៌មានទាក់ទងនឹងសភាពការណ៍ និងវឌ្ឍនភាពវិស័យសេដ្ឋកិច្ចនៅតំបន់អឺរ៉ុប មជ្ឈឹមបូព៌ា និងអាហ្វ្រិក។

## ២.៤ កិច្ចសហប្រតិបត្តិការពាណិជ្ជកម្មជាមួយទ្វីបអាមេរិក

- សម្របសម្រួលដំណើរទស្សនកិច្ចក្រុមប្រឹក្សាធុរកិច្ច សហរដ្ឋអាមេរិក-អាស៊ាន (USABC) (មានក្រុមហ៊ុនដូចជា: Apple, ConocoPhilips, General Electric, Moody's, Oracle, RMA Group, and Visa) ស្វែងយល់ពីសក្តានុពលវិនិយោគនៅកម្ពុជា និងផ្សរផ្គងក្រុមវិនិយោគិនសហរដ្ឋអាមេរិក និងកម្ពុជាដែលរៀបចំដោយឯកឧត្តម William E. Todd ឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិកប្រចាំនៅកម្ពុជា
- ធ្វើកិច្ចសហប្រតិបត្តិការជាមួយនឹងប្រទេសកាណាដា ក្នុងការសម្របសម្រួលជួបជាមួយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាលើសេចក្តីស្នើសុំចុះ "កិច្ចព្រមព្រៀងការជំរុញ និងការការពារវិនិយោគទុនបរទេស - Foreign Investment Protection and Promotion Agreement"
- រៀបចំទទួលដំណើរទស្សនកិច្ចស្វែងយល់ពីឱកាសធ្វើពាណិជ្ជកម្ម និងវិនិយោគទុន របស់គណៈប្រតិភូសហរដ្ឋអាមេរិក ដែលដឹកនាំដោយព្រឹទ្ធសភាសហរដ្ឋអាមេរិក H.E. Mr Don Benton ដឹកនាំគណៈប្រតិភូមកពីទីក្រុង Seattle រដ្ឋ Washington
- ជួយសិក្សាវិភាគពីវិធានប្រភពដើមទំនិញ (35% នីតិវិធីនៃការបំប្លែង) ទំនិញត្រឹមត្រូវតាមប្រព័ន្ធអនុគ្រោះពន្ធ សម្រាប់ផលិតម្សៅផ្សំគ្រឿងចំណីអាហារ (glycine food) និងឧស្សាហកម្ម (glycine industry) សម្រាប់នាំទៅកាន់ទីផ្សារសហរដ្ឋអាមេរិក ដែលមាន HTS 29225011 ឲ្យដល់ក្រុមហ៊ុន JIZHOU CITY HUAYANG CHEMICAL CO., LTD មុនធ្វើការសម្រេចមកវិនិយោគបើករោងចក្រនៅកម្ពុជា
- ធ្វើការផ្សរផ្គងក្រុមហ៊ុនបញ្ជាទិញរបស់សហរដ្ឋមេរិក កាណាដា ជាមួយក្រុមហ៊ុនកម្ពុជា៖ 1) ក្រុមហ៊ុន Gel Spice Company Inc. ជួបជាមួយសមាគមអ្នកដាំម្រេចនៅ ឃុំដា, ស្រុកមេមុត ខេត្តត្បូងឃ្មុំ 2) កំពុងធ្វើការផ្សរផ្គងក្រុមហ៊ុនកាណាដា ជាមួយកម្ពុជា ដើម្បីផ្គត់ផ្គង់បំពង់ខ្យល់ធ្វើពីអាលុយមីញ៉ូមចំនួនច្រើន 3) ក្រុមហ៊ុន National Importers Inc. របស់កាណាដា មានបំណងទិញនំបញ្ចុកក្រៀម "Rice Vermicelli" ជួបជាមួយក្រុមហ៊ុន RM Cambodia 4) ក្រុមហ៊ុន Contrast, Inc.

ជាក្រុមហ៊ុនផ្គត់ផ្គត់សម្ភារៈសង្ហារឹម នៅសហរដ្ឋអាមេរិកកំពុង ស្វែងរកក្រុមហ៊ុនទទួលទិញផលិតផលរបស់ខ្លួននៅកម្ពុជា 5) ក្រុមហ៊ុន Worldwide Protective តម្រូវការបញ្ជាទិញស្រោមដៃជួបជាមួយក្រុមហ៊ុន SWANY (Cambodia) និង (U.S.A) Co., Ltd ជាអ្នកផ្គត់ផ្គង់ស្រោមដៃនៅកម្ពុជា 6) ក្រុមហ៊ុន Angles New York U.S., Inc. តម្រូវការបញ្ជាទិញសម្លៀកបំពាក់សម្រាប់កូនក្មេងជួបជាមួយសមាជិករបស់ GMAC 7) ក្រុមហ៊ុន Safdie & Co., Inc កាណាដា ជួបជាមួយសមាជិករបស់ GMAC ដែលមានបំណងបញ្ជាទិញទំនិញវាយនភ័ណ្ឌសម្រាប់គេហដ្ឋានដូចជាៈ កន្សែងពោះគោ (បន្ទប់ទឹក, ចង្ក្រានបាយ, ឆ្នេរសមុទ្រ, សំអាតផ្ទះ), ភួយ, កំរាលពូក...។ល។

## ២.៥ ការងារសមាហរណកម្មសាកល

- ផ្តល់ព័ត៌មាន ស្តីពីអាជ្ញាប័ណ្ណនាំចូល (Import Licensing) សម្ភារៈកសិកម្ម និងផលិតផលមានប្រភពដើមពីសត្វ ទៅការិយាល័យចុះបញ្ជីកណ្តាលសម្រាប់ការផ្តល់ព័ត៌មាននៃលេខាធិការដ្ឋានអង្គការពាណិជ្ជកម្មពិភពលោក
- សហការជាមួយមន្ត្រីជំនាញនៃក្រសួងស្ថាប័នពាក់ព័ន្ធពិនិត្យ និងប្រមូលឯកសារ ស្តីពីអនាម័យ និងភូតគាមអនាម័យ (Sanitary and Phyto-sanitary) ដើម្បីផ្តល់ព័ត៌មានទៅការិយាល័យ ចុះបញ្ជីកណ្តាល នៃលេខាធិការដ្ឋានអង្គការពាណិជ្ជកម្មពិភពលោក
- តាមដាន និងសិក្សាការផ្តល់ព័ត៌មាន អំពីវិធានការរបស់សមាជិកដទៃទៀត នៃអង្គការពាណិជ្ជកម្មពិភពលោក ដើម្បីផ្តល់អនុសាសន៍ទាន់ពេលវេលា ក្នុងករណីមានផលប៉ះពាល់មកលើការធ្វើពាណិជ្ជកម្មរបស់កម្ពុជា
- រៀបចំឯកសារផ្តល់ព័ត៌មាន អំពីកិច្ចសម្រួលពាណិជ្ជកម្ម ជូនដល់លេខាធិការដ្ឋានអង្គការពាណិជ្ជ កម្មពិភពលោក
- រៀបចំសិក្ខាសាលា ស្តីពីកិច្ចសម្រួលពាណិជ្ជកម្មក្រោមក្របខណ្ឌ WTO ដើម្បីធ្វើការវាយតម្លៃតម្រូវការ និងបញ្ហាអាទិភាពនៅខែមិថុនា ឆ្នាំ២០១៤
- ចូលរួមក្នុងកិច្ចប្រជុំតុមូលសម្រាប់បណ្តាប្រទេសអភិវឌ្ឍន៍តិចតួច ជាសមាជិក WTO នៅប្រទេសឡាវ ដើម្បីស្វែងរកជំហររួម ជំរុញការអភិវឌ្ឍន៍ពាណិជ្ជកម្មនៅ ក្នុងបណ្តាប្រទេសទាំងនោះ
- ចូលរួមក្នុងសន្និសីទរដ្ឋមន្ត្រីអង្គការពាណិជ្ជកម្មពិភពលោកលើកទី៩ (9th WTO Ministerial Conference) នៅបាលី ប្រទេសឥណ្ឌូណេស៊ី ដើម្បីជំរុញការអនុវត្តការនាំចេញដោយគ្មានកូតា និងរួចពន្ធសម្រាប់ប្រទេសអភិវឌ្ឍន៍តិចតួច ទៅកាន់ទីផ្សារប្រទេសអភិវឌ្ឍន៍ តាមរយៈការអនុវត្តកញ្ចប់វិធានការទីក្រុងបាលី (Bali Package)
- ផ្តល់មតិបច្ចេកទេស ចំពោះសេចក្តីព្រាងលិខិតរួមរបស់ អាស៊ានឆ្លើយតបទៅនឹងច្បាប់របស់អាមេរិកឆ្នាំ២០១៤ ស្តីពីការហាមឃាត់ការនាំចូល អំបូរត្រីអណ្តែង (Catfish) ពីវៀតណាម ហ្វីលីពីន និងថៃឡង់ដ៍
- ផ្តល់មតិលើអត្ថបទដែលរៀបចំដោយលេខាធិការដ្ឋាន WTO ត្រង់ផ្នែកដែលពាក់ព័ន្ធនឹងការសន្យាវិស័យសេវាកម្ពុជាក្នុង កិច្ចព្រមព្រៀងតំបន់ពាណិជ្ជកម្មសេរី អាស៊ាន-អូស្ត្រាលី-ញូវហ្សេឡែន (AANZFTA)

- ផ្តល់មតិជូនរាជរដ្ឋាភិបាលលើសេចក្តីព្រាងរួម របស់ក្រុមប្រទេសអភិវឌ្ឍន៍តិចតួច ស្តីពីការអនុវត្តការលើកលែងដែលផ្តល់កិច្ចអនុគ្រោះចំពោះការផ្គត់ផ្គង់សេវា និងសេវាកម្ម ដើម្បីការពារផលប្រយោជន៍របស់កម្ពុជា ក្នុងទីផ្សារប្រទេសអភិវឌ្ឍន៍
- ផ្តល់មតិជូនរាជរដ្ឋាភិបាលកម្ពុជា លើសំណើរបស់អង្គការសហប្រជាជាតិ ស្នើសុំរាជរដ្ឋាភិបាលកម្ពុជាពិចារណាលើការចុះហត្ថលេខា លើអនុសញ្ញាពីរ របស់អង្គការសហប្រជាជាតិ គឺអនុសញ្ញាស្តីពីកិច្ចសន្យាលក់ទំនិញជាអន្តរជាតិ និងអនុសញ្ញា ស្តីពីការធានាទូទាត់ក្នុងពាណិជ្ជកម្មអន្តរជាតិ
- ធ្វើបច្ចុប្បន្នភាព កម្មវិធីការងាររបស់រាជរដ្ឋាភិបាល ក្រោមកាតព្វកិច្ចរបស់អង្គការពាណិជ្ជកម្មពិភពលោក ដោយដកចេញនូវកិច្ចការមួយចំនួន ដែលសម្រេចបានរួចហើយ ដោយក្រសួងពាណិជ្ជកម្ម និងស្ថាប័នពាក់ព័ន្ធ
- បន្តកែសម្រួលលើអត្ថបទនៃសេចក្តីព្រាងច្បាប់ឧបាស្រ័យពាណិជ្ជកម្មជាភាសាខ្មែរ ដែលបានបកប្រែរួចដោយក្រុមហ៊ុនបកប្រែ ដែលជួលដោយអង្គការ USAID
- ធ្វើសេចក្តីផ្តល់ព័ត៌មាន អំពីឧបត្ថម្ភធនក្នុងស្រុក និងការគាំពារសម្រាប់ការនាំចេញរបស់កម្ពុជា រួចផ្ញើទៅក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ដើម្បីបញ្ជូនបន្តទៅអង្គការពាណិជ្ជកម្មពិភពលោក
- រៀបចំសំណុំឯកសាររួចរាល់ ដើម្បីត្រៀមផ្តល់ព័ត៌មានអំពីកម្មសិទ្ធិបញ្ញា (Intellectual Property Rights) ទៅអង្គការពាណិជ្ជកម្មពិភពលោក
- ចូលរួមកិច្ចពិភាក្សាមេគង្គ-ជប៉ុន ស្តីពីគម្រោងអភិវឌ្ឍន៍ឧស្សាហកម្មធុនតូច និងមធ្យម សម្រាប់ប្រទេសកម្ពុជា ឡាវ ភូមា និងវៀតណាម នៅទីក្រុងបាងកក។

## ២.៦ ការងារកសាងបញ្ញត្តិច្បាប់ពាណិជ្ជកម្ម

- បញ្ចប់ការងាររៀបចំច្បាប់ ស្តីពីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ ដែលបានឆ្លងកាត់ការអនុម័តដោយរដ្ឋសភា ព្រឹទ្ធសភា និងបានប្រកាសដាក់ឲ្យប្រើប្រាស់ដោយព្រះរាជក្រម លេខនស/រកម/០១១៤/០០៦ ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០១៤
- បញ្ចប់សេចក្តីព្រាងច្បាប់ ស្តីពីកិច្ចការពារអ្នកប្រើប្រាស់ និងត្រៀមបញ្ជូនទៅទីស្តីការគណៈរដ្ឋមន្ត្រីនៅដើមឆ្នាំ២០១៥
- កំពុងប្រជុំពិភាក្សា អំពីមតិយោបល់ដែលទទួលបានពីស្ថាប័នពាក់ព័ន្ធ លើសេចក្តីព្រាងច្បាប់ស្តីពីការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក (E-Commerce) ដើម្បីបញ្ចូលមតិយោបល់ទាំងនេះទៅក្នុងខ្លឹមសារនៃសេចក្តីព្រាងច្បាប់។ ទន្ទឹមនឹងនេះក៏បានរៀបចំប្រកាសបង្កើតក្រុមការងារចម្រុះមកពីក្រសួងពាណិជ្ជកម្ម ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ក្រសួងយុត្តិធម៌ និងធនាគារជាតិនៃកម្ពុជា ដើម្បីពិភាក្សាលើសេចក្តីព្រាងច្បាប់នេះ
- កំពុងធ្វើការកែសម្រួលខ្លឹមសារមាត្រាមួយចំនួន នៃសេចក្តីព្រាងច្បាប់កិច្ចសន្យាពាណិជ្ជកម្មជាមួយក្រសួងយុត្តិធម៌ ដើម្បីឲ្យមានសង្គតភាព ជាមួយនឹងខ្លឹមសារនៃក្រមរដ្ឋប្បវេណី។ ជាលទ្ធផលការកែសម្រួលសេចក្តីព្រាងច្បាប់នេះបានសម្រេចមួយផ្នែកធំ នៅសល់តែជំពូក ស្តីពីកិច្ចសន្យាទិញ-លក់ ចលនទ្រព្យ អចលនទ្រព្យ និងមូលនិធិពាណិជ្ជកម្ម ហើយនិងមាត្រាដែលទាក់ទងនឹងកិច្ចសន្យាម៉ៅការ ដែលត្រូវពិនិត្យឡើងវិញ ជាមួយក្រសួងយុត្តិធម៌ ដែលកិច្ចការនេះរំពឹងថានឹងត្រូវបញ្ចប់នៅដំណាច់ខែធ្នូ ឆ្នាំ២០១៤នេះ

- រៀបចំសេចក្តីព្រាងអនុក្រឹត្យ ស្តីពីការបង្កើតអនុគណៈកម្មការអនុវត្តច្បាប់កម្មសិទ្ធិបញ្ញា និងអនុគណៈកម្មការអប់រំ និងផ្សព្វផ្សាយ ចប់សព្វគ្រប់ និងបញ្ជូនទៅទីស្តីការគណៈរដ្ឋមន្ត្រីរួចហើយ
- កំពុងរៀបចំសេចក្តីព្រាងអនុក្រឹត្យ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រុមទទួលបន្ទុកម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ
- កំពុងរៀបចំសេចក្តីព្រាងសារាចរណែនាំ ស្តីពីការអនុវត្តន៍នីតិវិធីពាក់ព័ន្ធនឹងការទទួលស្គាល់សិទ្ធិផ្តាច់មុខក្នុងការប្រើប្រាស់ម៉ាកលើមុខទំនិញ
- កំពុងរៀបចំសេចក្តីព្រាងប្រកាស ស្តីពីនីតិវិធីនៃការអនុវត្តច្បាប់ស្តីពី ម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ
- កំពុងរៀបចំសេចក្តីព្រាងប្រកាស ស្តីពីម៉ាកបញ្ជាក់ពីចរិកលក្ខណៈទំនិញនិងសេវា(Certification Mark)
- កំពុងធ្វើការសិក្សាស្រាវជ្រាវលើការងារបង្កើតស្ថាប័ន និងយន្តការ ដើម្បីអនុវត្ត ស្តីពីការប្រកួតប្រជែង ដោយផ្អែកលើខ្លឹមសារ នៃសេចក្តីព្រាងច្បាប់ដែលទើបនឹងបានបញ្ចប់ជាបឋម។ ទន្ទឹមនឹងនេះក៏បានធ្វើការស្រាវជ្រាវរៀបចំគោលនយោបាយនៃការប្រកួតប្រជែង ហើយធ្វើការវាយតម្លៃផលប៉ះពាល់ នៃសេចក្តីព្រាងច្បាប់នេះ ជាមួយក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ECOSSOC)
- រៀបចំកិច្ចសហប្រតិបត្តិការជាមួយសាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ (IFC) ដើម្បីបង្កើនសមត្ថភាពការចុះបញ្ជីប្រតិបត្តិការមានកិច្ចធានា តាមប្រព័ន្ធអេឡិចត្រូនិចឱ្យមានប្រសិទ្ធិភាព។ ទន្ទឹមនឹងនេះបានសហការជាមួយធនាគារអេស៊ីលីដា និងមជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្មដើម្បីធ្វើការផ្សព្វផ្សាយ ការអនុវត្តច្បាប់ ស្តីពីប្រតិបត្តិការមានកិច្ចធានា និងច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ជូនដល់សភាពាណិជ្ជកម្ម និងអាជីវករនៅតាមបណ្តាខេត្តសំខាន់ៗ មួយចំនួនដែលនៅក្នុងឆ្នាំ ២០១៤ នេះបានធ្វើឡើងនៅក្នុងខេត្តសំខាន់ៗ មួយចំនួន។ ក្នុងឆ្នាំ២០១៤ ក្រសួងបានទទួលចុះបញ្ជីតម្កល់លិខិតជូនដំណឹងប្រតិបត្តិការដែលមានកិច្ចធានាបានចំនួន ១.៣៤៩សំណុំរឿងដែលក្នុងនោះមានទាំងទ្រព្យអរូបីយ៍ និងទ្រព្យរូបីយ៍មួយចំនួនជាភាគហ៊ុនត្រូវបានដាក់ធានា
- បំពេញការងារវាយតម្លៃផលប៉ះពាល់លិខិតបទដ្ឋានគតិយុត្ត ដោយសហការជាមួយក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ នៃទីស្តីការគណៈរដ្ឋមន្ត្រី តាមរយៈការវាយតំលៃប្រកាស និងសេចក្តីព្រាងច្បាប់មួយចំនួនរបស់ក្រសួងពាណិជ្ជកម្ម
- ផ្តល់ការពិភាក្សាពិគ្រោះយោបល់ផ្នែកច្បាប់ សម្រាប់ការចុះបញ្ជីពាណិជ្ជកម្ម ដល់អាជីវករ និងធុរជនដើម្បីធ្វើឲ្យមានអនុលោមភាពទៅតាមការកំណត់របស់ច្បាប់
- ប្រជុំជាមួយជំនាញការ នៃអង្គការកម្មសិទ្ធិបញ្ញាពិភពលោក ស្តីពីការបង្កើតសាលាបណ្តុះបណ្តាលកម្មសិទ្ធិបញ្ញា របស់អង្គការកម្មសិទ្ធិបញ្ញាពិភពលោកនៅកម្ពុជា
- រៀបចំនីតិវិធីពាក់ព័ន្ធនានា ដើម្បីត្រៀមទទួលពាក្យស្នើសុំចុះបញ្ជីម៉ាកសមូហភាព (Collective Mark)
- បញ្ចប់ការកែសម្រួលសេចក្តីព្រាងច្បាប់ឧបាស្រ័យពាណិជ្ជកម្មជាភាសាខ្មែរ និងកំពុងរៀបចំបញ្ជូនទៅទីស្តីការគណៈរដ្ឋមន្ត្រី។

## ២.៧ ការងារអភិវឌ្ឍន៍វិស័យឯកជន

- ចូលរួមរៀបចំវេទិកាបើកទូលាយ ឲ្យវិស័យឯកជនផ្តល់យោបល់ សម្រាប់កែលម្អបរិយាកាសពាណិជ្ជកម្ម នៅខែធ្នូ ឆ្នាំ២០១៣
- ចូលរួមរៀបចំសិក្ខាសាលាស៊េរីចំនួន ៥លើកៈ សិក្ខាសាលាលើកទីមួយ បានប្រព្រឹត្តទៅនៅថ្ងៃទី២៩-៣០ ខែមីនា ឆ្នាំ២០១៤ ក្រោមប្រធានបទ ស្តីពី "កំណែទម្រង់ក្រសួងពាណិជ្ជកម្ម និង E-Commerce" និងសិក្ខាសាលាលើកទីពីរ ស្តីពី "បច្ចុប្បន្នភាពនៃកំណែទម្រង់ក្រសួងពាណិជ្ជកម្ម និងសុវត្ថិភាពស្បៀង" ដែលប្រព្រឹត្តទៅនៅថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១៤ នៅទីស្តីការក្រសួងពាណិជ្ជកម្ម សាលប្រជុំអង្គរវត្ត ដែលមានសិក្ខាកាមចូលរួមប្រហែល ២.១៥០នាក់ ដែលជាសិស្សនិស្សិតពីបណ្តាសាកលវិទ្យាល័យនានា មន្ត្រីរាជការ និងសាធារណៈជន ក្រោមអធិបតីដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម។ សិក្ខាសាលាលើកទីបី ប្រព្រឹត្តទៅនៅវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា កាលពីថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០១៤ ក្រោមប្រធានបទ ស្តីពី "សារៈសំខាន់នៃជំនាញភាពជាអ្នកដឹកនាំ - សម្រាប់ សិស្ស និស្សិត នាពេលបច្ចុប្បន្ន ក្នុងខណៈដែលកម្ពុជាចូលជាសមាជិកសហគមន៍ សេដ្ឋកិច្ចអាស៊ាន ឆ្នាំ២០១៥" ដែលមានលោក John G. Rice អនុប្រធានក្រុមហ៊ុន General Electric និងឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្មជាវាគ្មិនដ៏សំខាន់ សម្រាប់សិក្ខាកាមជានិស្សិតប្រមាណជាង ២.០០០នាក់។ សិក្ខាសាលាលើកទីបួន ប្រព្រឹត្តទៅនៅវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជានាថ្ងៃទី០១ ខែតុលា ឆ្នាំ២០១៤ ក្រោមប្រធានបទ ស្តីពី "តួនាទីនៃភាពច្នៃប្រឌិត ក្នុងសេដ្ឋកិច្ច សម័យឌីជីថល" ដែលមានសិក្ខាកាមចូលរួមជាក្រុមនិស្សិតប្រមាណជាង ២.០០០នាក់ ក្រោមអធិបតីដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម និងលោក Mike Nelson អនុប្រធានក្រុមហ៊ុន Google, Inc.។ និងសិក្ខាសាលាលើកទីប្រាំ ប្រព្រឹត្តទៅថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១៤ ក្រោមប្រធានបទ "ជំនាញនៃភាពជាអ្នកដឹកនាំដើម្បីជំរុញទឹកចិត្តបទពិសោធន៍ នៃការជួយសង្គ្រោះ" នៅវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា ក្នុងគោលបំណងផ្តល់នូវចំណេះដឹង និងបទពិសោធន៍ល្អៗ ពីថ្នាក់ដឹកនាំក្នុងស្ថាប័នរដ្ឋ និងឯកជនជូនដល់សិស្ស និស្សិត និងមន្ត្រីរាជការ ក្រោមអធិបតីភាពរបស់ឯកឧត្តមទេសរដ្ឋមន្ត្រី ក្រសួងពាណិជ្ជកម្ម និងលោក Scott Neeson ស្ថាបនិក Cambodian Children's Fund ដែលមានអ្នកចូលរួមចំនួនប្រមាណ ២.០០០នាក់
- ជូនដំណឹងដល់ផលិតករ ពាណិជ្ជករ ស្តីពីស្តង់ដារកម្ពុជាចំនួន ១០ ដែលជាស្តង់ដារបញ្ញាសម្រាប់ទំនិញសិប្បកម្ម និងផលិតកម្មខ្នាតតូច
- ចូលរួមកំណត់វិធានការទប់ស្កាត់ កុំឲ្យឈ្មួញកណ្តាល បញ្ចុះតម្លៃស្រូវក្នុងរដូវច្រូតកាត់ប្រមូលផលរបស់ប្រជាកសិករ ដោយឆ្លុះបញ្ចាំងនូវតថភាពមួយចំនួន ដែលវិស័យឯកជនកំពុងប្រឈម និងលទ្ធភាពរបស់ក្រសួងពាណិជ្ជកម្មក្នុងការជួយសម្រួលដល់កសិករ និងអាជីវករ
- ចូលរួមរៀបចំកិច្ចប្រជុំជាមួយគម្រោង "កម្មវិធីរោងចក្រកាន់តែប្រសើរនៅកម្ពុជា" ដែលអនុវត្តដោយ អង្គការពលកម្មអន្តរជាតិ ILO សហការជាមួយក្រសួងពាណិជ្ជកម្ម និងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សំដៅស្វែងរកមធ្យោបាយ និងដំណោះស្រាយដើម្បីកាត់បន្ថយវិវាទការងារនៅក្នុងរោងចក្រ ពង្រឹងការគោរពច្បាប់ការងារ លើកកម្ពស់ការយល់ដឹងរបស់កម្មករនិយោជិតក្នុងការប្រតិបត្តិវិន័យ និងការថែទាំសុខភាព អាហារូបត្ថម្ភ សំដៅបង្កើនផលិតភាពផលិតកម្ម

- កំពុងសហការជាមួយវិស័យឯកជន បង្កើតសហព័ន្ធដំឡូងមីកម្ពុជាដើម្បីសម្រួល និងជំរុញការនាំចេញដំឡូងមីទៅទីផ្សារក្រៅប្រទេស
- កំពុងរៀបចំសេចក្តីព្រាងព្រះរាជក្រឹត្យ ស្តីពីការបង្កើតក្រុមប្រឹក្សាជាតិសូត្រកម្ពុជា និងអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាជាតិសូត្រកម្ពុជា ដើម្បីរៀបចំយុទ្ធសាស្ត្រ ជំរុញវិស័យសូត្រនៅកម្ពុជា និងធ្វើពិពិធកម្ម ការធ្វើអាជីវកម្ម ពិសេសការនាំចេញផលិតផលសូត្រខ្មែរ ក្នុងគោលដៅជំរុញឲ្យទៅជាទំនិញម៉ាកសម្គាល់ភូមិសាស្ត្រ
- ចុះទៅជួយបង្កើតសមាគមកសិករដាំក្រូចពោធិ៍សាត់ ដែលមានផ្ទៃដីប្រមាណជាង ១០០០ហិកតា នៅខេត្តពោធិ៍សាត់ ដើម្បីងាយស្រួលក្នុងការគ្រប់គ្រងផលិតកម្ម បង្កើនគុណភាពផលិតផល និងជួយគ្នាទៅវិញទៅមក ក្នុងចំណោមអ្នកដាំដុះក្រូច សំដៅជំរុញអាជីវកម្ម ទាំងទីផ្សារក្នុងស្រុក និងការនាំចេញទៅក្រៅប្រទេស
- សហការជាមួយធនាគារពិភពលោក រៀបចំសិក្ខាសាលា អំពីកម្មវិធីគោលថ្នាក់ជាតិស្តីពីភស្តុភារពាណិជ្ជកម្ម ដែលបានប្រព្រឹត្តទៅនៅថ្ងៃទី០២-០៣ ខែកញ្ញា ឆ្នាំ២០១៤ សំដៅស្វះស្វែងរកវិធានការ និងបង្កើតយន្តការជួយសម្រួលដល់ការនាំចេញអង្ករ និងទំនិញផ្សេងៗរបស់កម្ពុជាទៅកាន់ទីផ្សារអន្តរជាតិឲ្យបានច្រើនបំផុត
- ចូលរួមធ្វើការតាមដាន និងធ្វើរបាយការណ៍ថ្លៃទំនិញប្រចាំថ្ងៃសម្រាប់ការវិភាគ និងផ្សព្វផ្សាយ
- ចេញវិញ្ញាបនបត្រទទួលស្គាល់ និងតម្កល់ទុកលក្ខន្តិកៈសមាគមចំនួន ០៦ សមាគមរួមមានៈ សមាគមពាណិជ្ជកម្មកម្ពុជា ជប៉ុន (JBAC), សមាគមស្វាយខេត្តកំពង់ស្ពឺ, សមាគមម៉ាស៊ីនកិនស្រូវខេត្តកំពង់ស្ពឺសមាគមអាជីវកម្មក្រូចពោធិ៍សាត់អង្គ្រង (ខេត្តពោធិ៍សាត់), សមាគមអភិវឌ្ឍន៍កសិផលស្រុកបារាយណ៍ និងសហព័ន្ធស្រូវអង្ករកម្ពុជា
- ចេញប្រកាស ស្តីពីការទទួលស្គាល់សមាជិកទីប្រឹក្សាបន្ថែមសភាពាណិជ្ជកម្ម មណ្ឌលខេត្ត កំពត កែប និងតាកែវ ចំនួន ៣រូប
- រៀបចំបង្កើតគណៈកម្មការបោះឆ្នោតសភាពាណិជ្ជកម្ម និង ជូនដំណឹងទៅសភាស្តីការបោះឆ្នោតរៀបចំសន្និបាតកំពូលសភាពាណិជ្ជកម្មទូទាំងប្រទេស
- តាមដានការវិវត្តន៍ថ្លៃប្រេងឥន្ធនៈ នៅលើទីផ្សាររាជធានីខេត្ត ដើម្បីធ្វើការផ្សព្វផ្សាយជាទូទៅសំដៅបម្រើផលប្រយោជន៍សាធារណៈជន
- ចេញលិខិតអនុញ្ញាតបិទស្លាកថ្លៃលើមុខទំនិញ និងសេវាកម្មជារូបិយវត្ថុបរទេសចំនួន ៤៧ច្បាប់ ជូនអាជីវករនៅតាមទីផ្សារ និងផ្សារទំនើបនានាសំដៅពង្រឹងតម្លាភាព រវាងអ្នកលក់និងអ្នកទិញ
- តាមដាន និងបូកសរុបរបាយការណ៍ នៃការអនុវត្តចេញលិខិតអនុញ្ញាតធ្វើអាជីវកម្ម ពាណិជ្ជកម្មសេវាកម្ម និងលិខិតអនុញ្ញាតធ្វើអាជីកម្មត្បូងថ្មមានតម្លៃជាគ្រឿងអលង្ការ របស់មន្ទីរពាណិជ្ជកម្មរាជធានីខេត្តដើម្បីធានាប្រសិទ្ធភាពនៃការធ្វើប្រតិភូកម្មពីថ្នាក់កណ្តាលទៅថ្នាក់ខេត្ត
- ចូលរួមការដាក់តាំង បង្ហាញផលិតផលបន្លែ និងផ្លែឈើកម្ពុជាលើកទី៦ នៅសៀមរាបដើម្បីស្រាវជ្រាវផលិផលសក្តានុពលផលិតផលថ្មីៗ សម្រាប់ផ្សព្វផ្សាយដល់វិនិយោគិន អាជីវករ និងសាធារណៈជន។

## ២.៨ ការចងក្រង និងផ្តល់ព័ត៌មានពាណិជ្ជកម្ម

- ធ្វើការកែសម្រួលសៀវភៅ ស្ថិតិពាណិជ្ជកម្ម ស្តីពីស្ថានភាពទំនិញនាំចេញ-នាំចូល ឲ្យកាន់តែមានសោភ័ណភាពដោយចែកជាជំពូកទៅតាមបណ្តាប្រទេស និងតាមប្រភេទទំនិញព្រមទាំងបញ្ចូលក្រាហ្វិក (Graphic) បង្ហាញជាលក្ខណៈសង្ខេបៗ ងាយស្រួលសម្រាប់អ្នកប្រើប្រាស់សៀវភៅនេះ។ ដោយឡែកការកំណត់នីតិវិធីជាក់លាក់ សម្រាប់ការស្រង់ស្ថិតិពាណិជ្ជកម្ម ឱ្យបានសុក្រឹតតាមអគ្គនាយកដ្ឋាន និងនាយកដ្ឋានពាក់ព័ន្ធ នៅពុំទាន់សម្រេចបានពេញលេញតាមផែនការនៅឡើយ។ កិច្ចការនេះកំពុងជំរុញ ស្វែងរកនីតិវិធី និងបែបបទជាក់ស្តែង
- រៀបចំចងក្រង នូវតម្លៃទំនិញប្រើប្រាស់ចាំបាច់សំខាន់ៗ នៅលើទីផ្សារក្នុងរាជធានីភ្នំពេញ និងតម្លៃទំនិញសំខាន់ៗ មួយចំនួនទៀតទូទាំង ២៥រាជធានីខេត្ត ប្រចាំសប្តាហ៍ ប្រចាំខែ ប្រចាំត្រីមាស និងប្រចាំឆមាស។ ក្រៅពីនោះក៏បានផ្សព្វផ្សាយព័ត៌មានទាំង នេះតាមរយៈ Website: www.moc.gov.kh និងFacebook: www.facebook.com/moc.gov.kh ព្រមទាំងផ្សាយតាមប្រព័ន្ធផ្សព្វផ្សាយ ទន្ទឹមនឹងនេះក៏បានផ្ញើព័ត៌មានទាំងនេះ ប្រចាំសប្តាហ៍សម្រាប់កិច្ចប្រជុំរបស់គណៈរដ្ឋមន្ត្រី
- ប្រមូលចងក្រងតម្លៃទំនិញប្រើប្រាស់សំខាន់ៗ លើទីផ្សារអន្តរជាតិបានមួយចំនួនដូចជាៈ តម្លៃប្រេងឆៅ ដែក លោហៈធាតុ គ្រាប់ធញ្ញជាតិ មានជាអាទិ៍ស្រូវ អង្ករ ពោត សណ្តែក ល្ង ជាដើម និង គ្រឿងឧបភោគបរិភោគអាហារសមុទ្រគ្រប់ប្រភេទ ព្រមទាំងរូបិយប័ណ្ណបរទេសមួយចំនួនទៀតដូចជាៈ ប្រាក់ដុល្លារអាមេរិក ប្រាក់បាតថៃ ដុងវៀតណាម ហ្វ្រង់ស្វីស យេនជប៉ុន។ល។ ដោយរៀបចំជាតារាងតម្លៃសម្រាប់ងាយស្រួលក្នុងការតាមដាន និងវិភាគព័ត៌មានទីផ្សារបរទេស
- តាមដានជាប្រចាំ ដោយបានស្រង់ទិន្នន័យស្ថិតិសំខាន់ៗ ពីបណ្តានាយកដ្ឋាន ពាក់ព័ន្ធហើយរៀបចំបែងចែក និងវិភាគតាមលក្ខណៈបច្ចេកទេសដោយបង្កលក្ខណៈងាយស្រួលដល់ការទាញយកមកប្រើប្រាស់តាមតម្រូវការរបស់អ្នកសិក្សាស្រាវជ្រាវ និងអតិថិជន
- អភិវឌ្ឍន៍គេហទំព័រ (Website: www.moc.gov.kh) ឲ្យកាន់តែមានសារៈសំខាន់ដោយចងក្រងព័ត៌មានទាំងអស់ដែលទាក់ទងនឹងវិស័យពាណិជ្ជកម្ម ដើម្បីដាក់បញ្ចូលទៅក្នុងគេហទំព័រ (Website) របស់ក្រសួងឲ្យបានច្រើនដូចជាៈ ការបង្កើតក្រុមហ៊ុនថ្មី ការកែប្រែលក្ខន្តិកៈក្រុមហ៊ុន ការបង្កើតសាខាក្រុមហ៊ុនក្នុងស្រុក ការបង្កើតសាខាក្រុមហ៊ុនបរទេស និងការរំលាយក្រុមហ៊ុន និងច្បាប់ព្រមទាំងបទបញ្ញត្តិផ្សេងៗ រួមមានៈ ព្រះរាជក្រម ព្រះរាជក្រឹត្យ អនុក្រឹត្យប្រកាស សេចក្តីជូនដំណឹង សារាចរណែនាំជាដើម។ គេហទំព័ររបស់ក្រសួងត្រូវបានកែសម្រួល បង្កើនគុណភាពដោយរំលេចព័ត៌មានពាណិជ្ជកម្មទាន់ហេតុការណ៍ សម្រាប់តម្រូវការរបស់អតិជន
- រៀបចំសេចក្តីព្រាងប្រកាស ស្តីពីការបង្កើតគណៈកម្មការសម្របសម្រួល និងក្រុមការងារសម្រាប់ការអនុវត្តផែនការលើវេបសាយព័ត៌មានពាណិជ្ជកម្ម នៅក្រសួងពាណិជ្ជកម្ម-បានរៀបចំសេចក្តីព្រាងប្រកាស ស្តីពីការបង្កើតគណៈកម្មការសម្របសម្រួល និងក្រុមការងារសម្រាប់ចុះបំពេញបេសកកម្មនៅខេត្តមណ្ឌលគីរី, ស្ទឹងត្រែង, រតនៈគីរី, ក្រចេះ និងកំពង់ចាម ដើម្បីពិនិត្យឡើងវិញនៃការតម្លើង ICT តភ្ជាប់បណ្តាញ Network ជំនាញកុំព្យូទ័រ ពីក្រសួងពាណិជ្ជកម្មទៅតាមបណ្តាមន្ទីរពាណិជ្ជកម្មខេត្ត
- ស្រង់ថ្លៃទំនិញសំខាន់ៗ ១២មុខ ពីមន្ទីរពាណិជ្ជកម្មចំនួន ២៥ រាជធានី-ខេត្ត
- ប្រមូលព័ត៌មានពាណិជ្ជកម្មពី អគ្គនាយកដ្ឋាន នាយកដ្ឋាន មន្ទីរពាណិជ្ជកម្មរាជធានី-ខេត្ត ក្រុមហ៊ុនប្រ្កឹនត្រេដ និងព័ត៌មានពាណិជ្ជកម្មអន្តរជាតិ ពីវិស័យឯកជនផ្សេងទៀតយកមករៀបចំចង

ក្រុងបោះពុម្ពផ្សាយព្រឹត្តិបត្រ ព័ត៌មានពាណិជ្ជកម្ម ជារៀងរាល់ខែ ដោយកែសម្រួលទាំងខ្លឹមសារ ពិនិត្យអក្ខរាវិរុទ្ធនិងសោភ័ណ្ឌភាព ដើម្បីឲ្យព្រឹត្តិបត្រព័ត៌មានពាណិជ្ជកម្ម កាន់តែល្អប្រសើរឡើង និងសម្បូរបែបដោយព័ត៌មានពាណិជ្ជកម្មក្នុង និងក្រៅប្រទេស

- តាមដានព័ត៌មាន តម្លៃប្រេងនៅនៅលើទីផ្សារអន្តរជាតិ តម្លៃមាស តម្លៃកសិផលសំខាន់ៗ ផលិតផលនេសាទ ផលិតផលឧស្សាហកម្ម និងអត្រាប្តូរប្រាក់នៅលើទីផ្សារអន្តរជាតិចំពោះរូបិយវត្ថុសំខាន់ៗ សម្រាប់ការដោះដូរពាណិជ្ជកម្ម
- ផ្សព្វផ្សាយឈ្មោះក្រុមហ៊ុន ដែលបានចុះបញ្ជីពាណិជ្ជកម្ម ក្នុងប្រព័ន្ធទិន្នន័យរបស់គេហទំព័រក្រសួង (Database Website:www.moc.gov.kh) សម្រាប់ក្រុមហ៊ុនបង្កើតថ្មី ក្រុមហ៊ុនកែប្រែលក្ខន្តិកៈ ការបង្កើតសាខាក្នុងស្រុក សាខាក្រុមហ៊ុនបរទេស និងការរំលាយ ក្រុមហ៊ុនបានចំនួន ៤០៧២ក្រុមហ៊ុន
- ផ្សព្វផ្សាយអត្រាប្តូរប្រាក់ របាយការណ៍ក្រសួង សេចក្តីជូនដំណឹងផ្សេងៗ ប្រកាស អនុក្រឹត្យ ព្រះរាជក្រឹត្យ ព្រះរាជក្រម និងសកម្មភាពថ្នាក់ដឹកនាំក្រសួង ក្នុងគេហទំព័ររបស់ក្រសួងជាប្រចាំ។

## ២.៩ ការងារសហប្រតិបត្តិការអន្តរជាតិ និងគ្រប់គ្រងជំនួយ

### ២.៩.១ ការងារគ្រប់គ្រងជំនួយ

- ដាក់សម្ពោធជាផ្លូវការយុទ្ធសាស្ត្រសមាហរណកម្មពាណិជ្ជកម្មកម្ពុជាឆ្នាំ ២០១៩-២០១៨ (CTIS 2014-2018) ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ដែលជាឯកសារវិភាគវាយតម្លៃ ការអភិវឌ្ឍន៍វិស័យពាណិជ្ជកម្មនៅកម្ពុជា ដោយបានកំណត់ទិសដៅអភិវឌ្ឍន៍ធំៗចំនួន ៥ និងលទ្ធផលជាយុទ្ធសាស្ត្រចំនួន ២០ ក្នុងរយៈពេលប្រាំឆ្នាំ ស្របតាមយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាល និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិ ២០១៩-២០១៨
- រៀបចំកិច្ចប្រជុំពិគ្រោះយោបល់ ស្តីពីការគ្រប់គ្រងអភិក្រមគ្របដណ្តប់វិស័យពាណិជ្ជកម្មដែលគោលបំណងនៃកិច្ចប្រជុំនេះគឺ ពិនិត្យឡើងវិញនូវប្រសិទ្ធភាពនៃយន្តការគ្រប់គ្រង ចំណុចខ្លាំង ចំណុចខ្សោយ ក្នុងការអនុវត្តកម្មវិធីនេះ ដើម្បីផ្តល់អនុសាសន៍ដល់អនុគណៈកម្មាធិការអភិវឌ្ឍន៍ពាណិជ្ជកម្ម និងវិនិយោគទាក់ទងនឹងពាណិជ្ជកម្ម (SSC-TD-TRI) សម្រាប់ការកែទម្រង់
- រៀបចំកិច្ចប្រជុំអនុគណៈកម្មាធិការ អភិវឌ្ឍន៍ពាណិជ្ជកម្ម និងវិនិយោគទាក់ទងនឹងពាណិជ្ជកម្ម ដើម្បីពិនិត្យវឌ្ឍនភាពនៃការអនុវត្តគម្រោង ផ្តល់ការណែនាំសម្រាប់ការអនុវត្តបន្ត និងផ្តល់ដំណោះស្រាយដល់បញ្ហាប្រឈមផ្សេងៗ ព្រមទាំងស្តាប់នឹងអនុម័តចំពោះសំណើររបស់ភ្នាក់ងារអនុវត្តគម្រោង
- រៀបចំកិច្ចប្រជុំប្រចាំខែ របស់គណៈកម្មការអនុវត្តគម្រោង IC ដើម្បីតាមដានវឌ្ឍនភាព និងសម្របសម្រួលកិច្ចការផ្សេងៗ ទាក់ទងនឹងការអនុវត្តគម្រោងរបស់ភ្នាក់ងារអនុវត្តគម្រោងនិមួយៗ ហើយបានអនុម័តគម្រោងថ្មីចំនួន ៣ គឺគម្រោងស្វ័យប្រវត្តិកម្មការចុះបញ្ជីពាណិជ្ជកម្ម គម្រោងស្វ័យប្រវត្តិកម្មវិញ្ញាបនបត្រអនាម័យ និងភូតគាមអនាម័យ និងគម្រោងគាំទ្រវិទ្យាស្ថានស្រាវជ្រាវ និងបណ្តុះបណ្តាលពាណិជ្ជកម្ម
- ដាក់សម្ពោធឲ្យប្រើប្រាស់ជាផ្លូវការនូវ EIF Tier 2 for CEDEP II (Cambodia Export Diversification and Expansion Program) នៅថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០១៤

- រៀបចំសិក្ខាសាលារួមគ្នាជាមួយក្រសួងទេសចរណ៍ ស្តីពី «ជំនួយសម្រាប់ពាណិជ្ជកម្ម និងទេសចរណ៍កម្ពុជា: ការវាយតម្លៃ និងទិសដៅ» ប្រព្រឹត្តទៅនៅខែមិថុនា ឆ្នាំ២០១៤ នៅភ្នំពេញ
- កែសម្រួលផែនការសកម្មភាព និងផែនការថវិកាជំនួយ ព្រមទាំងផែនការកសាងសមត្ថភាពសម្រាប់ឆ្នាំ ២០១៣-២០១៥ ដែលប្រើប្រាស់ជំនួយពីដៃគូអភិវឌ្ឍន៍
- ទទួលបេសកកម្មត្រួតពិនិត្យ (Supervision Mission) ការអនុវត្តគម្រោង EIF Tier 1 និង EIF Tier 2 ដែលជាផ្នែកមួយនៃអភិបាលកិច្ចល្អក្នុងការគ្រប់គ្រងជំនួយអភិវឌ្ឍន៍ពាណិជ្ជកម្ម
- រៀបចំកិច្ចប្រជុំមន្ត្រី Liaison Officers និងមន្ត្រី Core Teams ក្នុងគោលបំណងផ្សព្វផ្សាយអំពីយុទ្ធសាស្ត្រ និងនីតិវិធីនៃការអនុវត្តន៍គម្រោង អំពី៖ i) Aid for Trade, ii) EIF Organization Structure, iii) Cambodia Institutional Framework, iv) CTIS v) TDSP និងvi) EIF។

### ២.៩.២ ការងារសហប្រតិបត្តិការកម្មសិទ្ធិបញ្ញា

- សហការជាមួយជំនាញការអង្គការកម្មសិទ្ធិបញ្ញាពិភពលោក (WIPO) និងសហគមន៍អឺរ៉ុបធ្វើស្វ័យប្រវត្តិកម្មការដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាក និងស្រាវជ្រាវម៉ាក
- រៀបចំកិច្ចប្រជុំក្រុមការងារអាស៊ានកម្មសិទ្ធិបញ្ញាលើកទី ៤៣ និងកិច្ចប្រជុំពាក់ព័ន្ធ នៅសៀមរាប ដោយមានការចូលរួម ពីអគ្គនាយកមកពីប្រទេសអាស៊ានទាំង១០ អង្គភាពកម្មសិទ្ធិបញ្ញាជប៉ុន (JPO) អង្គភាពកម្មសិទ្ធិបញ្ញាសហរដ្ឋអាមេរិក (USPTO) អង្គការពាណិជ្ជកម្មក្រៅប្រទេសជប៉ុន (JETRO) និងប្រធានអង្គភាពកម្មសិទ្ធិបញ្ញាសហគមន៍អឺរ៉ុប (OHIM/EPO) សរុបចំនួន ៥៩រូប
- ជួបពិភាក្សាជាមួយជំនាញការសហគមន៍អឺរ៉ុប (OHIM) ដើម្បីបង្កើតនីតិវិធីរួមអាស៊ានសម្រាប់ការត្រួតពិនិត្យម៉ាកលម្អិត
- រៀបចំឯកសារ និងនីតិវិធីសម្រាប់ការចុះហត្ថលេខា លើអនុស្សារណៈយោគយល់ស្តីពីសហប្រតិបត្តិការកម្មសិទ្ធិបញ្ញាកម្ពុជាជាមួយភាគីកូរ៉េ នៅថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១៤ នៅទីក្រុងសេអ៊ូល
- ជួបពិភាក្សាជាមួយអង្គភាពកម្មសិទ្ធិបញ្ញារដ្ឋ នៃសាធារណរដ្ឋប្រជាមានិតចិន (SIPO) ទាក់ទងនឹងការបន្តកិច្ចសហប្រតិបត្តិការ និងបានរៀបចំផែនការការងារសម្រាប់ឆ្នាំបន្តបន្ទាប់
- ចុះហត្ថលេខាលើអនុស្សរណៈសហប្រត្តិបត្តិការ ស្តីពីកម្មសិទ្ធិបញ្ញា នៅទីក្រុងតូក្យូ នាថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០១៤។

## ២.១០ ការងារជំរុញពាណិជ្ជកម្ម

### ២.១០.១ ការរៀបចំពិព័រណ៍ពាណិជ្ជកម្ម

- ចូលរួមពិព័រណ៍ក្រៅប្រទេសបានចំនួន ៣៨លើក
- រៀបចំ និងសម្របសម្រួលឱ្យមានព្រឹត្តិការណ៍ពិព័រណ៍ពាណិជ្ជកម្មមានចំនួន ៥៧លើក
- ចូលរួមប្រជុំកិច្ចការការិយាល័យពិព័រណ៍អន្តរជាតិ (BIE) ចំនួន ០៣លើក ដើម្បីពង្រីកទំនាក់ទំនងពាណិជ្ជកម្ម និងទីផ្សារ
- ដឹកនាំក្រុមហ៊ុនចំនួន ៧៦ក្រុមហ៊ុន ក្នុងនោះមានក្រុមហ៊ុនអង្ករចំនួន ១១ ទៅចូលរួមក្នុងការតាំងពិព័រណ៍ពាណិជ្ជកម្មចិន-អាស៊ានលើកទី១១ ឆ្នាំ២០១៤ ចាប់ពីថ្ងៃទី១៦-១៩ ខែកញ្ញា ឆ្នាំ២០១៤ នៅទីក្រុងណាននីង ប្រទេសចិន។

## ២.១០.២ ការងារពង្រីកដៃគូពាណិជ្ជកម្ម

- ដឹកនាំពាណិជ្ជករកម្ពុជាចូលរួមស្វែងរកដៃគូពាណិជ្ជកម្ម នាឱកាស Seoul Funiture & Home Living Fair 2014 ចូលរួមនៅទីក្រុងសេអូល ប្រទេសកូរ៉េ (ថ្ងៃទី២៤-២៧ ខែមេសា ឆ្នាំ២០១៤)
- ដឹកនាំអ្នកនាំចេញកម្ពុជាចូលរួមជំនួបពាណិជ្ជកម្ម នាឱកាសBusiness to Consommer Exhibition នៅទីក្រុងសេអូលប្រទេសកូរ៉េ (ថ្ងៃទី២៤ ខែមិនា ដល់ថ្ងៃទី០២ ខែមេសា ឆ្នាំ២០១៤)
- ដឹកនាំក្រុមហ៊ុនឯកជនចូលសិក្ខាសាលា ស្តីពី Korean Market Access Seminar on ASEAN Culture Agriculture Products នៅទីក្រុងសេអ៊ូល ប្រទេសកូរ៉េ (ថ្ងៃទី១៧-២០ ខែមីនា ឆ្នាំ២០១៤)
- ដឹកនាំពាណិជ្ជករកម្ពុជា (អ្នកនាំចេញគ្រឿងសង្ហារឹម) ចូលរួមជំនួបពាណិជ្ជកម្មនៅប្រទេសចិន នៅទីក្រុងឆុងជ័រ នៃតំបន់ស្វយ័តជនជាតិក្វាងស៊ីប្រទេសចិន (ថ្ងៃទី២៦-២៨ ខែមេសា ឆ្នាំ២០១៤)
- ចូលរួមការសម្របសម្រួលដឹកនាំពាណិជ្ជករកម្ពុជា ទៅចូលរួមជំនួបពាណិជ្ជកម្ម និងស្វែងរកដៃគូ និងទីផ្សារអង្ករ នៅទីក្រុងហុងកុង សាធារណរដ្ឋប្រជាមានិតចិន ក្រោមការរៀបចំ និងគាំទ្រដោយ Hong Kong Trade Development Council (HKTDC) នៅថ្ងៃទី១៣-១៦ ខែសីហា ឆ្នាំ២០១៤
- បន្តរួមសហការជាមួយដៃគូពាណិជ្ជកម្ម ក្នុងតំបន់ដូចជាមជ្ឈមណ្ឌលអាស៊ាន-ជប៉ុន មជ្ឈមណ្ឌលអាស៊ាន-កូរ៉េ វេទិកាជំរុញពាណិជ្ជកម្មអាស៊ីអាគ្នេយ៍ អង្គការ JETRO អង្គការ KOTRA ភ្នំពេញ និងក្រុមប្រឹក្សាពាណិជ្ជកម្ម និងអភិវឌ្ឍន៍ហុងកុងដើម្បីជំរុញពាណិជ្ជកម្ម និងវិនិយោគពីបរទេសមកកម្ពុជា និងជំរុញការនាំចេញផលិតផល និងសេវាកម្ម
- រៀបចំវេទិកា ស្តីពីការជំរុញពាណិជ្ជកម្ម និងវិនិយោគ និងជំនួបពាណិជ្ជកម្មនៅថ្ងៃទី១៧ និងថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០១៤ ដើម្បីជំរុញពាណិជ្ជកម្ម និងវិនិយោគកម្ពុជា-ចិន នាពិព័រណ៍ពាណិជ្ជកម្មចិន-អាស៊ានលើកទី១១ ឆ្នាំ២០១៤ នៅទីក្រុងណាននីង
- កំពុងរៀបចំអនុស្សារណៈយោគយល់គ្នាជាមួយ Evalliance Association ដែលមានទីតាំងនៅទីក្រុងប៉ារីស សម្រាប់ពិនិត្យចុះហត្ថលេខា ដើម្បីពង្រីកកិច្ចសហប្រតិបត្តិការជំរុញការនាំចេញផលិតផលសម្លៀកបំពាក់ពីកម្ពុជា
- រៀបចំកិច្ចប្រជុំគណៈកម្មាធិការពាណិជ្ជកម្មចម្រុះលើកទី១ កម្ពុជា-គូវ៉ែត កាលពីថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៤
- កំពុងរៀបចំបេសកកម្មពាណិជ្ជកម្ម រួមមានការតាំងពិព័រណ៍ កម្មវិធីផ្គូរផ្គងធុរៈជន និងសិក្ខាសាលាផ្សព្វផ្សាយអំពីពាណិជ្ជកម្ម នៅគូវ៉ែត នាចុងត្រីមាសទីបួន នៃឆ្នាំ២០១៤។

## ២.១០.៣ ការស្វែងរកទីផ្សារ

- ដំណើរផ្សព្វផ្សាយរបស់រដ្ឋមន្ត្រីសេដ្ឋកិច្ចអាស៊ានទៅកាន់ប្រទេសចិន ហុងកុង និងប្រទេស កាណាដា
- បេសកកម្មរួមគ្នារវាងទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម និងឯកអគ្គរដ្ឋទូតអាមេរិកប្រចាំនៅកម្ពុជា ទៅធ្វើការផ្សព្វផ្សាយ អំពីបរិយាកាសវិនិយោគនៅកម្ពុជា និងស្វែងរកទីផ្សារទំនិញសម្រាប់កម្ពុជា នៅសហរដ្ឋអាមេរិក កាលពីខែមិថុនា ឆ្នាំ២០១៤ ដោយបានជួបជាមួយធុរៈជន និងមន្ត្រីរដ្ឋាភិបាល សមាជិកសភា អ្នកវិនិយោគអាមេរិក និងសមាគមខ្មែរនៅសហរដ្ឋអាមេរិក
- បេសកកម្មរបស់ប្រតិភូក្រសួងពាណិជ្ជកម្មដឹកនាំដោយ ឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ទៅកាន់សាធារណរដ្ឋប្រជាមានិតចិន ដើម្បីចុះអនុស្សារណៈយោគយល់គ្នារវាងកម្ពុជា-ចិន សំដៅជំរុញការនាំចេញអង្ករចំនួន ១០ម៉ឺនតោន ទៅកាន់ទីផ្សារចិន និងចរចាដោះ

ស្រាយបញ្ហាអនាម័យ និងភូតគាមអនាម័យសម្រាប់ទំនិញកសិផលកម្ពុជាដូចជា៖ ពោត សណ្តែក ដំឡូងមី ស្វាយចន្ទី ចេក ទៅកាន់ទីផ្សារប្រទេសចិន

- អមដំណើរ **សម្តេចតេជោនាយករដ្ឋមន្ត្រី** ទៅកាន់សាធារណៈរដ្ឋបេឡារុស និងអាហ្សែបៃសាន់ ប្រកបដោយជោគជ័យ ក្នុងការស្វែងរកទីផ្សារទំនិញរបស់កម្ពុជា និងការពង្រីកពាណិជ្ជកម្មរវាងកម្ពុជា និងប្រទេសទាំងនេះ តាមរយៈការបង្កើតក្រុមការងារពាណិជ្ជកម្ម និងគណៈកម្មាធិការពាណិជ្ជកម្មរួម
- នៅក្នុងកិច្ចប្រជុំកំពូលអាស៊ាន នៅទីក្រុងណៃពីដោ ប្រទេសមីយ៉ាន់ម៉ាកាលពីខែសីហា បានជួបពិភាក្សាជាមួយរដ្ឋមន្ត្រីពាណិជ្ជកម្មរុស្ស៊ី ដើម្បីពិភាក្សាពីការលក់កសិផលកម្ពុជា ទៅកាន់ទីផ្សាររុស្ស៊ី ហើយឈានទៅដល់ការចុះអនុស្សរណៈយោគយល់គ្នាទៅវិញទៅមកក្នុងពេលឆាប់ៗ។

## ២.១០.៤ ការងារអភិវឌ្ឍន៍ទីផ្សារ

- រៀបចំជំនួបពាណិជ្ជកម្មរវាងកម្ពុជា-ចិន នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ២០១៤ មានអ្នកចូលរួម ២២៦ នាក់នៅសណ្ឋាគារសូហ្វីថេលភ្នំពេញ
- រៀបចំជំនួបស្វែងរកដៃគូពាណិជ្ជកម្មរវាង កម្ពុជា ចិន នៅសណ្ឋាគារណាហ្គាវើល មានអ្នកចូលរួម ៧៨នាក់
- រៀបចំសិក្ខាសាលា ស្តីពីទីផ្សារនាំចេញ និងការអភិវឌ្ឍន៍ការវេចខ្ចប់ ដល់សហគ្រាសធុនតូច និងមធ្យម នៅសណ្ឋាគារ អីនធ័រកុងទីណល់តាល់ រាជធានីភ្នំពេញ ដែលមានការចូលរួម ៨៥នាក់
- ចុះផ្សព្វផ្សាយអំពីនីតិវិធី នៃការប្រើប្រាស់ប្រព័ន្ធព័ត៌មានទីផ្សារអេឡិចត្រូនិច ដល់ទីផ្សារគោលដៅក្នុងខេត្តកំពង់ធំ សៀមរាប ពោធិ៍សាត់ បាត់ដំបង កំពង់ឆ្នាំង ប៉ៃលិន បន្ទាយមានជ័យ កំពត ព្រះសីហនុ តាកែវ កោះកុង កែប កំពង់ចាម ក្រចេះ ស្ទឹងត្រែង រតនគិរី មណ្ឌលគិរី ព្រៃវែង ស្វាយរៀង កំពង់ស្ពឺ ព្រះវិហារ និងខេត្តឧត្តរមានជ័យ
- ចុះធ្វើការសិក្សាថ្លៃដើមស្រូវ ពោត និងដំឡូងមី នៅខេត្តព្រៃវែង ស្វាយរៀង តាកែវ កំពត កំពង់ស្ពឺ កំពង់ឆ្នាំង ពោធិ៍សាត់ បាត់ដំបង បន្ទាយមានជ័យ សៀមរាប កំពង់ធំ កំពង់ចាម ក្រចេះ ព្រះវិហារ មណ្ឌលគិរី ស្ទឹងត្រែង រតនគិរី និងខេត្តប៉ៃលិន
- ចុះត្រួតពិនិត្យបរិមាណសន្និធិ និងណែនាំដល់ក្រុមហ៊ុននាំចូលប្រេងឥន្ធនៈ និងហ្គាសទាំងអស់ ហើយជំរុញឲ្យក្រុមហ៊ុនទាំងអស់ធ្វើសេចក្តីរាយការណ៍ និងនៅពេលមានការប្រែប្រួលថ្លៃលក់នៅលើទីផ្សារ
- រៀបចំលិខិតណែនាំទៅ ស្ថានតំណាងពាណិជ្ជកម្មអមស្ថានទូតប្រចាំបរទេស លើការជំរុញអូសទាញភ្ញៀវទេសចរណ៍ឲ្យមកកម្ពុជា
- រៀបចំជំនួបស្វែងរកដៃគូពាណិជ្ជកម្មរវាង កម្ពុជា ចិន នៅសណ្ឋាគារ ណាហ្គាវើល មានអ្នកចូលរួម ៧៨នាក់
- រៀបចំសិក្ខាសាលា ស្តីពីការអភិវឌ្ឍន៍ការវេចខ្ចប់ ដល់សហគ្រាសធុនតូចនិងមធ្យម នៅសណ្ឋាគារ អីនធ័រកុងទីណល់តាល់ រាជធានីភ្នំពេញ (Seminar on the Effective Utilization of Packaging Technology for the Cambodian Consumer Goods industry SME′s) មានការចូលរួម ៨៥នាក់
- រៀបចំលិខិតសុំផ្តល់ព័ត៌មានទាក់ទង និងផលិតផលកសិកម្មសម្រាប់នាំចេញទៅសហព័ន្ធរុស្ស៊ី

- ធ្វើការទំនាក់ទំនង ស្នើសុំសៀវភៅ និងផ្សព្វផ្សាយអំពីកម្ពុជា ទៅក្រសួងទេសចរណ៍ និងក្រុមប្រឹក្សាអភិវឌ្ឍន៍សេដ្ឋកិច្ច (CDC) ដើម្បីផ្ញើទៅទីប្រឹក្សាពាណិជ្ជកម្មអមស្ថានទូតប្រចាំនៅបរទេស
- រៀបចំឯកសាដើម្បីចុះតាមដានការអនុវត្តន៍ និងជំរុញការចុះលេខ បាកូដកម្ពុជា លើផលិតផលកម្ពុជា តាមបណ្តាខេត្ត និងរាជធានីភ្នំពេញ
- រៀបចំកិច្ចសម្របសម្រួល កម្មវិធីជួបពាណិជ្ជកម្មរវាង ក្រុមហ៊ុន Cast Laborotorice Pie មកពីសឹង្ហបូរី ជាមួយក្រុមហ៊ុនក្នុងស្រុកមួយចំនួន និងគណៈវិស្វករកម្ពុជា
- រៀបចំដាក់តាំងបង្ហាញផលិតផល ផ្លែឈើ និងបន្លែកម្ពុជា លើកទី៥ និងទី៦ប្រចាំឆ្នាំ២០១៤ នៅរាជធានីភ្នំពេញ និងខេត្តសៀមរាប ចប់សព្វគ្រប់
- ផ្តល់សេវា ពិគ្រោះយោបល់ ជាមួយប្រធានសមាគមស្វាយកំពង់ស្ពឺ ក្នុងការស្វែងរកដៃគូពាណិជ្ជកម្មនាំចេញស្វាយកែវរមៀត
- ផ្តល់សេវាពិគ្រោះយោបល់ ជាមួយប្រធានក្រុមហ៊ុន Winton Stock Feed និងសហការីក្នុងការស្វែងរកដៃគូពាណិជ្ជកម្ម នាំចេញស្ករអំពៅ និងវង្វេស្ករ
- សហការរៀបចំសិក្ខាសាលា ស្តីពី "The Export Promotion-Intellectual Property Protection and Marketing Strategy for Your Products " ជាមួយ"HKTDC"
- សហការរៀបចំសិក្ខាសាលា ស្តីពី "ភាពប៉ិនប្រសប់នៃការកែច្នៃផលិតផលភេសជ្ជៈ" និង "Beverage Processing Technique" ជាមួយ KOTRA
- សហការរៀបចំដំណើរទស្សនៈកិច្ចពាណិជ្ជកម្ម និងជំនួបពាណិជ្ជកម្មរបស់គណៈប្រតិភូខេត្តFujian ប្រទេសចិន ដឹកនាំដោយអភិបាលរងខេត្ត ដែលនឹងមកដល់កម្ពុជានៅថ្ងៃទី១២-១៤ ខែធ្នូ ឆ្នាំ២០១៤
- សហការរៀបចំជំនួបពាណិជ្ជកម្ម រវាងគណៈប្រតិភូពាណិជ្ជកម្មខេត្ត Tainjin ប្រទេសចិន ដែលនឹងមកដល់កម្ពុជានៅថ្ងៃទី១៥-១៦ ខែធ្នូ ឆ្នាំ២០១៤
- ចូលរួមក្នុងកិច្ចប្រជុំកម្រិតមន្ត្រីបច្ចេកទេស នៃសមាគមអង្គភាពជំរុញពាណិជ្ជកម្មនៅប្រទេសជប៉ុន
- ដឹកនាំពាណិជ្ជករកម្ពុជាចូលរួមស្វែងរកដៃគូពាណិជ្ជកម្ម នាឱកាស Seoul Funiture &Home Living Fair 2014 ចូលរួមនៅទីក្រុងសេអ៊ូលប្រទេសកូរ៉េ (ថ្ងៃទី២៤-២៧ មេសា ឆ្នាំ២០១៤)
- ដឹកនាំអ្នកនាំចេញកម្ពុជាចូលរួមជំនួបពាណិជ្ជកម្មនាឱកាស Business to Consommer Exhbition នៅទីក្រុងសេអ៊ូលប្រទេសកូរ៉េ (ថ្ងៃទី២៤ ខែមីនា ដល់ថ្ងៃទី០២ ខែមេសា ឆ្នាំ២០១៤)
- ដឹកនាំក្រុមហ៊ុនឯកជនចូលសិក្ខាសាលា ស្តីពី Korean Market Access Seminar on ASEAN Culture Agriculture Products នៅទីក្រុងសេអ៊ូល ប្រទេសកូរ៉េ (ថ្ងៃទី១៧-២០ ខែមីនា ឆ្នាំ២០១៤)
- ដឹកនាំពាណិជ្ជករកម្ពុជា (អ្នកនាំចេញគ្រឿងសង្ហារឹម) ចូលរួមជំនួបពាណិជ្ជកម្មនៅប្រទេសចិន នៅទីក្រុងឆុងជ័រ នៃតំបន់ស្វយ័តជនជាតិក្វាងស៊ីប្រទេសចិន (ថ្ងៃទី២៦-២៨ ខែមេសា ឆ្នាំ២០១៤)
- ចូលរួមការសម្របសម្រួលដឹកនាំពាណិជ្ជករកម្ពុជា ទៅចូលរួមជំនួបពាណិជ្ជកម្ម និងស្វែងរកដៃគូ និងទីផ្សារអង្ករ នៅទីក្រុងហុងកុង សាធារណរដ្ឋប្រជាមានិតចិន ចំនួន២លើក ក្រោមការរៀបចំ និងគាំទ្រដោយ Hong Kong Trade Development Council (HKTDC) នៅថ្ងៃទី១៣-១៦ ខែសីហា និងថ្ងៃទី៤-៧ ខែធ្នូ ឆ្នាំ២០១៤
- ដឹកនាំពាណិជ្ជករកម្ពុជា ទៅចូលរួមការតាំងបង្ហាញម្ហូបអាហារ និងរកទីផ្សារអង្ករ នៅទីក្រុងហុងកុង សាធារណរដ្ឋប្រជាមានិតចិន
- ចូលរួមបេសកកម្ម ស្វែងរកដៃគូផលិតផលជំឡូងមីនៅ ខេត្តក្វាងស៊ីសាធារណរដ្ឋប្រជាមានិតចិន

- រៀបចំ និងដឹកនាំក្រុមហ៊ុនឯកជនចូលរួមកម្មវិធី "Mekong Desing Selection 2014 " នៅទីក្រុងតូក្យូប្រទេសជប៉ុន ថ្ងៃទី១-៦ ខែវិច្ឆិកា ឆ្នាំ២០១៤
- រៀបចំ និងដឹកនាំក្រុមហ៊ុនឯកជន ឲ្យចូលរួមការដាក់តាំងបង្ហាញផលិតផលម្ហូបអាហារ និង ស្បៀងកម្ពុជា និងជំនួបពាណិជ្ជកម្ម រវាងកម្ពុជា-កូរ៉េ នៅទីក្រុងសេអ៊ូលសាធារណៈរដ្ឋកូរ៉េ ថ្ងៃទី៩-១៦ ខែវិច្ឆិកា ឆ្នាំ២០១៤
- សហការជាមួយសហព័ន្ធស្រូវ-អង្ករកម្ពុជា (CRF) រៀបចំពិធីបុណ្យអង្ករ និងសន្និសិទអង្ករពិភពលោក (World Rice Forum) នៅសណ្ឋាគារសូហ្វីតែល ថ្ងៃទី១៨-១៩ ខែវិច្ឆិកា ឆ្នាំ ២០១៤
- ចូលរួមកិច្ចប្រជុំ ស្តីពី "ការបង្កើតភាពជាដៃគូពាណិជ្ជកម្ម" 2nd India CLMV Business Conclave" Creating Business នៅសាធារណៈរដ្ឋឥណ្ឌា ថ្ងៃទី១១-១២ ខែធ្នូ ឆ្នាំ២០១៤។

## ២.១០.៥ ការងារអភិវឌ្ឍន៍ផលិតផល

- បន្តធ្វើបច្ចុប្បន្នភាពផលិតផលសក្តានុពល ១០មុខជំហានទី២ ដោយបានចុះប្រមូលទិន្នន័យ និងពិនិត្យដល់ទីតាំងផលិតកម្ម ក្នុងខេត្តចំនួន ១៥
- ចុះសិក្សា និងប្រមូលព័ត៌មានលម្អិត ស្តីពីការប្រឈម និងកត្តារាំងស្ទះមួយចំនួន ដែលកើតមានឡើងចំពោះអាជីវកម្មសូត្រនៅកម្ពុជាបានចំនួន ៦ខេត្ត គោលដៅក្នុងគោលបំណងបន្តនិរន្តរភាពលើកកម្ពស់ផលិតផលសូត្រ និងផលិតផលកែច្នៃពីសូត្រ
- ធ្វើការបោះពុម្ពផ្សព្វផ្សាយសៀវភៅសាវតារផលិតផលម្រេច និងកៅស៊ូ ដើម្បីចែកជូនពាណិជ្ជករ និងវិនិយោគិន ឲ្យមានការស្វែងយល់បានទូលំទូលាយពីចរន្តទីផ្សារសកល និងបានរៀបចំសិក្ខាសាលាផ្សព្វផ្សាយផលិតផលសក្តានុពលទាំងនោះនៅខេត្តកោះកុង
- ធ្វើការបោះពុម្ពផ្សព្វផ្សាយសៀវភៅមគ្គុទ្ទេសក៍ ស្តីពីនីតិវិធីនាំចេញចំនួន ១.០០០ច្បាប់ ហើយបានចែកជូន និងផ្សព្វផ្សាយដល់ពាណិជ្ជករ អាជីវករ និងអ្នកនាំចេញ នៅតាមខេត្តចំនួន ៥ តាមព្រំដែនខ្មែរ-ថៃ
- កំពុងសិក្សា និងចងក្រងឯកសារ អំពីផលិតផល និងម្ហូបអាហារហាឡាល់ ដើម្បីរៀបចំបញ្ញត្តិច្បាប់សំដៅគ្រប់គ្រងទីផ្សារក្នុងប្រទេស និងជំរុញការនាំចេញទៅក្រៅប្រទេស

## ២.១០.៦ ការអភិវឌ្ឍន៍ស្ថាប័នពាណិជ្ជកម្ម

- ចុះណែនាំអំពីផែនការសកម្មភាពពាណិជ្ជកម្មដល់មន្ទីរពាណិជ្ជកម្មរាជធានី ខេត្ត និងមណ្ឌលសភាពាណិជ្ជកម្មបានចំនួន ០៤ខេត្តគឺ ខេត្តសៀមរាប បន្ទាយមានជ័យ បាត់ដំបង និង ពោធិសាត់
- រៀបចំចាត់ចែងឲ្យមានការផ្តល់កិច្ចសំភាសន៍ និងការបង្ហាញពីទស្សនវិស័យពាណិជ្ជកម្ម និងទិសដៅការងារពាណិជ្ជកម្មរបស់ មន្ទីរពាណិជ្ជកម្មរាជធានី ខេត្ត សម្រាប់ការត្រៀមខ្លួនចូលក្នុងសហគមន៍សេដ្ឋកិច្ចអាស៊ានឆ្នាំ២០១៥ខាងមុខនេះ ដោយសហការជាមួយប្រព័ន្ធផ្សព្វផ្សាយ
- សិក្សាអំពីលទ្ធភាព នៃការបង្កើតសភាពាណិជ្ជកម្មសភាពាណិជ្ជកម្មខេត្តស្វាយរៀង និងខេត្តក្រចេះ-ស្ទឹងត្រែង-រតនគិរី ជាលទ្ធផលនៃការសិក្សាស្រាវជ្រាវ ក្រុមការងារបានរៀបចំបោះសភាពាណិជ្ជកម្មមណ្ឌលខេត្តក្រចេះ-ស្ទឹងត្រែង-រតនគិរី ចប់សព្វគ្រប់ ហើយក្រសួងកំពុងបន្តការស្នើសុំអនុក្រឹត្យទទួលស្គាល់សមាជិកដែលជាប់ឆ្នោតទាំងអស់ពីគណៈរដ្ឋមន្ត្រី

- រៀបចំបោះឆ្នោតជ្រើសរើសប្រធានដឹកនាំសម្រាប់អាណត្តិថ្មី សមាគមស្វាយចន្ទីក្នុងខេត្តកំពង់ធំ សមាគមម៉ាស៊ីនកិនស្រូវខេត្តកំពង់ស្ពឺ និងសមាគមអាជីវកម្មផ្សេងទៀត ក្នុងរាជធានីភ្នំពេញ សមាគមម្រេចក្នុងខេត្តកំពង់ចាម, កោះកុង, សមាគមជំឡូងក្នុងខេត្តបាត់ដំបង និងឧត្តរមានជ័យ
- សម្របសម្រួលជាមួយវិស័យឯកជន បង្កើតសហព័ន្ធស្រូវ-អង្ករកម្ពុជាកាលពីខែឧសភា ឆ្នាំ២០១៤ ដោយជោគជ័យ ដើម្បីជំរុញការនាំចេញអង្កររបស់កម្ពុជាអោយបានមួយលានតោន ក្នុងឆ្នាំ២០១៥ តាមអនុសាសន៍របស់ប្រមុខរាជរដ្ឋាភិបាល
- កំពុងចូលរួមរៀបចំមហាសន្និបាតសភាពាណិជ្ជកម្មទូទាំងប្រទេស និងជំរុញកិច្ចសហប្រតិបត្តិការ រវាងសភាពាណិជ្ជកម្មថ្នាក់ជាតិ អន្តរជាតិ។

## ២.១០.៧ ការងារអភិវឌ្ឍន៍គោលនយោបាយពាណិជ្ជកម្ម

- **ការងារគោលនយោបាយអភិវឌ្ឍន៍ផលិតផលហាឡាល់នៅកម្ពុជា**
  - អនុវត្តតាមអនុសាសន៍ណែនាំរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** និងស្រប តាមទស្សនទានក្នុងការ រៀបចំគោលនយោបាយសមស្រប ជំរុញឲ្យមាននូវការបង្កើន ផលិតកម្មថ្មីៗ ដើម្បីផលិតនូវផលិតផលសំបូរបែបសម្រាប់បំពេញ សេចក្តីត្រូវការក្នុងស្រុក និងជំរុញការនាំចេញទៅទីផ្សារអន្តរជាតិ ក្រសួងបានរៀបចំសេចក្តីព្រាងប្រកាស ស្តីពីការ បង្កើតក្រុមការងារបច្ចេកទេសហាឡាល់ ដែលមានសមាសភាពមន្ត្រីជំនាញអន្តរក្រសួង ដើម្បីអនុវត្តកិច្ចការហាឡាល់កម្ពុជា។ សេចក្តីព្រាងប្រកាសនេះ នឹងដាក់ជូនឯកឧត្តមទេស រដ្ឋមន្ត្រី ពិនិត្យនិងសម្រេចនាខែធ្នូ
  - រៀបចំកិច្ចប្រជុំជាមួយមន្ត្រីអន្តរក្រសួង ដើម្បីពិនិត្យលើ សេចក្តីព្រាងអនុក្រឹត្យ ស្តីពីការ អភិវឌ្ឍន៍ការងារហាឡាល់នៅកម្ពុជា។ សេចក្តីព្រាងអនុក្រឹត្យនេះនឹងដាក់ជូនគណៈរដ្ឋមន្ត្រី អនុម័តនាពេលឆាប់ៗនេះ

- **ការផ្សព្វផ្សាយគោលនយោបាយ**
  - ចាត់បញ្ជូនមន្ត្រីថ្នាក់ការិយាល័យ ទៅចូលរួមធ្វើបទឧទ្ទេសនាមក្នុងសិក្ខាសាលាថ្នាក់ក្រោម ជាតិ ស្តីពីវេទិការាជរដ្ឋាភិបាល-ផ្នែកឯកជននៅរាជធានី-ខេត្ត ចំនួន ៦ រួមមានៈ ខេត្តពោធិ៍សាត់ ខេត្តបាត់ដំបង ខេត្តបន្ទាយមានជ័យ ខេត្តសៀមរាប ខេត្តកំពង់ធំ និងខេត្តព្រៃវែង
  - ក្នុងន័យជួយជំរុញ និងលើកកម្ពស់ផលិតផលសូត្រ ជាពិសេសអ្នកផលិតសូត្រនៅតាមមូល ដ្ឋានសំខាន់ៗ បានស្វែងយល់ពីរចនាសម្ព័ន្ធផ្គត់ផ្គង់ និងការកសាងចង្វាក់តម្លៃបន្ថែមលើ ផលិតផលសូត្រ បានរៀបចំសម្របសម្រួលជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ និងក្រុមហ៊ុន នាំចេញផលិតផលសូត្រ ដើម្បីរៀបចំសិក្ខាសាលា ស្តីពីប្រព័ន្ធគាំពារពាណិជ្ជកម្ម និងការ តភ្ជាប់ទំនាក់ទំនង រវាងគ្រប់ដៃគូពាក់ព័ន្ធ នឹងវិស័យសូត្រ ដែលនឹងគ្រោងធ្វើឡើងនាពាក់ កណ្តាលខែធ្នូ ខាងមុខនេះ

- ការចូលរួមសន្និសីទអន្តរជាតិ ស្តីពីគោលនយោបាយរបៀង អភិវឌ្ឍន៍សេដ្ឋកិច្ច ណាននីង-សឹង្ហបុរី និងសន្និសីទ ស្តីពីការអភិវឌ្ឍន៍ពាណិជ្ជកម្មរវាង កម្ពុជា-ឡាវ-មីយ៉ាន់ម៉ា និងចិន

- ➢ ចូលរួម កិច្ចពិភាក្សាពិគ្រោះយោបល់តុមូល លើប្រធានបទរបៀងអភិវឌ្ឍន៍សេដ្ឋកិច្ច Nanning-Singapore នៅទីក្រុងណាននីងប្រទេសចិន នាថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១៤។ កិច្ចពិភាក្សាតុមូលបានឯកភាពដូចខាងក្រោមៈ

ក. របៀងអភិវឌ្ឍន៍នេះផ្តល់សារៈសំខាន់ ដល់ការតភ្ជាប់ទីក្រុងណាននីងរបស់ប្រទេសចិនមកកាន់តំបន់អាស៊ានទាំងមូល តាមការតភ្ជាប់ផ្លូវដឹកជញ្ជូនតាមផ្លូវគោក-ផ្លូវដែក-ផ្លូវសមុទ្រពីប្រទេសចិន-វៀតណាម-កម្ពុជា-ឡាវ-ថៃ-ម៉ាឡេស៊ីនិងសឹង្ហបុរី

ខ. គួររកប្រភពធនធានហិរញ្ញវត្ថុដើម្បីជួយកសាងផ្លូវ Missing Ling ក្នុងប្រទេសអភិវឌ្ឍតិចតួច

គ. Corridor នេះនឹងផ្តល់ផលប្រយោជន៍មិនត្រឹមតែលើការដឹកជញ្ជូនប៉ុណ្ណោះទេ តែថែមទាំងផ្តល់ ប្រយោជន៍ដល់ការពង្រីកសកម្មភាពពាណិជ្ជកម្ម វិនិយោគទេសចរណ៍រវាងអាស៊ាន និងចិនផងដែរ

- ➢ សម្របសម្រួលជាមួយវិស័យឯកជន និងមន្ត្រីក្រសួងពាក់ព័ន្ធ ទៅចូលរួមសន្និសីទ អំពី "ការអភិវឌ្ឍពាណិជ្ជកម្មរវាងប្រទេសកម្ពុជា-ឡាវ-មីយ៉ាន់ម៉ា និងចិន នាថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០១៤។ សន្និសីទនេះបានផ្តោតសំខាន់ទៅលើឧបសគ្គនានា ក្នុងការនាំចេញផលិតផលកសិកម្មទៅកាន់ប្រទេសចិនរួមមានៈ

ក. រនាំងបច្ចេកទេសមិនមែនពន្ធគយ រួមមានអនាម័យ ភូតគាមអនាម័យ និងស្តង់ដារបែបបទពន្ធគយ គួរបន្ធូរបន្ថយរវាងភាគីចិន ចំពោះផលិតផលកសិកម្មរបស់កម្ពុជា ឡាវ និងមីយ៉ាន់ម៉ា

ខ. ប្រទេសកម្ពុជា ឡាវ និងមីយ៉ាន់ម៉ា គួរពង្រឹងខ្សែចង្វាក់នៃការផ្គត់ផ្គង់របស់ខ្លួនដើម្បីអាចឲ្យផលិតផលរបស់ខ្លួន ធ្វើការនាំចេញបានទៅកាន់ប្រទេសចិន

គ. ប្រទេសសមាជិកអាស៊ានថ្មីទាំងបី គួរខិតខំបំពេញឲ្យបាននូវវិធានប្រភពដើមទំនិញដើម្បីទទួលផលប្រយោជន៍ពេញលេញលើកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ាន-ចិន

ឃ. ធ្វើឲ្យភាគីចិនមកបណ្តាក់ទុនវិនិយោគនៅក្នុងប្រទេសអាស៊ានថ្មីទាំងបី ជាពិសេសលើការច្នៃផលិតផលកសិកម្ម

- ➢ ចាត់បញ្ជូនមន្ត្រីថ្នាក់ការិយាល័យទៅចូលរួមសន្និសីទ ស្តីពីគោលនយោបាយ ជំរុញការនាំចេញផលិតផលម្រេច ឆ្នាំ២០១៤ នៅទីក្រុងហូជីមិញ ប្រទេសវៀតណាមផងដែរ។

## ២.១១ ការងារត្រួតពិនិត្យ បង្ក្រាបការក្លែងបន្លំ និងការពារអ្នកប្រើប្រាស់

### ២.១១.១ ការពង្រឹងប្រសិទ្ធភាពនៃការត្រួតពិនិត្យការនាំចេញ-នាំចូល តាមច្រកព្រំដែន

- រកឃើញ និងរឹបអូសយកមកកម្ទេចចោលនូវផលិតផលម្ហូបអាហារគ្មានសុវត្ថិភាពចំនួន ៦.១៣៨គីឡូក្រាម
- សហការទប់ស្កាត់ការធ្វើចរាចរសារធាតុញៀនបានចំនួន ០៦ករណី ដោយឃាត់ខ្លួនជនល្មើសចំនួន ០៦នាក់ និងរឹបអូសសារធាតុញៀនចំនួន ២០,៥៦៦គីឡូក្រាម
- រកឃើញការនាំចូលផលិតផលសម្លៀកបំពាក់សម្រេច (PULLOVER) ដែលបន្លំថាជាផ្ទាំងក្រណាត់ចំនួន ១៩.៣៣៥អាវ និងបានផាកពិន័យជាប្រាក់ចំនួន ១០.០០០ ដុល្លារអាមេរិកបង់ចូលថវិកាជាតិ
- សហការជាមួយសមត្ថកិច្ចពាក់ព័ន្ធ រកឃើញករណីនាំចូលភ្លុកដំរីចំនួន ១០៨ដុំ ស្មើ ៨.០០៨,៨០ គីឡូក្រាម
- សិក្សាតួនាទីរបស់អគ្គនាយកដ្ឋានកាំកុងត្រូល អំពីសុវត្ថិភាពចំណីអាហារ និងកិច្ចការពារអ្នកប្រើប្រាស់

### ២.១១.២ ពង្រឹងប្រសិទ្ធភាពនៃការឃ្លាំមើលពិនិត្យទីផ្សារ ទប់ស្កាត់គ្រោះថ្នាក់សុខមាលភាព សុវត្ថិភាពអ្នកប្រើប្រាស់ ពាក់ព័ន្ធនឹងផលិតផល

កម្មវិធីឃ្លាំពិនិត្យទីផ្សាររួមមាន ការធ្វើអង្កេតលើការប្រើប្រាស់សារធាតុគីមីហាមឃាត់ និងសារធាតុគីមីបន្ថែមក្នុងម្ហូបអាហារ វត្តមានមីក្រូជីវសាស្ត្រដែលបណ្តាលអោយពុល និងការធ្វើអង្កេតលើមេតាណុលក្នុងស្រា។ ជាលទ្ធផលបានឃ្លាំពិនិត្យទីផ្សារចំនួន ១.០៥៥ លើកនៅទូទាំងប្រទេស ដកហូតទំនិញដែលមានភាពមិនប្រក្រតី (ទំនិញក្លែងក្លាយ, ខូចគុណភាព, ផុតកំណត់រយៈពេលប្រើប្រាស់ ។ល។) សរុបប្រមាណ ៣.១៧៨ គីឡូក្រាម មកកំទេចចោល។

ការត្រួតពិនិត្យសិប្បកម្មកែច្នៃម្ហូបអាហារ រួមមានការត្រួតពិនិត្យដល់គ្រឹះស្ថានផលិត និងបណ្តាឃ្លាំងស្តុកទំនិញ ដោយអនុវត្តតាមការវាយតម្លៃគ្រោះ ដែលធ្វើឡើងដោយក្រុមគ្រប់គ្រងហានិភ័យ ដោយមានផលិតផលជាក់លាក់ ជាមូលដ្ឋានសម្រាប់អនុវត្តកម្មវិធីឃ្លាំពិនិត្យទីផ្សារ។ ក្នុងនោះបានចុះត្រួតពិនិត្យសិប្បកម្មផលិត អំបិលបានចំនួន ២៩លើក នៅខេត្តកំពត និងខេត្តកែប ដោយដកហូតអំបិលចំនួន ៧.៥៦៧ គីឡូក្រាម ប្រគល់ឲ្យសហគមន៍អ្នកផលិតអំបិល ដើម្បីពិនិត្យ និងបញ្ចូលសារធាតុអ៊ីយ៉ូដតាមបទដ្ឋានកំណត់ឡើងវិញ និងចុះត្រួតពិនិត្យសិប្បកម្មផលិតទឹកបរិសុទ្ធចំនួន ០២ កន្លែង នៅខេត្តបន្ទាយមានជ័យដោយផ្អាកមិនឲ្យដំណើរការផលិតជាបណ្តោះអាសន្ន ក្រោយពីបានត្រួតពិនិត្យឃើញ សិប្បកម្មទាំងនេះគ្មានច្បាប់អនុញ្ញាតផលិត ហើយខ្វះអនាម័យសមស្រប។

### ២.១១.៣ ពង្រឹងស្ថាប័នធ្វើឱ្យប្រសើរ និងមានប្រសិទ្ធភាពចំពោះកិច្ចការពារអ្នកប្រើប្រាស់

ជំរុញឲ្យមានការឃោសនាផ្សាយពាណិជ្ជកម្មមិនភូតកុហក ឬនាំឲ្យមានការភ័ន្តច្រឡំតាមប្រព័ន្ធផ្សព្វផ្សាយ ដោយអញ្ជើញតំណាងម្ចាស់ផលិតផលចំនួន ០៩ក្រុមហ៊ុន ដើម្បីធ្វើការណែនាំ និងកែសម្រួលខ្លឹមសារអត្ថបទផ្សព្វផ្សាយ៖

- បានបិទផ្ទាំងរូបភាពផ្សព្វផ្សាយ (Posters) អំពីរបៀបពិនិត្យស្លាកសញ្ញាផលិតផលម្ហូបអាហារដែលមានសុវត្ថិភាព នៅតាមទីផ្សារ និងទីសាធារណៈ បានចំនួន ៣០.៦០០ផ្ទាំង
- បង្កើតខិតប័ណ្ណថ្មីស្តីពី ការយល់ដឹងពីការទិញម្ហូបអាហារ សុវត្ថិភាពម្ហូបអាហារ ភេសជ្ជៈគ្រឿងស្រវឹង និងការផ្សាយពាណិជ្ជកម្មទំនិញ។

### ២.១១.៤ លើកកម្ពស់ការយល់ដឹងសាធារណៈ

- បានចុះអប់រំផ្សព្វផ្សាយ អំពីគុណភាព សុវត្ថិភាពម្ហូបអាហារ និងផលប៉ះពាល់ដល់អាជីវករនៅតាមទីផ្សារបានចំនួន ៩៨៣លើក ដោយមានអាជីវករចូលរួមប្រមាណ ១៩.៥០០នាក់
- បានចុះអប់រំផ្សព្វផ្សាយ អំពីគុណភាព សុវត្ថិភាពម្ហូបអាហារ និងផលប៉ះពាល់ដែលបណ្តាលមកពីការប្រើប្រាស់គ្រឿងញៀននៅតាមវិទ្យាល័យ និងមហាវិទ្យាល័យបានចំនួន ១៥លើក ដោយមានសិស្សានុសិស្ស-និស្សិត លោកគ្រូ-អ្នកគ្រូ និងសាស្ត្រាចារ្យចូលរួមចំនួន ៩.១៦២នាក់។

### ២.១១.៥ ទប់ស្កាត់ការក្លែងបន្លំ

- បានសហការជាមួយស្ថាប័នពាក់ព័ន្ធ ចុះត្រួតពិនិត្យនិងបង្ក្រាបករណីចរាចរផលិតផលក្លែងបន្លំម៉ាកសញ្ញា ០៥ករណី, រំលោភសិទ្ធិចែកចាយផ្តាច់មុខ ០១ ករណី ផលិតផលគ្មានច្បាប់អនុញ្ញាតឲ្យចរាចរ ០១ករណី និងធ្វើតេស្តិ៍សាកល្បងលើជញ្ជីងលក់ក្តាមនៅខេត្តកំពត និងខេត្តកែប ចំនួន ១១៨ជញ្ជីង រកឃើញ ជញ្ជីងចំនួន១៧ មានកម្រិតលំអៀងពី ២០០ក្រាម ទៅ ៧០០ក្រាម លើទម្ងន់ ២.០០០ក្រាម
- ឃាត់ចាប់យកមកកម្ទេចចោលប្រអប់ដាក់ម្សៅ និងឡេលាបស្បែកមានម៉ាកត្រឹមត្រូវដែលប្រើរួចចំនួន ២.៣៣៦ប្រអប់ ហើយមានបំណាងទុកច្រកផលិតផលលាយផ្សំខ្លួនឯង
- ចុះត្រួតពិនិត្យទីផ្សារគ្រប់បណ្តារាជធានី-ខេត្ត ដើម្បីស្វែងរកវត្តមានប្រេងឆាផលិតនៅកោះតៃវ៉ាន់ដោយក្រុមហ៊ុន Chang Guann Co.,Ltd ដែលត្រូវបានស្ថាប័នមានសមត្ថកិច្ចកោះតៃវ៉ាន់ រកឃើញថាផលិតដោយចាក់លាយប្រេងឆាប្រើប្រាស់រួចកែច្នៃឡើងវិញឬលាយខ្លាញ់ជ្រូក។ ជាលទ្ធផលពុំមានការនាំចូលផលិតផលរបស់ក្រុមហ៊ុននេះមកកម្ពុជាទេ
- ចុះត្រួតពិនិត្យបណ្តាស្ថានីយ៍ចែកចាយប្រេងឥន្ធនៈចំនួន ៤៣ស្ថានីយ៍ ដើម្បីរកអនុលោមភាពកម្រិតអុកតាន និងរង្វាស់រង្វាល់ ដើម្បីបញ្ជាក់បរិមាណជាក់ស្តែង។

### ២.១១.៦ បញ្ជរទំនាក់ទំនងអំពីអនាម័យ និងភូតគាមអនាម័យ (SPS Enquiry Points)

- ស្រាវជ្រាវ និងពិនិត្យការជូនដំណឹងអំពីអនាម័យ និងភូតគាមអនាម័យបានចំនួន ៤២៧ករណី (ផ្នែកសុវត្ថិភាពផលិតផលម្ហូបអាហារចំនួន ៣០៩ករណី ផ្នែកកិច្ចការពារដំណាំចំនួន ៦៧ ករណី និងផ្នែកកិច្ចការពារសុខភាពសត្វចំនួន ៥១ករណី) ពី២៥ប្រទេស និងតាមដានព្រឹត្តិការណ៍ស្តីពីសុវត្ថិភាពផលិតផលម្ហូបអាហារ ដែលកើតមាននៅប្រទេសនានាបានចំនួន ០៧ករណី ដូចជាករណីផលិតផលចាហួយចានផលិតនៅសិង្ហបូរីដែលមានសារធាតុគីមីបន្ថែម E407 Carrageena ដែលមិនអនុញ្ញាត្តិឲ្យប្រើប្រាស់នៅក្នុងផលិតផលម្ហូបអាហារ និងសារធាតុមេតាណុលដែលលើកកម្រិតអនុញ្ញាតក្នុងផលិតផលស្រា
- តាមដានចំណាត់ការអាជ្ញាធរសុវត្ថិភាពម្ហូបអាហារអ៊ីតាលី ដែលបញ្ជូនត្រឡប់មកវិញនូវអង្ករ Basmati របស់ឥណ្ឌា បន្ទាប់ពីរកឃើញសំណល់ថ្នាំគីមីកសិកម្ម Carbendazim លើសពីកម្រិតកំណត់
- តាមដានចំណាត់ការអាជ្ញាធរសុវត្ថិភាពម្ហូបអាហារប៊ែលហ្ស៊ិក ដែលកម្ទេចចោល និងហាមនាំចូលបន្លែសណ្តែកគួរ (Yardlong Beans) និងស្លឹកគួយឆាយ (Fresh Celery) របស់កម្ពុជាបន្ទាប់ពីរកឃើញសំណល់ថ្នាំគីមីកសិកម្មលើសកម្រិតកំណត់
- តាមដានសេចក្តីជូនដំណឹងរបស់ក្រុមហ៊ុន Solgar,Inc., of Leonia, NJ និង SOLGAR UK LTD អំពីការប្រមូលមកវិញ ពីទីផ្សារនៅសហរដ្ឋអាមេរិក ចក្រភពអង់គ្លេស និងទូទាំងពិភពលោកនូវផលិតផលម្ហូបអាហារបំប៉ន ABC Dophilus® Powder និង Solgar ABC Dophilus ™ Powder សម្រាប់ទារក និងកុមារ ដោយសារមានវត្តមានផ្សិត Rhizopus oryzae នៅក្នុងផលិតផលនេះ ដែលបណ្តាលឲ្យទារកម្នាក់ស្លាប់។

### ២.១១.៧ ការងារពាក់ព័ន្ធ ACCSQ, ATFC, ARASFF, ARASCP, ACOST, ACCP

- ចូលរួមទៅក្នុងក្រុមការងារ Prepared Foodstuff Product Working Group (PFPWG) របស់គណៈកម្មការACCSQ ដើម្បីរៀបចំឲ្យមានសុខដុមនីយកម្មក្នុងវិស័យស្តង់ដារបទប្បញ្ញត្តបច្ចេកទេស និងនិតិវិធីវាយតម្លៃអនុលោមភាព
- ចូលរួមអនុវត្តន៍ប្រព័ន្ធផ្តល់ចម្លើយទាន់ហេតុការណ៍ ស្តីពីផលិតផលម្ហូបអាហារ និងចំណីសត្វក្នុងក្របខណ្ឌអាស៊ាន ដោយដើរតួនាទីជាចំណុចទំនាក់ទំនងថ្នាក់ជាតិក្នុងកិច្ចការ ARASFF (ASEAN Rapid Alert System for Food and Feed)
- ចូលរួមក្នុងគណៈកម្មាធិការកិច្ចការការពារអ្នកប្រើប្រាស់របស់អាស៊ាន ASEAN Committee on Consumer Protection (ACCP) ដោយបំពេញតួនាទីជា ចំណុចបង្គោលថ្នាក់ជាតិ សម្រាប់អនុវត្តតាមដានចាត់ចែង និងបង្កើតយន្តការដើម្បីអភិវឌ្ឍន៍កិច្ចការការពារអ្នកប្រើប្រាស់។

### ២.១១.៨ ការងារគណៈកម្មាធិការអន្តរក្រសួងសម្របសម្រួលការត្រួតពិនិត្យគុណភាពសុវត្ថិភាពផលិតផល និងសេវា និងគណៈកម្មាធិការកូដិចជាតិ

- ព្រាងប្រកាសធ្វើបច្ចុប្បន្នភាពកែសម្រួល សមាសភាពគណៈកម្មាធិការអន្តរក្រសួងសម្របសម្រួលការត្រួតពិនិត្យគុណភាពសុវត្ថិភាពផលិតផល និងសេវា និងគណៈកម្មាធិការកូដិចជាតិ និងការកំណត់នូវភារកិច្ចលំអិត ដើម្បីមានសមត្ថភាពធ្វើសមាហរណកម្មក្នុងតំបន់ និងពិភពលោក
- ទទួលសេចក្តីជូនដំណឹង គណៈកម្មាធិការកូដិចដែលសម្រេច កំណត់កម្រិតអតិបរិមា បរិមាណសារធាតុអសរីរាង្គ លោហធាតុធ្ងន់អាសេនិចនៅក្នុងអង្ករសំរិតត្រឹម ០.២ មីលីក្រាមក្នុង ១ គីឡូក្រាមអង្ករសំរិត (Max. Inorganic Arsenic in Polished Rice = 0.2mg/Kg)។

### ២.១១.៩ ការកសាងច្បាប់ និងបទប្បញ្ញត្តិបច្ចេកទេស

- កំពុងរៀបចំសេចក្តីព្រាងច្បាប់ស្តីពីម្ហូបអាហារ និងសេចក្តីព្រាងច្បាប់ស្តីពីកិច្ចការពារអ្នកប្រើប្រាស់
- កំពុងរៀបចំសេចក្តីព្រាងបញ្ញត្តិបច្ចេកទេស អំពីការនាំចូលផលិតផលម្ហូបអាហារ និងការប្រមូលត្រលប់មកវិញនូវម្ហូបអាហារដែលមានគ្រោះថ្នាក់ (Food Recall)
- បន្តការស្រាវជ្រាវ និងធ្វើបច្ចុប្បន្នភាព កម្រងព័ត៌មានហានិភ័យ បង្កដោយផលិតផលម្ហូបអាហារ ដើម្បីកំណត់វិធានការត្រួតពិនិត្យការនាំចូល និងឃ្លាំពិនិត្យទីផ្សារ ព្រមទាំងវាយតម្លៃហានិភ័យលើប្រភេទម្ហូបអាហារកំប៉ុង ផលិតផលទឹកដោះគោ ផលិតផលទឹកពិសារ និងផលិតផលប្រេងឥន្ធនៈមួយចំនួន។

### ២.១១.១០ ការងារមន្ទីរពិសោធន៍

- កសាងនីតិវិធី សម្រាប់វិភាគរកប៉ារ៉ាម៉ែត្រគុណភាព សុវត្ថិភាពម្ហូបអាហារ ផលិតផលប្រេងឥន្ធនៈ និងនីតិវិធីប្រើប្រាស់ឧបករណ៍ពិសោធន៍
- ចូលរួមការធ្វើតេស្តក្នុងកម្មវិធីអន្តរមន្ទីរពិសោធន៍ជាលក្ខណៈអន្តរជាតិ ផ្នែកមីក្រូជីវសាស្ត្រចំនួន ២ ដង និងផ្នែកវិភាគលោហៈធាតុធ្ងន់ចំនួន ០១ដង

- ទទួលវិភាគ សារធាតុគីមីបន្ថែមក្នុងម្ហូបអាហារចំនួន ៩៩៨គំរូ សារធាតុចម្លងចំនួន ៤៩គំរូ មីក្រូជីវសាស្ត្រចំនួន ៧៨៨គំរូ រូបសាស្ត្រចំនួន ១៥០៣គំរូ គុណភាពប្រេងឥន្ធនៈចំនួន ៧៥២គំរូ និង វិភាគសារធាតុអាហារូបត្ថម្ភចំនួន ១២៣គំរូ។

## ២.១២ ការងារមន្ត្រី បណ្តុះបណ្តាល និងអភិវឌ្ឍន៍ធនធានមនុស្ស

ក្របខណ្ឌមន្ត្រីរាជការសរុបចំនួន ១.៦៨២ នាក់ ស្រីចំនួន ៥២៨នាក់រួមមាន៖

- រដ្ឋបាលកណ្តាល ចំនួន ១.១៨៧ នាក់ ស្រីចំនួន ៥២៨នាក់
- មន្ទីរពាណិជ្ជកម្មរាជធានី-ខេត្ត ចំនួន ៥៥៨ នាក់ ស្រីចំនួន ១៥៨នាក់
- ក្របខណ្ឌ មុខងារសាធារណៈ ចំនួន ១.៦៦៧នាក់
- ក្របខណ្ឌ មិនមែនមុខងារសាធារណៈ ចំនួន ២៥នាក់
- ប្រភេទក្របខណ្ឌ"ក" ចំនួន ១.២៨១នាក់ ក្របខណ្ឌ"ខ"ចំនួន ១០០នាក់ ក្របខណ្ឌ"គ" ចំនួន ៣៣នាក់ និងក្របខណ្ឌ"ឃ" ចំនួន ១៨៣នាក់
- ដោយឡែកជនពិការមានចំនួន ២៦នាក់ ស្រីចំនួន ៥នាក់ គិតជាភាគរយចំនួន១.៦%នៃមន្ត្រីសរុប
- បញ្ចប់ការធ្វើនិយ័តកម្មថ្នាក់ និងដំឡើងថ្នាក់ប្រចាំឆ្នាំជូនមន្ត្រីរាជការសរុបចំនួន ៦៦២នាក់ ក្នុងនោះមាន ក្របខណ្ឌរដ្ឋបាលចំនួន ២០១នាក់ និងក្របខណ្ឌបច្ចេកទេសចំនួន ៤៦១នាក់
- បានដំឡើងថ្នាក់ប្រចាំឆ្នាំជូនមន្ត្រីរាជការចំនួន ២៧១នាក់ ក្នុងនោះមាន ឡើងថ្នាក់តាមសញ្ញាប័ត្រ មានចំនួន ៥៤នាក់
- ដំឡើងកម្រិតនៃប្រាក់បំណាច់មុខងារ ជូនមន្ត្រីរាជការចំនួន ៣០៥នាក់ (ថ្នាក់រដ្ឋបាលកណ្តាល ចំនួន ២៥២នាក់ និងថ្នាក់រាជធានី ខេត្ត ចំនួន ៦៣នាក់)
- រៀបចំធ្វើការប្រឡងប្រជែងផ្ទៃក្នុង សម្រាប់ការផ្លាស់ប្តូរប្រភេទ ក្របខ័ណ្ឌមន្ត្រីចំនួន ៨២កន្លែង
- រៀបចំបច្ចុប្បន្នភាពបញ្ជីគ្រប់គ្រងមន្ត្រីរាជការថ្នាក់កណ្តាល រាជធានី-ខេត្ត
- ធ្វើសេចក្តីជូនដំណឹង ស្តីពីមន្ត្រីរាជការដែលត្រូវចូលនិវត្តន៍ឆ្នាំ២០១៥ មានចំនួន ៣៥នាក់ ជូនទៅគ្រប់អង្គភាព
- បាន និងកំពុងធ្វើប័ណ្ណសំគាល់មន្ត្រីរាជការរបស់ក្រសួងពាណិជ្ជកម្ម
- ក្រសួងបានស្នើសុំគ្រឿងឥស្សរិយយសជូនមន្ត្រីរាជការក្រសួងពាណិជ្ជកម្ម ដែលមានស្នាដៃល្អក្នុងការបំពេញការងារក្នុងឆ្នាំ២០១៣ កន្លងមកចំនួន ២៦៣គ្រឿង រហូតមកដល់ពេលនេះពុំទាន់ទទួលបានការឯកភាពពីប្រមុខរាជរដ្ឋាភិបាលនៅឡើយ
- ចេញប្រកាស ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់នាយកដ្ឋានថ្មីចំនួន ៩ ក៏ដូចជាបានកែសម្រួលតួនាទីភារៈកិច្ចនាយកដ្ឋានចាស់ចំនួន ៧ ឲ្យសមស្របទៅតាមអនុក្រឹត្យ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងពាណិជ្ជកម្ម។

តែងតាំង និងសម្រួលភារកិច្ចជូនមន្ត្រីរាជការដោយព្រះរាជក្រឹត្យ អនុក្រឹត្យ និងប្រកាសសរុប ចំនួន ៤៧០រូប (ថ្នាក់រដ្ឋបាលកណ្តាលចំនួន ៤៥៨រូប ថ្នាក់រាជធានីខេត្តចំនួន ១២រូប) រួមមាន៖

## ក. តែងតាំង

- ថ្នាក់អគ្គនាយកចំនួន ០២រូប ថ្នាក់អគ្គាធិការស្តីទីចំនួន ០១រូប អគ្គនាយករងចំនួន ១៣រូប ប្រធាននាយកដ្ឋានចំនួន ១២រូប ប្រធាននាយកដ្ឋានស្តីទីចំនួន ០៥រូប អនុប្រធាននាយកដ្ឋានចំនួន ២៥រូប ថ្នាក់ប្រធានការិយាល័យចំនួន ១៨រូប និងថ្នាក់អនុប្រធានការិយាល័យចំនួន ៥៨រូប
- ទីប្រឹក្សា និងជំនួយការក្រសួងថ្នាក់ស្មើរដ្ឋលេខាធិការចំនួន ០៣រូប ថ្នាក់ស្មើអនុរដ្ឋលេខាធិការចំនួន ១០រូប ថ្នាក់ស្មើអគ្គនាយកចំនួន ០៣រូប ថ្នាក់ស្មើអគ្គនាយករងចំនួន ០១រូប ថ្នាក់ស្មើប្រធាននាយកដ្ឋានចំនួន ០១រូប និងថ្នាក់ស្មើអនុប្រធាននាយកដ្ឋានចំនួន ០៤រូប
- តែងតាំងមន្ត្រីថ្នាក់អនុប្រធាននាយកដ្ឋាន ជាប្រធានប្រចាំតំបន់រដ្ឋបាលសេដ្ឋកិច្ចពិសេសខេត្តព្រះសីហនុចំនួន ០១រូប នៅបាវិតចំនួន ០១រូប
- ប្រធានមន្ទីរពាណិជ្ជកម្មចំនួន ០៣រូប និងប្រធានមន្ទីរពាណិជ្ជកម្មស្តីទីចំនួន ០១រូប ប្រធានការិយាល័យ ០៦រូប និងអនុប្រធានការិយាល័យចំនួន ០២រូប។

## ខ. ផ្ទេរ និងសម្រួលភារកិច្ច

- ផ្ទេរសម្រួលភារកិច្ចជូនថ្នាក់អគ្គនាយកចំនួន ០២រូប និងថ្នាក់អគ្គនាយករងចំនួន ០៣រូប
- ផ្ទេរមន្ត្រីថ្នាក់អគ្គនាយករងពីតំបន់រដ្ឋបាលសេដ្ឋកិច្ចពិសេសខេត្តព្រះសីហនុ ឱ្យមកបម្រើការងារនៅអង្គភាពដើមវិញចំនួន ០១រូប ថ្នាក់អនុប្រធាននាយកដ្ឋានចំនួន ០៨រូប ថ្នាក់ប្រធានការិយាល័យចំនួន ២៨រូប ថ្នាក់អនុប្រធានការិយាល័យចំនួន ៥៨រូប និងមន្ត្រីចំនួន ២១៦រូប។

## គ. ការបណ្តុះបណ្តាល និងអភិវឌ្ឍន៍ធនធានមនុស្ស

- *ការបណ្តុះបណ្តាលក្នុងប្រទេស* - នៅក្នុងឆ្នាំ២០១៤នេះ បានចាត់មន្ត្រីឲ្យចូលរួម បណ្តុះបណ្តាលវគ្គខ្លីៗ និងសិក្ខាសាលាមួយចំនួន លើមុខវិជ្ជាស្តីពីការអនុវត្ត និងប្រតិបត្តិ គម្រោង Window Electronic តែមួយរបស់សមាគមន៍អាស៊ានថ្នាក់ ភាសាអង់គ្លេសសម្រាប់ទំនាក់ទំនងក្នុងតំបន់អាស៊ាន យុទ្ធសាស្ត្រអភិវឌ្ឍន៍សហគ្រាសធុនតូច និងមធ្យមការបញ្ច្រាបយេនឌ័រក្នុងវិស័យមុខងារសាធារណៈ សមាគមន៍អាស៊ាន ២០១៥ ព្រមទាំងបានបញ្ជូនមន្ត្រីទៅចូលរួមពិភាក្សាជាមួយសាស្ត្រាចារ្យសកលវិទ្យាល័យនានារបស់ប្រទេសជប៉ុន អំពីគម្រោងអាហារូបករណ៍ជប៉ុន "Public Speaking and Presentation Skills" វគ្គភាសាអង់គ្លេសកម្រិតខ្ពស់ទាក់ទងនឹងកិច្ចចចារពាណិជ្ជកម្ម និងកិច្ចប្រជុំអន្តរជាតិ, "ASEAN Single Electronic Window (SEW) Planning Implementation and Operations",English for Business Communication in ASEAN, Development Strategies for Small and Medium Enterprises, ASEAN Community 2015, ភាពជាអ្នកដឹកនាំក្នុងវិស័យសាធារណៈ រដ្ឋបាលសាធារណៈ គោលយោបាយសាធារណៈ និងអភិបាលកិច្ច បទពិសោធន៍របស់ប្រទេសសឹង្ហបុរី "Public Private Partnerships", Basic English Language and Communication Skills, Development Strategies for SME, Development Strategies for SME, ពន្លកសង្គម Management and Leadership Strategies for the Public Sector, ការអនុវត្តគោលនយោបាយ ធនធានមនុស្សក្នុងរដ្ឋបាលសាធារណៈការពង្រឹងគុណភាព នៃការផ្តល់សេវាសាធារណៈ និងការគ្រប់គ្រងការផ្លាស់ប្តូរនិងគោលការនៃការគ្រប់គ្រង និងការអនុវត្ត International Trade and Investment Laws, ជំនាញគ្រប់គ្រងប្រសិទ្ធភាពស្ថាប័ន ការគ្រប់គ្រង

ទំនាស់ និងដំណោះស្រាយទំនាស់ និងការគ្រប់គ្រងប្រសិទ្ធភាពការងារការរៀបចំផែនការគ្រប់គ្រងការអភិវឌ្ឍន៍សមត្ថភាព និងការរៀបចំផែនការធនធានមនុស្សថ្នាក់ភាសាអង់គ្លេសកម្រិត Elementary និងកម្រិត Pre-Intermediate, និងថ្នាក់ព័ត៌មានវិទ្យា។ល។ សរុបការបណ្តុះបណ្តាលក្នុងប្រទេសមានចំនួន ២៩៩នាក់ ក្នុងនោះមានស្រី ៦០នាក់។ ក្រសួងក៏បានសម្រួលដល់និស្សិតចំនួន ១៨នាក់ ស្រី ៨នាក់ដែលក្នុងនោះមកពីសាកលវិទ្យាល័យន័រតុន សាកលវិទ្យាល័យខនកែននៃប្រទេសថៃ សាកលវិទ្យាល័យជាតិគ្រប់គ្រង សាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច ឲ្យចុះកម្មសិក្សាស្រាវជ្រាវនៅទីស្តីការក្រសួងពាណិជ្ជកម្ម

- *ការបណ្តុះបណ្តាលក្រៅប្រទេស* - បានចាត់បញ្ជូនមន្ត្រីចូលរួមវគ្គបណ្តុះបណ្តាលការជ្រើសរើសទស្សនៈកិច្ចសិក្សា និងចូលរួមសិក្ខាសាលារយៈពេលខ្លីនិងរយៈពេលវែង នៅបណ្តាប្រទេសមួយចំនួនរួមមាន ជប៉ុន ចិន ស្វីស ថៃ កូរ៉េឥណ្ឌូណេស៊ី ម៉ាឡេស៊ី និងស៊ុយអ៊ែត ស្តីពីការគ្រប់គ្រងការនាំចេញក្នុងតំបន់អាស៊ាននៅសតវត្សទី២១ វគ្គបណ្តុះបណ្តាលអនុបណ្ឌិតរដ្ឋបាលសាធារណៈកម្មវិធីអ្នកច្បាប់ពាណិជ្ជកម្មអាស៊ាន២០១៤ និងច្បាប់ប្រឆាំងការរំលោភទំនុកចិត្ត, The 21st AsianExportControl Seminar, The Secondment Program for Trade Lawyers 2014-2015,Anti-Trust Law for Asian andEuropean Countries, Master's Degree in Korea experience ofEconomic Development, LL. Master Programin International Economic Law in the EastChina University of Political Science and Law in China,Asia-Pacific Trade Agreement in 2014, ATR/NTR and Notification Procedure under the ATIGA, International Executive Master of Business Administration (IEMBA), Training Program for Overseas Fellows forthe 2014-2015),Young Leader's Program 2014, 2014 WTO Advanced Trade Policy Course, Effecient Energy Use and Planning 2014B,Master's Degree Program in Economic Policy and Development,Regional Advanced Trade Negotiations Simulation Skills Course for Asia and Pacific Economies, Intellectual Property (IP), ការកសាង និងអភិវឌ្ឍន៍តំបន់ពាណិជ្ជកម្មសេរី Business Investment and Risk Management for DevelopingCountries និងប្រធានបទដទៃទៀត។ល។ សរុបការបណ្តុះបណ្តាលក្រៅប្រទេសមានចំនួន ៦១នាក់ ក្នុងនោះមានស្រី ១៨នាក់
- ចុះអនុស្សារណៈយោគយល់ ស្តីពីការអនុវត្តគម្រោងអភិវឌ្ឍន៍ការងារវិទ្យាស្ថានបណ្តុះបណ្តាលពាណិជ្ជកម្ម និងស្រាវជ្រាវ (TTRI) ជាមួយនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ ដើម្បីទទួលបានថវិកាសម្រាប់ធ្វើការកែលំអហេដ្ឋារចនាសម្ព័ន្ធ និងដំណើរការរបស់វិទ្យាស្ថាន
- បញ្ជូនសំណើថវិកាគម្រោងបណ្តុះបណ្តាលពាណិជ្ជកម្ម និងស្រាវជ្រាវ នៃក្រសួងពាណិជ្ជកម្មទៅធនាគារពិភពលោកដើម្បីស្នើសុំការយល់ព្រម
- ស្នើសុំឲ្យក្រុមហ៊ុនចំនួន ៣ ផ្តល់ជូននូវការបញ្ជាក់តម្លៃ (Quotation) នៃការរចនាប្លង់របស់វិទ្យាស្ថានដើម្បីធ្វើលទ្ធកម្ម
- រៀបចំបញ្ជីសំណួរ សម្រាប់ការវាយតម្លៃអំពីតម្រូវការបណ្តុះបណ្តាលរបស់ក្រសួងពាណិជ្ជកម្ម និងធ្វើការសំភាសន៍ អំពីតម្រូវការនេះជាមួយប្រធាននាយកដ្ឋានចំនួន ៦ គឺនាយកដ្ឋាននាំចេញ-នាំចូល នាយកដ្ឋានអឺរ៉ុប មជ្ឈឹមបូព៌ា អាហ្វ្រិក នាយកដ្ឋាននីតិកម្ម នាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម នាយកដ្ឋានអាមេរិក និងនាយកដ្ឋានកម្មសិទ្ធិបញ្ញា

- រៀបចំគោលនយោបាយ និងប្រព័ន្ធវាយតម្លៃការបណ្តុះបណ្តាលសម្រាប់វិទ្យាស្ថាន
- រៀបចំគោលការណ៍និងនីតិវិធីដើម្បីរៀបចំប្រព័ន្ធទិន្នន័យសម្រាប់ចងក្រងឯកសារបណ្តុះបណ្តាល
- ស្វែងរកការជួយឧបត្ថម្ភពីដៃគូអភិវឌ្ឍន៍នានារួមមាន: អង្គការ IDE-JETRO, វិទ្យាស្ថាន ADBI, វិទ្យាស្ថានស្រាវជ្រាវសេដ្ឋកិច្ចអាស៊ាន និងអាស៊ីខាងកើត (Economic Research Institute for ASEAN and East Asia) ដោយ ADBI បានសន្យាផ្តល់នូវ Trade Training Manual and Video Lecture មកឲ្យវិទ្យាស្ថានបណ្តុះបណ្តាលពាណិជ្ជកម្ម និងស្រាវជ្រាវ (TTRI) ហើយ ERIA មានគម្រោងនឹងរៀបចំសិក្ខាសាលា ដើម្បីផ្សព្វផ្សាយស្នាដៃស្រាវជ្រាវ នៅកម្ពុជាក្នុងខែតុលា ឆ្នាំ២០១៤ ខាងមុខនេះ។ ទន្ទឹមនឹងនេះក៏បានជួបជាមួយប្រធានក្រុមអ្នកសេដ្ឋកិច្ចរបស់ ADB ដើម្បីស្វែងរកការជួយឧបត្ថម្ភបច្ចេកទេសបន្ថែមសម្រាប់ TTRI
- រៀបចំវគ្គបណ្តុះបណ្តាលលើកទី១ សម្រាប់គ្រូបង្គោល ក្រោមជំនួយឧបត្ថម្ភរបស់គម្រោងកម្មវិធីជំនួយអភិវឌ្ឍន៍ផ្នែកពាណិជ្ជកម្ម (TDSP) និងវគ្គទីពីរនាពេលខាងមុខ
- រៀបចំសិក្ខាសាលា ស្តីពីការអនុវត្តច្បាប់កម្មសិទ្ធិបញ្ញា ក្រោមគំរោងTDSP សម្រាប់ចៅក្រម ប៉ូលីស សេដ្ឋកិច្ច មន្ត្រីកាំកុងត្រូល និងមន្ត្រីគយ និងស្តីពីទស្សនៈទាន និងនីតិវិធីចុះបញ្ជីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ។ និងបើកវគ្គបណ្តុះបណ្តាល ស្តីពីការពង្រឹងសមត្ថភាពដើម្បីក្លាយជាភ្នាក់ងារតំណាងស្របច្បាប់នៃម្ចាស់ម៉ាក ជំនាន់ទី២
- បើកវគ្គបណ្តុះបណ្តាល Trademark Examiners ស្តីពី Certification and Collective Mark ដោយសហការជាមួយអង្គភាពប្រកាសនីយប័ត្រតត្តកម្ម និងពាណិជ្ជសញ្ញា របស់សហរដ្ឋអាមេរិក (USPTO)
- រៀបចំសិក្ខាសាលាបង្កើនចំណេះដឹងកម្មសិទ្ធិបញ្ញា និងការអនុវត្តជាក់ស្តែង ដល់មន្ត្រីតុលាការពាណិជ្ជកម្មជំនាន់ទី១ ទី២ ព្រមទាំងព្រះរាជអាជ្ញា ដោយមានអ្នកចូលរួម ៥០នាក់
- ធ្វើការបណ្តុះបណ្តាលពង្រឹងសមត្ថភាពជំនាញរបស់ក្រុមការងាររៀបចំច្បាប់ ដោយបានបញ្ជូនទៅចូលរួមក្នុងសិក្ខាសាលា វគ្គបណ្តុះបណ្តាលថ្នាក់ជាតិ និងថ្នាក់តំបន់ជាច្រើនលើក
- បញ្ជូនមន្ត្រីចំនួន ១៣ រូបមកពីក្រសួងពាក់ពន្ធ័ចូលរួមវគ្គបណ្តុះបណ្តាលភាសាអង់គ្លេសនៅ ACE រយៈពេលបីខែចាប់ពីខែមេសា ដល់ខែមិថុនា ឆ្នាំ២០១៤
- បញ្ជូនមន្ត្រី៤រូប ចូលរួមសិក្ខាសាលា ស្តីពី «ការត្រួតពិនិត្យវាយតម្លៃរបស់កម្មវិធីពង្រឹងក្របខ័ណ្ឌសមាហរណកម្ម និងការអភិវឌ្ឍសមត្ថភាពផ្នែកទំនាក់ទំនង (EIF Monitoring and Evaluation and Communication Capacity Development)» នៅថ្ងៃទី១៩-២៣ ខែឧសភា ឆ្នាំ២០១៤ នៅទីក្រុងបាងកក ប្រទេសថៃឡង់ដ៍
- រៀបចំគោលនយោបាយ និងឯកសារវាយតម្លៃការបណ្តុះបណ្តាលសម្រាប់វិទ្យាស្ថាន និងរៀបចំផែនការបណ្តុះបណ្តាល ឆ្នាំ២០១៤ និងផែនការបណ្តុះបណ្តាលឆ្នាំ២០១៥
- រៀបចំវគ្គបណ្តុះបណ្តាល និងសិក្ខាសាលាក្នុងប្រទេសចំនួន ៨លើក សរុបសិក្ខាកាមចូលរួមចំនួន ៣២០នាក់ ក្នុងនោះរួមមានមន្ត្រីក្រសួងពាណិជ្ជកម្មចំនួន ២៧០នាក់ មន្ត្រីក្រសួងពាក់ព័ន្ធចំនួន ១០នាក់ និងវិស័យឯកជនចំនួន ៤០នាក់
- ជ្រើសរើសគ្រូបង្គោលរបស់វិទ្យាស្ថានចំនួន ៣៥នាក់ មកពីនាយកដ្ឋាន និងមន្ទីរពាណិជ្ជកម្មរាជធានី-ខេត្តនានា
- រៀបចំឯកសារបណ្តុះបណ្តាល និងកម្មវិធីសិក្សាសម្រាប់មុខវិជ្ជា កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី មុខវិជ្ជាកុំព្យូទ័រ និងមុខវិជ្ជាមជ្ឈត្តកម្មពាណិជ្ជកម្ម

- រៀបចំសេចក្តីព្រៀងអនុស្សារណៈយោគយល់គ្នារវាងវិទ្យាស្ថានបណ្តុះបណ្តាលពាណិជ្ជកម្ម និងស្រាវជ្រាវ (TTRI) និងវិទ្យាស្ថានមេគង្គ (Mekong Institute) នៃប្រទេសថៃឡង់ដ៍ដើម្បីសហការបើកវគ្គបណ្តុះបណ្តាលកសាងសមត្ថភាពពាណិជ្ជកម្មជូនដល់មន្ត្រីរាជការ និងវិស័យឯកជន
- ធ្វើការជួបពិភាក្សាជាមួយដៃគូអភិវឌ្ឍន៍នានា ដើម្បីស្វះស្វែងរកជំនួយឧបត្ថម្ភ និងឈានទៅរកការចុះកិច្ចព្រមព្រៀងភាពជាដៃគូ សម្រាប់វិទ្យាស្ថានហើយទទួលបានការសន្យា មួយចំនួនពីដៃគូអភិវឌ្ឍន៍ដូចជា JETRO, ADBI, WTO, ITC និង ERIA
- រៀបចំបញ្ជីការងារ (TOR) សម្រាប់ការរចនាប្លង់ និងត្រួតពិនិត្យអាគាររបស់វិទ្យាស្ថាន សម្រាប់ការវិភាគតម្លៃផលិតកម្មសម្រាប់ផលិតផលនាំចេញកម្ពុជាចំនួន ៣ បង្កើតកម្មវិធីសិក្សា និងផ្តល់ការបណ្តុះបណ្តាល និងរៀបចំផែនការយុទ្ធសាស្ត្ររបស់វិទ្យាស្ថាន
- រៀបចំធ្វើសិក្ខាសាលា ចុះផ្សព្វផ្សាយ អំពីសហគមន៍សេដ្ឋកិច្ចអាស៊ាននៅតាមរាជធានីក្រុង-ខេត្ត-ទាំងអស់របស់កម្ពុជាសម្រាប់ឆ្នាំ២០១៤ ដល់សាធារណជន និងវិស័យឯកជន ឲ្យបានជ្រួតជ្រាប និងត្រៀមរៀបចំខ្លួនចាប់យកឱកាស និងទប់ទល់បញ្ហាប្រឈមនៃ AEC ឆ្នាំ២០១៥ និងក្រោយឆ្នាំ ២០១៥
- រៀបចំពិធីរំលឹកខួបលើកទី ៤៧ ថ្ងៃបង្កើតសមាគមប្រជាជាតិអាស៊ីអគ្នេយ៍ នៅថ្ងៃទី៨ ខែសីហា ឆ្នាំ២០១៤ ដោយមានការចូលរួមពីឯកអគ្គរាជទូត រដ្ឋទូត មន្ត្រីតំណាងស្ថានទូត មន្ត្រីរាជរដ្ឋាភិបាល ភ្ញៀវជាតិ និងអន្តរជាតិប្រមាណ ២០០នាក់
- សហការជាមួយនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិរៀបចំឯកសារ និងបានចូលរួម ធ្វើជាវាគ្មិន នៅក្នុងសិក្ខាសាលា ស្តីពីសហគមន៍សេដ្ឋកិច្ចអាស៊ាន ២០១៥ នៅថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ ២០១៤
- ចូលរួមជាមួយក្រុមការងារមកពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងក្រសួងអប់រំយុវជន និងកីឡា ប្រជុំចរចាក្នុងក្រុមការងារក្របខណ្ឌគុណវុឌ្ឍិអាស៊ាន(AQRF) ដើម្បីធ្វើឲ្យលំហូរដោយសេរីនៃកម្លាំងពលកម្មក្នុងបណ្តាប្រទេសអាស៊ាន ស្របតាមគោលដៅសហគមន៍សេដ្ឋកិច្ចអាស៊ាន ឆ្នាំ២០១៥
- មន្ត្រីមួយរូប ទើបបានបញ្ចប់វគ្គសិក្សាគោលនយោបាយពាណិជ្ជកម្មតំបន់ (Regional Trade Policy Course) នៅទីក្រុងញូដេលី ប្រទេសឥណ្ឌា ដោយទទួលបាននូវចំណេះដឹងថ្មីបន្ថែមទៀត ស្តីពីការចរចាពាណិជ្ជកម្មក្នុងក្របខ័ណ្ឌអង្គការពាណិជ្ជកម្មពិភពលោក
- បញ្ជូនមន្ត្រីសរុបចំនួន ៩រូប ទៅចូលរួមវគ្គបណ្តុះបណ្តាល ស្តីពីភ្នាក់ងារបញ្ជូនទំនិញ និងពហុភាពនៃការដឹកជញ្ជូន គោលនយោបាយពាណិជ្ជកម្ម និងការចរចាពាណិជ្ជកម្ម ថវិកាកម្មវិធី និងអង្គភាពថវិកា និងសន្និសីទ ស្តីពីការផ្តល់ហិរញ្ញប្បទានដល់សហគ្រាសធុនតូច និងមធ្យមនៅកម្ពុជាដើម្បីបង្កើនសមត្ថភាព និងការយល់ដឹងរបស់មន្ត្រីនៅក្នុងនាយកដ្ឋានសំដៅបង្កើនប្រសិទ្ធភាពការងារ។

## ២.១៣ រដ្ឋបាលទូទៅ និងហិរញ្ញវត្ថុ

### ក. ការងាររដ្ឋបាលទូទៅ

- រៀបចំសណ្តាប់ធ្នាប់ចំណតយានយន្តរបស់ថ្នាក់ដឹកនាំ មន្ត្រីរាជការ ព្រមទាំងអតិថិជន ភ្ញៀវជាតិ និងអន្តរជាតិ
- សហការពង្រឹងសន្តិសុខ និងសុវត្ថិភាពក្នុងទីស្តីការក្រសួង

- ថែទាំ និងជួសជុលហេដ្ឋារចនាសម្ព័ន្ធ (ទឹក ភ្លើង ម៉ាស៊ីនត្រជាក់ លូ ផ្លូវ សួនច្បារ។ល។) នៅក្នុងទីស្តីការក្រសួង
- រៀបចំ និងចងក្រងរបាយការណ៍បូកសរុបការងារពាណិជ្ជកម្មប្រចាំសប្តាហ៍ ខែ ត្រីមាស ឆមាស ឆ្នាំ និងលទ្ធផលការងារពាណិជ្ជកម្មរបស់រាជរដ្ឋាភិបាលអាណត្តិទី៥ គិតត្រឹមខែកញ្ញាឆ្នាំ២០១៤ ធៀបនឹងផែនការសកម្មភាពឆ្នាំ២០១៤ ដើម្បីរាយការណ៍ជូនទៅទីស្តីការគណៈរដ្ឋមន្ត្រី និងខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- រៀបចំពិធីបដិសណ្ឋារកិច្ចទទួលភ្ញៀវជាតិ-អន្តរជាតិ និងកិច្ចប្រជុំផ្សេងៗ
- រៀបចំទុកដាក់ឯកសារ ឲ្យបានល្អប្រសើរតាមលំដាប់នៃលេខកូដ នៃសៀវភៅងាយស្រួលក្នុងការស្វែងរក។

ខ. <u>ការងារហិរញ្ញវត្ថុ</u>

- អនុវត្តការបើកផ្តល់ប្រាក់បៀវត្ស និងប្រាក់លាភការផ្សេងៗ ជូនមន្ត្រីរាជការសរុបទឹកប្រាក់ចំនួន ៨.៥៨២.០៨៧.៨១៤រៀល ក្នុងទឹកប្រាក់ប្រចាំឆ្នាំ ៣៦.៣៥១.២៤៣.០០០រៀល
- កត់ត្រា និងតាមដានរាល់ការចំណូល-ចំណាយថវិកាជាតិ
- រៀបចំបើកប្រាក់បៀវត្សមន្ត្រីរាជការតាមប្រព័ន្ធធនាគារ (ATM) និងធានាបើកប្រាក់បៀវត្សបានទៀងទាត់រៀងរាល់ចុងសប្តាហ៍ទី៤ នៃខែនិមួយៗ
- <u>*ចំណូលៈ*</u>
  - ការអនុវត្តចំណូល ស្តីពីការផ្តល់សេវាសាធារណៈក្នុងឆ្នាំ២០១៤ បានចំនួន ២២០.៣៧១,៣ លានរៀល ក្នុងនោះបានបង់ចូលថវិកាជាតិចំនួន ១៨៤.៨២៥,៨១លានរៀល រង្វាន់កាត់ទុកជូនក្រសួងពាណិជ្ជកម្មចំនួន ៣៤.២៥១,៦លានរៀល និងរង្វាន់កាត់ទុកជូនក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុចំនួន ១.២៩៣,៨លានរៀល
- <u>*ចំណាយៈ*</u>
  - ជំពូក៦០: មានឥណទានចំនួន ៩.៩៦៧.២២១.០០០រៀល អនុវត្តបាន ៩.៩៣៦.៧៥១.៧៧៥ (៩៩,៧%)
  - ជំពូក៦១: មានឥណទានចំនួន ៧.០៤៥.៧៧៩.០០០រៀល អនុវត្តបាន ៧.០៤៣.៥៣៧.៩៦២ (១០០%)
  - ជំពូក៦២: មានឥណទានចំនួន ២៩.៤៩៦.២០០.០០០រៀល អនុវត្តបាន ២៩.៤៤៣.៩៧៦.៩៨៤ (៩៩,៨%)
  - ជំពូក៦៣: មានឥណទានចំនួន ១៥.០០០.០០០រៀល អនុវត្តបាន ៧.៨០៩.០០០ (៥២%)
  - ជំពូក៦៤: មានឥណទានចំនួន ៣៤.៥១៧.០០០.០០០រៀល អនុវត្តបាន ៣០.៣៦៦.២៦៧.០៤២ (៨៨%)
  - ជំពូក៦៥: មានឥណទានចំនួន ៤.១១៩.២០០.០០០រៀល អនុវត្តបាន ៣.៦៧០.១៧០.១៨៣ (៨៩.១%)
- សហការរៀបចំផែនការយុទ្ធសាស្ត្រថវិកាក្រសួងឆ្នាំ២០១៥-២០១៧
- លើកគម្រោងថវិកាក្រសួងប្រចាំឆ្នាំ២០១៥

- ចូលរួមការពារគម្រោងថវិការបស់ក្រសួងឆ្នាំ២០១៥
- លើកកម្មវិធីចំណូលចំណាយថវិកាប្រចាំត្រីមាស ឆ្នាំ
- រៀបចំបណ្តុះបណ្តាល មន្ត្រីទទួលចំណូលនៅតាមបញ្ជរ
- អនុវត្តការបើកប្រាក់តាមប្រព័ន្ធធនាគារ (ATM)
- ពិនិត្យ និងកែសម្រួលកម្រៃសេវា ក្នុងទិសដៅប្រមូលចំណូល និងចំណាយឲ្យបានសមស្រប
- កំពុងសិក្សារៀបចំបន្ទប់សម្រាប់អ្នករត់ការ (នៅជាន់ទី៥) និងអង្គភាពដែលបានត្រៀមបង្កើតថ្មី
- ដោះស្រាយទូទាត់បំណុលចាស់ពី២០០៤-២០០៩
- ចូលរួមការពារគម្រោងថវិការបស់ក្រសួងឆ្នាំ២០១៥
- រៀបចំគម្រោងដេញថ្លៃផ្គត់ផ្គង់ប្រេងឥន្ទនៈ-សម្ភារៈការិយាល័យ-ឧបករណ៍មន្ទីរពិសោធន៍និងការបោះពុម្ភ
- រៀបចំផែនការលទ្ធកម្មឆ្នាំ២០១៥
- ធ្វើរបាយការណ៍បូកសរុបលទ្ធផលការងារលទ្ធកម្មប្រចាំឆ្នាំ
- ចូលរួមក្នុងគណៈកម្មការដើម្បីផ្ទៀងផ្ទាត់បញ្ជីសារពើភណ្ឌ
- បានបញ្ចប់បញ្ជីសារពើភណ្ឌឆ្នាំ២០១៣ និងកំពុងបន្តរៀបចំបញ្ជីសារពើភណ្ឌរបស់ក្រសួងឆ្នាំ២០១៤
- បានផ្គត់ផ្គង់សម្ភារៈការិយាល័យ និងបរិក្ខារជូនបណ្តាអគ្គនាយកដ្ឋាន និងនាយកដ្ឋាន។

## ២.១៤ ការធានាសន្តិសុខស្បៀង និងសន្និធិអាហារ

យុទ្ធសាស្ត្រពីរដែលចាំបាច់ត្រូវរក្សាឲ្យបានជាដាច់ខាត គឺការរក្សាសន្តិសុខស្បៀង តាមសន្និធិត្រៀមបំរុងរដ្ឋ និងស្ថេរភាពតម្លៃស្បៀងអង្ករបស់ប្រជាកសិករ។ នៅឆ្នាំ២០១៤នេះ ក្រសួងពាណិជ្ជកម្មបានស្តុកនូវអង្ករត្រៀមបំរុងរដ្ឋសម្រាប់ជូនរាជរដ្ឋាភិបាលបរិមាណ ១១.៣៦៤តោន៦០៤ ដើម្បីត្រៀមបង្ការទុកសម្រាប់ជួយដោះស្រាយជូនជនរងគ្រោះដោយសារគ្រោះទឹកជំនន់ គ្រោះរាំងស្ងួត និងឧប្បហេតុផ្សេងៗ។ បរិមាណអង្ករស្តុកចុងគ្រាសម្រាប់ត្រៀមបំរុងរដ្ឋគិតត្រឹមខែធ្នូ ឆ្នាំ២០១៤មានបរិមាណ ១៦.៦៩៤តោន៦០៤។ តាមការណែនាំដ៏ខ្ពង់ខ្ពស់ពី **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** គិតត្រឹមចុងខែធ្នូនេះ ក្រសួងបានផ្គត់ផ្គង់អង្ករតាមតម្រូវការរបស់រាជរដ្ឋាភិបាលដោយដឹកជញ្ជូនទៅកាន់ ទីដៅដែលមានប្រជាជនរងគ្រោះ រួមមានមាន ខេត្តបន្ទាយមានជ័យ ខេត្តបាត់ដំបង ពោធិសាត់ ស្ទឹងត្រែង ក្រចេះ កំពង់ស្ពឺ កំពង់ចាម ត្បូងឃ្មុំ កណ្តាល តាកែវ និងព្រៃវែងមានបរិមាណសរុបអង្ករចំនួន ៧២០តោន។

ចំណែកការធ្វើអាជីវកម្មរយៈពេលមួយឆ្នាំ របស់ក្រុមហ៊ុនគ្រឿនត្រេដ បានលទ្ធផលដូចខាងក្រោម៖

| | | | |
|---|---|---|---|
| **ក.** | - ចំណូលអាជីវកម្ម | = | ១២.៨១៦.០១០.០០០រៀល |
| | - ចំណាយអាជីវកម្ម | = | ១២.៦៨២.១៥៣.០០០រៀល |
| | - ចំណេញដុល | = | ១៣៣.៨៥៣.០០០រៀល |

**ខ.** រក្សាបាននូវសន្តិសុខស្បៀង ដោយប្រើប្រាស់យន្តការសុវត្ថិភាព និងរួមវិភាគទានជួយដល់កំណើនសេដ្ឋកិច្ចជាតិតាមរយៈ៖

- ការប្រកាន់យកគោលការណ៍ទីផ្សារសេរី ដោយរក្សាការប្រកួតប្រជែងក្នុងវិស័យឯកជន ក្នុងគោលការណ៍ជំរុញការនាំចេញឲ្យទទួលបានលទ្ធផលល្អប្រសើរ

- ការលើកកម្ពស់ប្រសិទ្ធភាពក្នុងការសម្របសម្រួលពីស្ថាប័នរដ្ឋ ដូចជាចងក្រងសហគមន៍កសិករ បង្កើនភាពងាយស្រួលសម្រាប់បង្កើនផលិតកម្ម និងការផ្គត់ផ្គង់ស្រូវអង្ករប្រកបដោយគុណភាព ក៏ដូចជាលើកស្ទួយអំណាចចរចាថ្លៃឲ្យមានតម្លាភាព
- ការជំរុញកិច្ចសហប្រតិបត្តិការភាពជាដៃគូរវាងរាជរដ្ឋាភិបាល និងវិស័យឯកជនដោយមានការចូលរួមពីផលិតករស្រូវ អាជីករម៉ាស៊ីនកិនស្រូវ ពាណិជ្ជករ និងអ្នកដឹកជញ្ជូនក្នុងការអនុវត្តគោលនយោបាយជំរុញផលិតកម្មស្រូវ និងការនាំចេញអង្ករដោយបានបង្កើននូវសហពន្ធ័ស្រូវ អង្ករកម្ពុជា
- ការលើកទឹកចិត្ត គាំទ្រ និងការពារផលប្រយោជន៍កសិករ ដោយជំរុញលើកទឹកចិត្តអ្នកនាំចេញក្នុងការបើកស្នាក់ការប្រមូលទិញ កែច្នៃស្រូវអង្ករក្នុងប្រទេស រួចធ្វើការនាំចេញអង្ករជាផ្លូវការដោយឈរលើគោលការណ៍ប្រកួតប្រជែងដោយសុច្ចរិតស្មោះត្រង់ តាមក្រមសីលធម៌ ដែលបានចុះហត្ថលេខាជាមួយក្រសួង។

## ២.១៥ ការងារអធិការកិច្ច និងសវនកម្ម

### ២.១៥.១ ការងារអធិការកិច្ច

- បើកប្រអប់សំបុត្រទទួលពាក្យបណ្តឹងជាប្រចាំ ហើយទទួលបានពាក្យបណ្តឹងចំនួន ០៦ច្បាប់ និងបានរាយការណ៍ជូនថ្នាក់ដឹកនាំទាន់ពេលវេលា
- បានបង្កើតក្រុមការងារសម្រាប់គ្រប់គ្រងត្រួតពិនិត្យ និងវាយតម្លៃអំពីកម្រិតសកម្មរបស់មន្ត្រីរាជការ
- រៀបចំកិច្ចប្រជុំដើម្បីទទួល និងដោះស្រាយបញ្ហារវាងអ្នករត់ការជាមួយថ្នាក់ដឹកនាំក្រសួង
- ចុះធ្វើអធិការកិច្ចចំពោះករណីបណ្តឹងនៅមន្ទីរពាណិជ្ជកម្មខេត្តបាត់ដំបង
- ចុះធ្វើអធិការកិច្ចលើការងារគ្រប់គ្រងថវិកា និងគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ នៅមន្ទីរពាណិជ្ជកម្មខេត្តបាត់ដំបង និងខេត្តកំពត ខេត្តកំពង់ស្ពឺ និងខេត្តព្រះសីហនុ
- ចុះត្រួតពិនិត្យនិងស្រាវជ្រាវ នៅតាមបណ្តាអង្គភាពពាក់ព័ន្ធក្នុងការផ្តល់សេវាសាធារណៈ ចំនួន ០៥ មាននាយកដ្ឋានប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម ចុះបញ្ជីពាណិជ្ជកម្ម ពហុភាគី ទ្វេភាគី កម្មសិទ្ធបញ្ញា ពីករណីការយកកម្រៃក្រៅផ្លូវការ និងនីតិវិធីមិនសមស្រប
- សហការ និងសម្របសម្រួលការងារបច្ចេកទេសជាមួយ ប្រតិភូអធិការកិច្ចនៃ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងប្រតិភូអាជ្ញាធរសវនកម្មជាតិ ដែលបានចុះមកធ្វើអធិការកិច្ច និងធ្វើសវនកម្មនៅក្រសួងពាណិជ្ជកម្ម ឲ្យប្រព្រឹត្តទៅល្អប្រសើរ
- ចុះធ្វើការត្រួតពិនិត្យឡើងវិញ ពីលទ្ធផលនៃការកែលម្អចំណុចខ្វះខាត ដែលបានរកឃើញនៅមន្ទីរពាណិជ្ជកម្ម ខេត្តកំពត និងក្រុមហ៊ុនហ្រ្វីនត្រេដ
- ចូលរួមធ្វើអធិការកិច្ចលើការរៀបចំ និងចាត់ចែងពិព័រណ៍ ជាមួយនាយកដ្ឋានជំរុញពាណិជ្ជកម្ម ចំនួន ១០លើក
- ចុះធ្វើអធិការកិច្ចការងារគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ និងរកឃើញការខ្វះខាត ៥ករណីរួមមាន៖
    - ភាពយឺតយ៉ាវនៃការធ្វើបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋ
    - ភាពយឺតយ៉ាវនៃការជំរះចេញពីបញ្ជីនូវទ្រព្យសម្បត្តិដែលមានប្រកាសអន្តរក្រសួង (ក្រសួងពាណិជ្ជកម្ម និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ) រួចហើយ
    - ទីតាំងដីមួយចំនួននៅមិនទាន់មានប័ណ្ណសម្គាល់កម្មសិទ្ធិជាទ្រព្យសម្បត្តិរដ្ឋ

- ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋនៅមិនទាន់បានម៉ឺងម៉ាត់ ទីតាំងដី និងឃ្លាំងមួយចំនួនត្រូវបានប្រជាជនរំលោភស្នាក់នៅ ដែលទីតាំងខ្លះមានប័ណ្ណសម្គាល់កម្មសិទ្ធិជាទ្រព្យសម្បត្តិរដ្ឋរួចហើយ ទីតាំងខ្លះទៀតត្រូវកងកម្លាំងប្រដាប់អាវុធយកធ្វើជាទីស្នាក់ការ
- មិនបានប្រជុំផ្ទៀងផ្ទាត់បញ្ជីសារពើភ័ណ្ឌប្រចាំឆ្នាំ។

### ២.១៥.២ ការងារសវនកម្មផ្ទៃក្នុង

ចុះធ្វើការងារសវនកម្មបានចំនួន ១៧ អង្គភាព ក្នុងនោះមានៈ

- អង្គភាពថ្នាក់កណ្តាល ០១ អង្គភាព (នាយកដ្ឋានរដ្ឋបាល)
- មន្ទីរពាណិជ្ជកម្មខេត្ត ០៨អង្គភាព (មន្ទីរពាណិជ្ជកម្មខេត្ត តាកែវ កណ្តាល កែប បន្ទាយមានជ័យ មណ្ឌលគិរី ឧត្តរមានជ័យ ក្រចេះ និងរាជធានីភ្នំពេញ)
- សាខាកាំកុងត្រូល ០៧អង្គភាព (សាខាខេត្ត តាកែវ កណ្តាល កែប បន្ទាយមានជ័យ មណ្ឌលគិរី ឧត្តរមានជ័យ ក្រចេះ)
- ក្រុមហ៊ុនហ្គ្រីនត្រេដ ០១អង្គភាព

**លទ្ធផលដែលបានរកឃើញមានដូចខាងក្រោមៈ**

- កង្វះខាតក្នុងការងារគ្រប់គ្រងរដ្ឋបាលចំនួន ០៤ករណី
- កង្វះខាតក្នុងការងារគ្រប់គ្រងហិរញ្ញវត្ថុចំនួន ១៤ករណី
- កង្វះខាតក្នុងការងារគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋចំនួន ១៣ករណី
- កង្វះខាតក្នុងការងារអនុវត្តន៍តាមអនុលោមភាពនៃច្បាប់មានចំនួន ១៥ករណី
- ត្រួតពិនិត្យឡើងវិញនូវអនុសាសន៍កាលពីឆ្នាំមុនចំនួន ០៧អនុសាសន៍។

## ២.១៦ ការងារសង្គមកិច្ច និងសម្ព័ន្ធភាព

- ចុះសួរសុខទុក្ខ និងឧបត្ថម្ភគ្រឿងឧបភោគ បរិភោគ និងវិភាគទានដល់កងអនុរាគមន៍លេខ១១ នៅព្រំប្រទល់តាកែវ-កំពតចំនួនទឹកប្រាក់សរុប ៣២.៣៤៩.៥០០រៀល
- ចុះសួរសុខទុក្ខ និងឧបត្ថម្ភគ្រឿងឧបភោគ បរិភោគ និងវិភាគទានដល់កងអន្តរាគមន៍លេខ៣ និងលេខ៨ ទិសប្រាសាទព្រះវិហារសរុបថវិកាចំនួន ៥១.២៧៥.០០០រៀល
- ចុះសួរសុខទុក្ខ និងឧបត្ថម្ភគ្រឿងឧបភោគ បរិភោគ និងវិភាគទានដល់កងអន្តរាគមន៍នៅទិសប្រាសាទតាក្របី និងតាមាន់ចំនួនទឹកប្រាក់សរុប ២៣.៩៤៦.៥០០រៀល
- ក្រៅពីនោះបានផ្តល់សម្ភារៈសាងសង់ជម្រក និងលេណដ្ឋានដល់កងអន្តរាគមន៍ទាំង៣ទីតាំងឈរជើងសរុបទឹកប្រាក់ ២២០.២៥៥.០០០រៀល (ស្មើនឹង៥៤.២៥០ដុល្លារអាមេរិក)
- ចងសម្ព័ន្ធមេត្រីភាពជាមួយអង្គភាពបញ្ជាការកាំភ្លើងធំនៃកងទ័ពជើងគោក ក្នុងខេត្តកំពង់ឆ្នាំង និងឧបត្ថម្ភគ្រឿងឧបភោគ បរិភោគ ព្រមទាំងថវិកាចំនួន ៣២.៣៤២.០០០រៀល
- ឧបត្ថម្ភទៅមន្ទីរពេទ្យគន្ធបុប្ផាតាមរយៈការលេងល្បែង Ice Bucket Challege ចំនួនទឹកប្រាក់សរុប ៣.៣០០ដុល្លារអាមេរិក និង២.៣៨០.០០០រៀល
- ចូលរួមបរិច្ចាកឈាមសម្រាប់មន្ទីរពេទ្យកាល់ម៉ែត ដោយមន្ត្រីរាជការចំនួន ៧០នាក់

- បានផ្តល់ប្រាក់សង្គហសង្គ្រោះរបស់សមាគមមន្ត្រីរាជការស៊ីវិលក្រសួងពាណិជ្ជកម្មចំនួន ១៩.០០០.០០០រៀល សម្រាប់សមាជិកសមាគមជាមន្ត្រីរាជការ ០៣រូប និងសហព័ទ្ធ ០១រូប ដែលបានទទួលមរណភាព
- បានចូលរួមវិភាគទានកាកបាទក្រហមប្រចាំឆ្នាំ២០១៤ជាទឹកប្រាក់ចំនួន ១១.០៨០ដុល្លារអាមេរិក និង១៤,៧៩៥,០០០រៀល។

## ២.១៧ ការងារយេនឌ័រ

- ស្របតាមអនុសាសន៍របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី** នៃព្រះរាជាណាចក្រកម្ពុជា ដែលបានជំរុញ ការលើកកំពស់តួនាទីស្ត្រី ដោយបញ្ជាក់ថា "មន្ត្រីរាជការជាស្ត្រី អាចត្រូវបានតែងតាំងជំនួសមន្ត្រីទាំងឡាយដែលចូលនិវត្តន៍" ថ្នាក់ដឹកនាំ ក្រសួងតាមរយៈកំណែទម្រង់បានធ្វើការតែងតាំងស្ត្រីជា អគ្គនាយករងចំនួន ៥រូប និងលើកទឹកចិត្តការតែងតាំងបន្តទៀត សមាសភាពស្ត្រីជាអ្នកដឹកនាំគ្រប់គ្រងទាំងថ្នាក់ជាតិ និងថ្នាក់មូលដ្ឋាន
- រៀបចំបញ្ជីឈ្មោះស្ត្រីថ្នាក់ដឹកនាំក្រសួង ដែលមានឋានៈស្មើប្រធាននាយកដ្ឋានឡើងចំនួន ១០រូប ផ្ញើជូនក្រសួងកិច្ចការនារី ដើម្បីក្រសួងកិច្ចការនារីរៀបចំបោះពុម្ពសៀវភៅ ស្ត្រីជាអ្នកដឹកនាំនៅកម្ពុជា
- ចូលរួម ជាមួយក្រុមការងារក្រសួងកិច្ចការនារី ក្នុងការអនុវត្តគម្រោង PGM2 ស្តីពីការពង្រឹងភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រីតាមរយៈគម្រោងសាកល្បង ចិញ្ចឹមមាន់ និងការកែច្នៃកសិផល ដូចជា៖ ការធ្វើនំ ជ្រក់ខ្ចី និងទឹកខ្ទិះ នៅស្រុកព្រៃឈរ ខេត្តកំពង់ចាម
- ទៅទស្សនៈកិច្ចសិក្សានៅខេត្ត Tochigi និង ខេត្ត Saytama ប្រទេសជប៉ុន រយៈពេលចំនួន ១៣ថ្ងៃ ដើម្បីសិក្សាអំពីគោលនយោបាយបញ្ជ្រាបយេនឌ័រ របស់ប្រទេសជប៉ុន ការបង្កើតសមាគមស្ត្រីវ័យចំណាស់ ក្នុងការចូលរួមចំណែកការងារសង្គម និងបង្កើនសេដ្ឋកិច្ចជាតិ
- ចូលរួមកិច្ចប្រជុំ រៀបចំឡើងដោយក្រសួងកិច្ចការនារី កាលពីខែមិថុនា ឆ្នាំ២០១៤ ដើម្បីចែករំលែកនូវព័ត៌មានអំពីដំណើរការ នៃការបញ្ជ្រាបយេនឌ័រទៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ឆ្នាំ២០១៤-២០១៨ និងផែនការថវិកាយេនឌ័រទៅក្នុងផែនការប្រចាំឆ្នាំរបស់ក្រសួង ស្ថាប័ន
- ចូលរួមសិក្ខាសាលា ស្តីពីការរៀបចំថវិកាឆ្លើយតបនឹងតម្រូវការយេនឌ័រ និងសិក្ខាសាលា ស្តីពីការរៀបចំអនុសាសន៍សម្រាប់គោលនយោបាយរបស់គម្រោងបញ្ជ្រាបយេនឌ័រដំណាក់កាលទី២ PGM2
- ចូលរួមកិច្ចប្រជុំផ្សព្វផ្សាយការងារឆ្លើយតប និងជំងឺអេដស៍ ស្តីពីទិសដៅ និងផែនការសកម្មភាពជាតិទូលំទូលាយនិងពហុវិស័យឆ្លើយតបការរាលដាលមេរោគអេដស៍និងជំងឺអេដស៍នៅទីស្តីការក្រសួង
- ស្ត្រីជាមន្ត្រីក្រសួងបានរួមចំណែកក្នុងការពង្រឹងសមត្ថភាពរបស់ពាណិជ្ជករ និងអាជីវករតាមរយៈការបង្កើនការយល់ដឹង អំពីមុខរបរពាណិជ្ជកម្មខ្នាតតូច ពិសេសជំរុញការចូលរួមរបស់ស្ត្រីជាអាជីវករនៅក្នុងការតាំងពិព័រណ៍ថ្នាក់ក្រោមជាតិ
- បើកកិច្ចប្រជុំពិភាក្សាពង្រឹងការអនុវត្តការងារបញ្ជ្រាបយេនឌ័រក្នុងវិស័យពាណិជ្ជកម្មនៅទីស្តីកាក្រសួង
- បើកវគ្គបណ្តុះបណ្តាល ស្តីពីអនុសញ្ញាលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងនារីភេទ និងច្បាប់ពាក់ព័ន្ធក្នុងការអនុវត្តបំពេញសិទ្ធិរបស់ស្ត្រី ខេត្តឧត្តរមានជ័យ
- បើកវគ្គបណ្តុះបណ្តាលស្តីពីគោលគំនិតយេនឌ័រ សមភាពយេនឌ័រ បញ្ហាប្រឈម ការតស៊ូមតិ និងអនុសញ្ញាស៊ី-ដ នៅទីស្តីការក្រសួង

- បើកវគ្គបណ្តុះបណ្តាល ស្តីពីគោលគំនិតយេនឌ័រ សមភាពយេនឌ័រ បញ្ហាប្រឈម និងការតស៊ូមតិ ខេត្តស្វាយរៀង
- ផ្សព្វផ្សាយរបាយការណ៍ជាតិលើកទី៤ និងលើកទី៥ ស្តីពីអនុសញ្ញាស៊ី-ដនៅកម្ពុជា ពិធីសារតាមជម្រើសនៃអនុសញ្ញាស៊ី-ដ នៅខេត្តពោធិ៍សាត់
- បើកកិច្ចប្រជុំបូកសរុបសកម្មភាពការងារបញ្ជ្រាបយេនឌ័រ ក្នុងវិស័យពាណិជ្ជកម្មឆ្នាំ២០១៣ និងលើកទិសដៅសកម្មភាពការងារបញ្ជ្រាបយេនឌ័រក្នុងវិស័យពាណិជ្ជកម្មឆ្នាំ២០១៤ នៅទីស្តីការក្រសួង
- ចូលរួមបណ្តុះបណ្តាលដល់កសិករជាស្ត្រី ក្នុងការចាប់ដៃគូប្រកបមុខរបរ និងវេទិកាអាជីវកម្មនៅខេត្តកំពង់ចាម
- បើកកិច្ចប្រជុំពិភាក្សាពង្រឹងការអនុវត្តការងារបញ្ជ្រាបយេនឌ័រក្នុងវិស័យពាណិជ្ជកម្មនៅទីស្តីកាក្រសួង
- បើកវគ្គបណ្តុះបណ្តាល ស្តីពីគោលគំនិតយេនឌ័រ និងអនុសញ្ញាលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងនារីភេទ នៅខេត្តកោះកុង
- ផ្សព្វផ្សាយរបាយការណ៍ជាតិលើកទី៤ និងលើកទី៥ ស្តីពីអនុសញ្ញាស៊ី-ដនៅកម្ពុជា យោបល់សន្និដ្ឋានរបស់អង្គការសហប្រជាជាតិ និងតម្រូវការយេនឌ័រ នៅខេត្តរតនៈគីរី។

## ២.១៨ សកម្មភាពការងារមន្ទីរពាណិជ្ជកម្មរាជធានី-ខេត្ត

### ២.១៨.១ ការងារអាជីវកម្ម

- ចេញលិខិតអនុញ្ញាតប្រកបអាជីវកម្ម សេវាកម្ម ពាណិជ្ជកម្មបាន ៩.២១០ច្បាប់ ដើម្បីគ្រប់គ្រងការធ្វើអាជីវកម្ម សេវាកម្ម ពាណិជ្ជកម្ម រាជធានី-ខេត្ត
- ចេញលិខិតអនុញ្ញាតប្រកបអាជីវកម្ម សេវាកម្ម ពាណិជ្ជកម្មបានចំនួន ៣.៧៧២ច្បាប់ តាមរយៈការិយាល័យច្រកចេញ-ចូលតែមួយ នៅតាមក្រុង-ស្រុក-ខណ្ឌគោលដៅ
- ចេញលិខិតអនុញ្ញាតប្រកបអាជីវកម្មគ្រឿងអលង្ការ លោហធាតុ និងត្បូងថ្មមានតម្លៃបានចំនួន ២.២៣៦ច្បាប់
- ផ្តល់ប្រឹក្សាជួយសម្រួលដល់ពាណិជ្ជករ អាជីវករដែលមានបំណងចង់បង្កើតអាជីវកម្មខ្នាតតូច ចុះបញ្ជីពាណិជ្ជកម្មសហគ្រាស ក្រុមហ៊ុន ចុះបញ្ជីម៉ាក និងសុំវិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញ ដើម្បីបង្កលក្ខណៈងាយស្រួលដល់ការប្រកបអាជីវកម្មនៅថ្នាក់មូលដ្ឋាន
- ផ្សព្វផ្សាយណែនាំ អំពីតម្រូវការទីផ្សារ ពិសេសចំពោះមុខទំនិញកសិផល ដែលជាតម្រូវការទីផ្សារក្នុងស្រុក និងទីផ្សារអន្តរជាតិ ដើម្បីតម្រង់ទិសឲ្យកសិករអាចសម្រេចចិត្តធ្វើការដាំដុះបានត្រឹមត្រូវជៀសវាងការធ្លាក់ថ្លៃ និងទំនិញកកស្ទះ
- ចូលរួមសហការជាមួយភ្នាក់ងារកាំកុងត្រូល ធ្វើការត្រួតពិនិត្យអនុលោមភាពបទដ្ឋានបច្ចេកទេសមុខទំនិញម្ហូបអាហារ ទំនិញវេចខ្ចប់ ដើម្បីស្វែងរកសារធាតុគីមីហាមឃាត់ ដែលអាចប៉ះពាល់សុខភាពអ្នកប្រើប្រាស់។

### ២.១៨.២ ការងារជំរុញពាណិជ្ជកម្ម

- ស្រង់ស្ថិតិថ្លៃទំនិញចាំចាច់សម្រាប់ជីវភាព នៅទីផ្សារតាមបណ្តាខេត្ត ដើម្បីបញ្ជូនជាប្រចាំមកទីស្តីការក្រសួង សម្រាប់ប្រើប្រាស់ក្នុងការវិភាគព័ត៌មានពាណិជ្ជកម្ម និងរាយការណ៍ជូនអង្គប្រជុំគណៈរដ្ឋមន្ត្រីប្រចាំសប្តាហ៍

- តាមដានត្រួតពិនិត្យ និងផ្សព្វផ្សាយណែនាំឲ្យមានការបិទស្លាកថ្លៃទំនិញនៅតាមទីផ្សារ និងតាមផ្សារទំនើបនៅបណ្ដាខេត្ត ដើម្បីលើកកម្ពស់ប្រសិទ្ធភាពកិច្ចការពារអ្នកប្រើប្រាស់ និងធានាតម្លាភាពរវាងអ្នកទិញ និងអ្នកលក់
- សហការជាមួយគណៈកម្មការរៀបចំពិព័រណ៍ថ្នាក់ខេត្ត រៀបចំពិព័រណ៍ប្រចាំឆ្នាំ និងពិព័រណ៍ភូមិមួយផលិតផលមួយ ជារៀងរាល់ឆ្នាំ
- សហការជាមួយប្រទេសជិតខាង ថៃ និងវៀតណាមរៀបចំពិព័រណ៍ ក្រោមរូបភាពពិព័រណ៍ផ្សារណាត់ និងពិព័រណ៍ពាណិជ្ជកម្មជាដៃគូ ដើម្បីផ្សព្វផ្សាយ និងស្វែងរកទីផ្សារសម្រាប់ទំនិញកម្ពុជា និងស្វែងរកទំនិញមានគុណភាពសម្រាប់ទីផ្សារក្នុងស្រុក
- ចូលរួមពិព័រណ៍ពាណិជ្ជកម្មអន្តរជាតិរៀបចំដោយ ខេត្តសម្ព័ន្ធភាព ដែលធ្វើឡើងនៅតាមខេត្តនៃប្រទេសនីមួយៗ
- រៀបចំពិព័រណ៍ផលិតផលកសិកម្មដោយសហការជាមួយមន្ទីរកសិកម្ម ដើម្បីជំរុញការធ្វើពិពិធកម្មការនាំចេញទំនិញកសិផលកម្ពុជា
- ចូលរួមផ្សព្វផ្សាយការអនុវត្តច្បាប់ពាណិជ្ជកម្មដល់អាជីវករ និងសភាពាណិជ្ជកម្មដើម្បីឲ្យយល់ដឹងអំពីបញ្ញត្តិច្បាប់ពាណិជ្ជកម្មថ្មីៗ ដែលទើបនឹងកសាង និងដាក់ឲ្យអនុវត្ត ដូចជាច្បាប់ស្តីពីមជ្ឈត្តការពាណិជ្ជកម្ម និងប្រតិបត្តិការដែលមានកិច្ចធានា ច្បាប់ស្តីពីកម្មសិទ្ធិបញ្ញា ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម និងវិធាននៃការចុះបញ្ជីពាណិជ្ជកម្ម។ល។
- ចូលរួមចុះស្រាវជ្រាវ ព័ត៌មានអំពីសក្តានុពលភាពរបស់រោងម៉ាស៊ីនកិនស្រូវតាមមូលដ្ឋាន និងរៀបចំស្ថិតិអ្នកនាំចេញអង្ករ ដើម្បីរួមចំណែកជំរុញអនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិបាលក្នុងការនាំចេញអង្ករឲ្យបាន ១លានតោនក្នុងឆ្នាំ២០១៥
- ចូលរួមក្នុងវេទិការសាធារណៈដើម្បីក្តាប់នូវសំណូមពររបស់ប្រជាពលរដ្ឋ និងអាជីវករទាក់ទងនឹងវិស័យពាណិជ្ជកម្ម សំដៅផ្តល់នូវដំណោះស្រាយចំពោះមុខទាន់ពេលវេលា និងពាំនាំបញ្ហាមួយចំនួនដែលមិនអាចដោះស្រាយបាន សម្រាប់ជូនថ្នាក់ក្រសួងដោះស្រាយ។

## ៣. ទិសដៅអនុវត្តការងារពាណិជ្ជកម្មឆ្នាំ២០១៥

### ក.ទិសដៅការងារមន្ត្រី

- រៀបចំធ្វើសមាហរណកម្មមន្ត្រីទៅ តាមក្របខណ្ឌ ឋានន្តរសក្តិ តាមព្រះរាជក្រឹត្យ ស្តីពីការរៀបចំមុខងារសាធារណៈ
- រៀបចំតែងតាំង ផ្ទេរភារៈកិច្ច និងបំពេញបន្ថែមមន្ត្រី ឲ្យស្របទៅតាមរចនាសម្ព័ន្ធថ្មីរបស់ក្រសួង
- រៀបចំឯកសារសម្រាប់ធ្វើការប្រលងផ្ទៃក្នុង ដើម្បីផ្លាស់ប្តូរប្រភេទក្របខណ្ឌមន្ត្រី
- ចុះណែនាំអំពីនីតិវិធីនៃការតែងតាំង ការផ្លាស់ប្តូរ និងការបញ្ចប់ភារកិច្ចមន្ត្រីរាជការស៊ីវិលដែលបំពេញការងារនៅថ្នាក់ក្រោមជាតិ
- ចុះប្រជុំវាយតម្លៃកម្មសិក្សានៅមន្ទីរពាណិជ្ជកម្មរាជធានីខេត្ត
- រៀបចំកិច្ចប្រជុំបូកសរុបសកម្មភាពការងារ បញ្ច្រាបយេនឌ័រក្នុងវិស័យពាណិជ្ជកម្មឆ្នាំ២០១៤ និងលើកទិសដៅសកម្មភាពការងារបញ្ច្រាបយេនឌ័រក្នុងវិស័យពាណិជ្ជកម្មឆ្នាំ២០១៥
- រៀបចំឯកសារដំឡើងកម្រិតនៃប្រាក់បំណាច់មុខងារ និងការដំឡើងថ្នាក់ជូនមន្ត្រីរាជការប្រចាំឆ្នាំ២០១៥

- រៀបចំសេចក្តីជូនដំណឹងទៅគ្រប់អង្គភាព ស្តីពីការប្រើប្រាស់បុគ្គលិកជាប់កិច្ចសន្យា និងពលករអណ្តែតសម្រាប់ឆ្នាំ២០១៥
- ធ្វើផែនការថវិកាបន្ទុកបុគ្គលិក ដើម្បីសរុបបញ្ចូលក្នុងកញ្ចប់ថវិកាក្រសួងឆ្នាំ២០១៥
- រៀបចំបែបបទបញ្ចូលក្នុងតារាងបៀវត្សឆ្នាំ២០១៤ នូវមន្ត្រីកម្មសិក្សាថ្មីចំនួន ៦០នាក់ ដែលបានប្រឡងជាប់ជាស្ថាពរ
- រៀបចំកែសម្រួលភារកិច្ច និងតែងតាំងមន្ត្រីដឹកនាំតាមអគ្គនាយកដ្ឋាន នាយកដ្ឋាន ជំនួសមន្ត្រីចូលនិវត្តន៍
- ធ្វើបច្ចុប្បន្នភាពមន្ត្រីរាជការគ្រប់ស្ថាប័នរាជធានីខេត្ត
- ចុះផ្សព្វផ្សាយលម្អិតពីរចនាសម្ព័ន្ធរបស់ក្រសួងដល់មន្ទីរពាណិជ្ជកម្មរាជធានីខេត្ត
- រៀបចំសិក្ខាសាលា ស្តីពីការពង្រឹងសមត្ថភាពមន្ត្រីរាជការថ្នាក់ក្រោមជាតិ
- ធ្វើបច្ចុប្បន្នភាពសមាជិកសមាគមមន្ត្រីរាជការស៊ីវិលក្រសួងពាណិជ្ជកម្ម។

## ខ.ទិសដៅការងារអធិការកិច្ច

- ពិនិត្យឡើងវិញ និងជំរុញការធ្វើរបាយការណ៍របស់បណ្តាអង្គភាពមកអគ្គាធិការដ្ឋាន
- លើកសកម្មភាព បំប៉នសមត្ថភាពមន្ត្រីនៃអគ្គាធិការដ្ឋាន
- តាមដាន និងវាយតម្លៃនូវលទ្ធផលនៃការអនុវត្តកែលម្អ តាមអនុសាសន៍របស់ប្រតិភូអធិការកិច្ចដែលបានលើកឡើង
- ចូលរួមពង្រឹងស្ថាប័ន និងគុណភាពការងារដើម្បីមានសមត្ថភាព សម្រេចបានសមិទ្ធិផលការងារប្រកបដោយគុណភាព
- ត្រួតពិនិត្យឡើងវិញ និងធ្វើការរំលឹកដល់បណ្តានាយកដ្ឋាន និងអង្គភាពក្រោមឪវាទក្រសួងពាណិជ្ជកម្ម ក្នុងការទារបំណុលដែលត្រូវបង់ចូលរដ្ឋ ពីភាគីពាក់ព័ន្ធរួមជាមួយការថែរក្សា និងគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ការអនុវត្តការងារប្រចាំថ្ងៃប្រកបដោយតម្លាភាព និងមានប្រសិទ្ធិភាពខ្ពស់
- បន្តការពិនិត្យ និងតាមដានជាប្រចាំ ការអនុវត្តការងារ របស់អង្គភាពចំណុះក្រសួង ពាណិជ្ជកម្មប្រកបដោយតម្លាភាព គោលបំណងបញ្ចៀសនូវបាតុភាព និងភាពអសកម្ម ដែលជាដើមហេតុជះឥទ្ធិពលដល់ក្រសួងពាណិជ្ជកម្ម
- ធ្វើអធិការកិច្ចលើការងារលទ្ធកម្មសាធារណៈ
- ខិតខំបំពេញការងារផ្សេងៗទៀត ដែលថ្នាក់ដឹកនាំក្រសួងប្រគល់ជូន។

## គ.ទិសដៅការងារសវនកម្មផ្ទៃក្នុង

- ធ្វើផែនការសវនកម្មប្រចាំឆ្នាំ ២០១៥
- ធ្វើការសិក្សាលើហានិភ័យរបស់អង្គភាពរងសវនកម្ម ដើម្បីកំណត់វិសាលភាព នៃការងារសវនកម្មឆ្នាំ ២០១៥
- កំណត់អំពីការងារដែលត្រូវធ្វើនៅតាមបណ្តាសវនដ្ឋាននីមួយៗ
- ចុះធ្វើការងារសវនកម្ម ២៥អង្គភាព ក្នុងនោះមាននាយកដ្ឋានថ្នាក់កណ្តាល ០៧ មន្ទីរពាណិជ្ជកម្មខេត្ត ៨ សាខាកាំកុងត្រូល ៨ តំបន់ពិសេស ១ និងផែស្ងួត ១

## ឃ.ទិសដៅការងារកម្មសិទ្ធបញ្ញា

- រៀបចំប្រកាស និងបោះពុម្ព Trademark Manual បន្ទាប់ពីបានបកប្រែជាភាសាខ្មែររួច
- រៀបចំបង្កើតបណ្ឌិតសភាកម្មសិទ្ធិបញ្ញា ដើម្បីចុះអនុស្សារណៈជាមួយសកលវិទ្យាល័យនានា សំដៅបញ្ចូលមុខវិជ្ជាកម្មសិទ្ធិបញ្ញា ក្នុងកម្មវិធីសិក្សា
- បង្កើតមជ្ឈមណ្ឌលព័ត៌មានកម្មសិទ្ធិបញ្ញា និងបញ្ជរពិគ្រោះ និងផ្តល់ព័ត៌មានកម្មសិទ្ធិបញ្ញាសម្រាប់ ទំនាក់ទំនងជាមួយសាធារណៈជន
- រៀបចំសេចក្តីព្រាងអនុក្រឹត្យ និងប្រកាសអនុវត្តច្បាប់ ស្តីពីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ
- បោះពុម្ពសៀវភៅច្បាប់ ស្តីពីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ និងសហការជាមួយអាជ្ញាធរដែនដី និងក្រសួងពាក់ព័ន្ធ សិក្សាស្រាវជ្រាវ និងកំណត់តំបន់ភូមិសាស្ត្រទំនិញ ដែលមានសក្តានុពល ដើម្បីឈានទៅដល់ការចុះបញ្ជីការពារជាម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ
- ជំរុញការរៀបចំសេចក្តីព្រាងច្បាប់ ស្តីពីព័ត៌មានសម្ងាត់ពាណិជ្ជកម្ម
- រៀបចំឡើងវិញនីតិវិធីនៃការទទួលស្គាល់សិទ្ធិផ្តាច់មុខលើម៉ាកក្នុងការនាំចូល និងការដោះស្រាយវិវាទ
- បន្តកែសម្រួល Data Validation ឡើងវិញលើម៉ាកដែលបានចុះបញ្ជី ដើម្បីសម្រួលដល់ការពិនិត្យ ស្រាវជ្រាវម៉ាកឲ្យបានកាន់តែច្បាស់លាស់
- ពង្រឹងបន្ថែមការធ្វើស្វ័យប្រវត្តិកម្ម (Automation) ការចុះបញ្ជីម៉ាក
- សុំការអនុម័តពីគណៈរដ្ឋមន្ត្រីលើសេចក្តីព្រាងអនុក្រឹត្យ ស្តីពីការបង្កើតអនុគណៈកម្មការអនុវត្ត ច្បាប់កម្មសិទ្ធិបញ្ញា និងអនុគណៈកម្មការការអប់រំ និងផ្សព្វផ្សាយ
- រៀបចំសេចក្តីព្រាងអនុក្រឹត្យ និងសេចក្តីណែនាំស្តីពីនីតិវិធីអនុវត្តច្បាប់កម្មសិទ្ធិបញ្ញា
- រៀបចំសេចក្តីព្រាងប្រកាស ស្តីពីនីតិវិធីចុះបញ្ជីម៉ាកសមូហភាព (Collective Mark) និង Certification Mark ដោយរួមសហការជាមួយអង្គការកម្មសិទ្ធិបញ្ញាពិភពលោក និងដៃគូអភិវឌ្ឍន៍
- ស្វែងរកដៃគូផ្តល់ជំនួយលើទំនិញសក្តានុពល ដើម្បីអភិវឌ្ឍន៍ទៅជាទំនិញសម្គាល់ភូមិសាស្ត្រ ទំនិញ និងបន្តជំរុញការចុះបញ្ជីម្រេចកំពត ជាម៉ាកសម្គាល់ភូមិសាស្ត្រទំនិញនៅEU និងបណ្តា ប្រទេសជិតខាង
- បន្តការពិនិត្យ និងកែសម្រួលសេចក្តីណែនាំ ស្តីពីនីតិវិធីចុះបញ្ជីម៉ាក ប្តឹងជំទាស់ លុបម៉ាក និងសវនការ ដើម្បីរៀបចំជាប្រកាសរបស់ក្រសួង
- ជំរុញរៀបចំកិច្ចការនានាដែលនៅសេសសល់ ដើម្បីក្លាយជាសមាជិកពិធីសារម៉ាឌ្រីត (Madrid Protocol) ស្តីពីការចុះបញ្ជីម៉ាកជាលក្ខណៈអន្តរជាតិ។

## ង.ទិសដៅការងារច្បាប់ និងបទបញ្ញត្តិផ្សេងៗ

- ជំរុញការអនុម័តច្បាប់ការពារអ្នកប្រើប្រាស់ នៅទីស្តីការគណៈរដ្ឋមន្ត្រី ឲ្យបានមុនដំណាច់ឆ្នាំ២០១៥
- ជំរុញបញ្ចប់ការពិភាក្សាច្បាប់ ស្តីពីកិច្ចសន្យាពាណិជ្ជកម្ម ដែលក្នុងនោះ រួមមានជំពូកស្តីពី Franchise (សិទ្ធិអាជីវកម្ម)
- បន្តជំរុញការរៀបចំសេចក្តីព្រាងច្បាប់ ស្តីពីការប្រកួតប្រជែង
- បន្តជំរុញការរៀបចំសេចក្តីព្រាងច្បាប់ ស្តីពីភ្នាក់ងារពាណិជ្ជកម្ម
- កែលម្អប្រព័ន្ធចុះបញ្ជីប្រាតិភោគ ដោយបន្ថែមមុខងារចុះបញ្ជីប្រតិបត្តិការភតិសន្យា

- ពិនិត្យឡើងវិញដើម្បីកែសម្រួលច្បាប់ ស្តីពីវិធានពាណិជ្ជកម្មនិងបញ្ជីពាណិជ្ជកម្ម និងច្បាប់សហគ្រាសពាណិជ្ជកម្ម
- រៀបចំប្រព័ន្ធស្វ័យប្រវត្តិកម្មការចុះបញ្ជីពាណិជ្ជកម្ម និងការកែប្រែផ្សេងៗ
- សិក្សាលទ្ធភាព នៃការរៀបចំនីតិវិធីចុះបញ្ជី ការរំលាយបញ្ចូលគ្នារបស់សហគ្រាសក្រុមហ៊ុន និងនីតិវិធីក្នុងការលុបឈ្មោះក្រុមហ៊ុនចេញពីបញ្ជីពាណិជ្ជកម្ម
- រៀបចំនីតិវិធីចុះបញ្ជីក្រុមហ៊ុនសហកម្មសិទ្ធិ
- ជំរុញបញ្ចប់ច្បាប់ ស្តីពីការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក (E-Commerce) ដើម្បីដាក់ជូនទីស្តីការគណៈរដ្ឋមន្ត្រីក្នុងឆ្នាំ២០១៥
- បន្តអនុវត្តការវាយតម្លៃផលប៉ះពាល់របស់លិខិតបទដ្ឋានគតិយុត្តទៅលើអាជីវកម្ម និងសង្គម។

## ច.ទិសដៅការងារសេវាពាណិជ្ជកម្ម

- អនុវត្តការចេញវិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញ តាមប្រព័ន្ធអេឡិកត្រូនិចពេញលេញ (Full Automation)
- អនុវត្តការចុះបញ្ជីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិកត្រូនិចពេញលេញ (Full Automation for Business Registration)
- អនុវត្តការប្រើប្រាស់ការទូទាត់តាមប្រព័ន្ធអេឡិចត្រូនិក E-payment សម្រាប់ការស្នើសុំវិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញ
- អនុវត្តការចុះបញ្ជីសម្រាប់ចេញប្រតិវេទន៍ នៃវិក្កយប័ត្រជំនួសឲ្យការចេញវិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញដោយខ្លួនឯងសម្រាប់អាស៊ាន (Self Certification)
- រៀបចំនីតិវិធី និងសហការជាមួយបណ្តាប្រទេសជាសមាជិក គម្រោងគីមប័រលីប្រូសេសក្នុងការគ្រប់គ្រងការចេញវិញ្ញាបនបត្រត្បូងពេជ្រមិនទាន់កែច្នៃ
- ជំរុញការអនុវត្ត ការប្រើប្រាស់ភាពអនុគ្រោះដែលផ្តល់ឲ្យដោយប្រទេសផ្តល់ភាពអនុគ្រោះឲ្យបានជាអតិបរមា តាមរយៈការធ្វើពិពិធកម្មទំនិញនាំចេញ ទៅកាន់ទីផ្សារទាំងនោះ។

## ឆ.ទិសដៅការងារអភិវឌ្ឍន៍វិស័យឯកជន

- សហការជាមួយអង្គការអន្តរជាតិ និងដៃគូពាក់ព័ន្ធ ដើម្បីជំរុញចលនាភូមិមួយផលិតផលមួយ និងអភិវឌ្ឍន៍ខ្សែសង្វាក់ផ្គត់ផ្គង់ និងខ្សែសង្វាក់ថ្លៃផលិតផល
- ផ្សព្វផ្សាយតាមរយៈសិក្ខាសាលា និងប្រព័ន្ធផ្សព្វផ្សាយផ្សេងៗ ដើម្បីរកវិធានការបង្កើតយន្តការជំរុញការអភិវឌ្ឍន៍ផលិតផលសម្រាប់ទីផ្សារក្នុងស្រុក និងនាំចេញ
- ចុះពង្រឹងការងារបច្ចេកទេសសភាពាណិជ្ជកម្ម ណែនាំបង្កើតសភាពាណិជ្ជកម្មថ្មី រៀបចំកែសម្រួល និងជួយជំរុញដំណើរការរបស់សភាពាណិជ្ជកម្ម
- សហការផ្តល់ប្រឹក្សាបច្ចេកទេស ដល់មន្ទីរពាណិជ្ជកម្មរាជធានី-ខេត្តទាំង ២៥ ដើម្បីស្រាវជ្រាវ និងកំណត់ផលិតផលសក្តានុពលថ្មីៗទៀតដែលអាចធ្វើអាជីវកម្មបាន ពិសេសផលិតផលសម្រាប់ធ្វើការនាំចេញ
- រៀបចំសិក្ខាសាលាផ្សព្វផ្សាយដល់មន្ត្រីរាជការ នៅតាមមន្ទីររាជធានី-ខេត្ត អំពីអត្ថប្រយោជន៍ និងត្រៀមខ្លួនចូលក្នុងសហគមន៍សេដ្ឋកិច្ចអាស៊ានឆ្នាំ២០១៥ខាងមុខនេះ

- រៀបចំវគ្គបណ្តុះបណ្តាលជូនផលិតករកម្ពុជា អំពីការវេចខ្ចប់ និងរចនាម៉ូតតាមស្តង់ដារអន្តរជាតិ សម្រាប់នាំចេញទៅកាន់ទីផ្សារអន្តរជាតិ
- អភិវឌ្ឍផលិតផលដែលជាសក្តានុពលជំហានទី២ សម្រាប់បម្រើទីផ្សារក្នុងស្រុក និងទីផ្សារនាំចេញ
- ត្រៀមរៀបចំបោះពុម្ព សៀវភៅផលិតផលសក្តានុពល ១០មុខជំហានទី២ ដើម្បីធ្វើការផ្សព្វផ្សាយឲ្យបានទូលំទូលាយដល់បណ្តាផលិតករ សិប្បករ ឧស្សាហកករកម្ពុជា
- ជម្រុញអនុវត្តការងារអភិវឌ្ឍន៍ផលិតផលសូត្រតាមរយៈការរៀបចំផែនការសកម្មភាព និងអនុវត្តការងារអភិវឌ្ឍន៍ ផលិតផលសូត្រ តាមមូលដ្ឋានផលិតកម្មសំខាន់ៗ នៅបណ្តាខេត្តចំនួន៥
- ធ្វើបច្ចុប្បន្នភាពឯកសារផលិតផល សក្តានុពលរបស់រាជធានី-ខេត្ត ទាំង ២៥ និងបន្តការសិក្សាស្រាវជ្រាវសង្វាក់តម្លៃផលិតផលអាទិភាពដែលកំណត់ ដោយរាជរដ្ឋាភិបាល
- រៀបចំកម្មវិធីផ្តល់ចំណេះដឹង និងផ្សព្វផ្សាយព័ត៌មានលើការអភិវឌ្ឍន៍ ផលិតផលក្នុងស្រុក និង រៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍផលិតផលតាមបណ្តាខេត្តនិមួយៗ
- តាមដានសន្និធិទំនិញយុទ្ធសាស្ត្រសំខាន់ៗ និងព័ត៌មានទីផ្សារតាមរយៈ កិច្ចសហការជាមួយមន្ទីរពាណិជ្ជកម្ម រាជធានី-ខេត្ត និងការធ្វើបច្ចុប្បន្នភាពព័ត៌មាន ដើម្បីបញ្ចូលទៅក្នុងប្រព័ន្ធ EMCS សម្រាប់ធុរៈជន និងសាធារណៈជន
- ជំរុញការចងក្រង និងបង្កើតសមាគមអាជីវកម្មទូទាំង រាជធានី-ខេត្ត តាមរយៈការផ្សព្វផ្សាយពីសារប្រយោជន៍ នៃការរៀបចំសមាគម និងប្រកាស ឬច្បាប់ទាំងឡាយទាក់ទងដល់ការបង្កើតសមាគម និងចុះជួយរៀបចំបង្កើតសមាគមអាជីវកម្មពាណិជ្ជកម្មនៅតាមរាជធានី-ខេត្ត
- ចុះតាមដាននិងពិនិត្យនូវស្ថានភាពសភាពាណិជ្ជកម្មនិងជំរុញឱ្យបង្កើតនូវមណ្ឌលសភាពាណិជ្ជកម្មថ្មីៗ និងចុះណែនាំ និងពង្រឹងការងារសភាពាណិជ្ជកម្មគ្រប់មណ្ឌលតាមរយៈ រៀបចំបោះឆ្នោតអាណត្តិថ្មី និងអាណត្តិបន្តរបស់មណ្ឌលសភាពាណិជ្ជកម្មរាជធានី-ខេត្ត
- ផ្តល់ប្រឹក្សាបច្ចេកទេស និងជំរុញការអនុវត្តការងារ អោយមានប្រសិទ្ធភាពដល់មន្ទីរពាណិជ្ជកម្មរាជធានី-ខេត្តទាំង ២៥។

**ជ.ទិសដៅការងារកាំកុងត្រូល**

- កសាង និងដំណើរការអនុវត្តខ្លឹមសារនៃការអប់រំ លើកកម្ពស់ការយល់ដឹងសាធារណៈ អំពីបញ្ហាសុខុមាលភាពពាក់ព័ន្ធនឹងម្ហូបអាហារ សុវត្ថិភាពផលិតផល សិទ្ធិរបស់អ្នកប្រើប្រាស់
- កសាង-អនុវត្តកម្មវិធី និងសកម្មភាពពាក់ព័ន្ធកិច្ចការអន្តរជាតិ (អង្គការពាណិជ្ជកម្មពិភពលោក, កូដិច, អាស៊ាន, តំបន់, ទ្វេភាគី)
- ពង្រឹងសមត្ថភាពមន្ទីរពិសោធន៍ ឈានទៅរកការទទួលស្គាល់ជាសាកល និងកសាងបណ្តាញព័ត៌មានមន្ទីរពិសោធន៍ថ្នាក់ជាតិ និងថ្នាក់តំបន់ដើម្បីពង្រីកកិច្ចសហការរវាងគ្នាទៅវិញទៅមក
- បន្តកសាងសេចក្តីព្រាងច្បាប់ស្តីពីម្ហូបអាហារ ច្បាប់ស្តីពីកិច្ចការពារអ្នកប្រើប្រាស់ និងបញ្ញត្តិស្តីពីការគ្រប់គ្រងការនាំចូលផលិតផលម្ហូបអាហារ
- កសាង-អនុវត្តកម្មវិធីបណ្តុះបណ្តាលឯកទេសសម្រាប់មន្ត្រីគ្រប់លំដាប់ថ្នាក់។

## ឈ.ទិសដៅការងារសមាហរណកម្មសាកល

- បន្តតាមដាន និងជំរុញអន្តរក្រសួងស្ថាប័នអនុវត្ត កម្មវិធីការងាររបស់រាជរដ្ឋាភិបាលកម្ពុជាតាមល័ក្ខខណ្ឌតម្រូវរបស់អង្គការពាណិជ្ជកម្មពិភពលោក
- បន្តតាមដាន ការវិវត្តន៍នានានៃការចរចាពាណិជ្ជកម្ម ក្នុងក្របខ័ណ្ឌអង្គការពាណិជ្ជកម្មពិភពលោក ជាពិសេសការអនុវត្តកញ្ចប់បាលី ដែលមានប្រយោជន៍សម្រាប់កម្ពុជា
- តាមដាន ការអនុវត្តគោលការណ៍អនុគ្រោះសម្រាប់ការផ្តល់សេវា ពីប្រទេសអភិវឌ្ឍន៍តិចតួចនៅក្នុងប្រទេសអភិវឌ្ឍន៍ក្នុងក្របខណ្ឌអង្គការពាណិជ្ជកម្មពិភពលោក ដែលមានប្រយោជន៍សម្រាប់កម្ពុជា
- ធ្វើសេចក្តីផ្តល់ព័ត៌មានអំពីអនាម័យ និងភូតគាមអនាម័យ (SPS Notification) ទៅការិយាល័យចុះបញ្ជីកណ្តាលសម្រាប់ការផ្តល់ព័ត៌មាននៃលេខាធិការដ្ឋានអង្គការ WTO
- រៀបចំមជ្ឈមណ្ឌលព័ត៌មានពាណិជ្ជកម្មពិភពលោក (WTO Reference Center)
- បន្តពិនិត្យឡើងវិញនូវអត្ថបទ នៃសេចក្តីព្រាងច្បាប់ឧបាស្រ័យពាណិជ្ជកម្មជាភាសាខ្មែរ ដើម្បីកែសម្រួលឲ្យកាន់តែសុក្រឹត និងមានភាពស៊ីសង្វាក់គ្នា មុននឹងបញ្ជូនទៅទីស្តីការគណៈរដ្ឋមន្ត្រី
- បន្តចូលរួមពិភាក្សាផ្តល់យោបល់ពាក់ព័ន្ធនឹងអនុលោមភាព WTO នៅក្នុងសេចក្តីព្រាងច្បាប់ បទប្បញ្ញត្តិ និងលិខិតបទដ្ឋានផ្សេងៗរបស់អន្តរក្រសួង-ស្ថាប័ន និងនៅក្នុងសន្ធិសញ្ញាអន្តរជាតិ និងកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីកម្រិតទ្វេភាគី អនុតំបន់ និងតំបន់ (ផ្អែកតាមការស្នើសុំរបស់សាមីស្ថាប័ន)
- សហការជាមួយស្ថាប័នពាក់ព័ន្ធ ដើម្បីរៀបចំវគ្គបណ្តុះបណ្តាលក្នុងក្របខណ្ឌ WTO លើប្រធានបទមួយចំនួនដូចជា "ការស្វែងយល់អំពីអង្គការពាណិជ្ជកម្មពិភពលោក" "ការចូលរួមក្នុងពាណិជ្ជកម្មអន្តរជាតិក្រោមប្រព័ន្ធពាណិជ្ជកម្មពហុភាគី"។ល។

## ញ.ទិសដៅការងារជំរុញពាណិជ្ជកម្ម

- រៀបចំ និងចូលរួមពិព័រណ៍ពាណិជ្ជកម្មក្នុង និងក្រៅប្រទេស
- ធ្វើការគ្រប់គ្រង និងផ្តល់ការអនុញ្ញាតច្បាប់ឲ្យរៀបចំពិព័រណ៍ពាណិជ្ជកម្ម របស់វិស័យឯកជន និងស្ថាប័នផ្សេងៗនៅកម្ពុជា
- ការងាររៀបចំ និងចូលរួមពិព័រណ៍ពិភពលោកឆ្នាំ២០១៥ មីឡង់ ប្រទេសអ៊ីតាលី (កម្រិតអន្តរក្រសួង និងកម្រិតជាតិ)
- កិច្ចការការិយាល័យពិព័រណ៍អន្តរជាតិ (BIE) ចូលរួមប្រជុំ សន្និបាតប្រចាំឆ្នាំ និងតាមដានសកម្មភាពរបស់ការិយាល័យ BIE និងចូលរួមប្រជុំបច្ចេកទេស ស្តីពីការងាររៀបចំពិព័រណ៍អន្តរជាតិ ២០១៧ កាស្សាក់ស្តង់
- ការងារគ្រប់គ្រង និងសម្របសម្រួលកិច្ចការពិព័រណ៍និងព្រឹត្តិការណ៍ពាណិជ្ជកម្ម នៅតាមរាជធានី និងខេត្ត
- ពង្រឹងការប្រមូលចំណូលពីការចាត់ចែង និងរៀបចំពិព័រណ៍ជូនរដ្ឋ ឲ្យមានប្រសិទ្ធភាពសម្រាប់ឆ្នាំបន្តបន្ទាប់
- កិច្ចការជំនួបពាណិជ្ជកម្ម និងកិច្ចការបេសកកម្មពាណិជ្ជកម្មទាំងក្នុង និងក្រៅប្រទេស
- ការងារសហប្រតិបត្តិការជាមួយ ដៃគូរជំរុញពាណិជ្ជកម្មបរទេស (ក្នុងទិសដៅជំរុញពាណិជ្ជកម្ម និងរកទីផ្សារ)

- ការងារទីផ្សារក្នុងប្រទេស និងក្រៅប្រទេស ក្នុងគោលដៅជំរុញការនាំចេញផលិតផលកម្ពុជា
- កសាង និងរៀបចំឲ្យមានផែនការយុទ្ធសាស្ត្រទីផ្សារ
- ធ្វើជាចំណុចប្រសព្វ និងធ្វើទំនាក់ទំនងការងារ ជាមួយស្ថានជំណាងពាណិជ្ជកម្មកម្ពុជាក្រៅប្រទេស និងរៀបចំនិងអនុវត្តកម្មវិធីជំរុញការនាំចេញកសិផលនិងផលិតផលសក្តានុពលកម្ពុជាទៅកាន់បណ្តាប្រទេសដែលកម្ពុជាមានតំណាងពាណិជ្ជកម្ម
- ជំរុញឲ្យមានការបង្កើតមជ្ឈមណ្ឌលអចិន្ត្រៃយផលិតផលកម្ពុជា និងមជ្ឈមណ្ឌលជំរុញពាណិជ្ជកម្មនៅក្រៅប្រទេស
- ធ្វើការផ្សព្វផ្សាយព័ត៌មានទីផ្សារ ដើម្បីជំរុញការនាំចេញ
- ផ្តល់សេវាព័ត៌មានពាណិជ្ជកម្ម និងផ្តល់ប្រឹក្សាលើកិច្ចការពាណិជ្ជកម្មជូនវិស័យឯកជន
- រៀបចំគ្រប់គ្រង និងថែរក្សាគេហទំព័ររបស់អគ្គនាយកដ្ឋានជំរុញពាណិជ្ជកម្ម
- ធ្វើការសិក្សា និងវិភាគលើគោលនយោបាយពាណិជ្ជកម្ម នៃបណ្តាប្រទេសជាគូប្រជែងដែលនាំចេញផលិតផលដូចគ្នា ទៅកាន់ទីផ្សារនាំចេញរបស់កម្ពុជា
- សិក្សាអំពីផលប្រយោជន៍នៃការអនុវត្តន៍កិច្ចព្រមព្រៀងពាណិជ្ជកម្មទ្វេភាគី និងពហុភាគីរវាងកម្ពុជា និងប្រទេសជាដៃគូរពាណិជ្ជកម្ម និងផ្សព្វផ្សាយអត្ថប្រយោជន៍ទាំងអស់នោះ ជូនវិស័យឯកជន ដើម្បីជំរុញការនាំចេញ
- ផ្តួចផ្តើមគំនិត យោបល់ដើម្បីបង្កើតនូវគោលនយោបាយ ជំរុញការនាំចេញផលិតផលក្នុងស្រុក (ផ្តោតលើផលិតផលហាឡាល់ និងផលិតផលសក្តានុពលដែលបានកំនត់ដោយរាជរដ្ឋាភិបាល)
- ផ្តួចផ្តើមគំនិតផ្តល់យោបល់ ដើម្បីបង្កើតនូវគោលនយោបាយសម្រាប់ទ្រទ្រង់ និងការពារពាណិជ្ជកម្មក្នុងប្រទេស
- សហការជាមួយស្ថាប័ននៅក្រៅប្រទេស ក្នុងកិច្ចការវាយតម្លៃបរិយាកាសពាណិជ្ជកម្មកម្ពុជា និងលើកអនុសាសន៍ជូនថ្នាក់ដឹកនាំ
- ធ្វើការស្រាវជ្រាវ និងកសាងគោលនយោបាយថ្មីៗ (កម្រិតបឋម) ដើម្បីជំរុញការនាំចេញផលិតផលសក្តានុពល និងសេវាកម្មកម្ពុជា
- ចូលរួមរៀបចំកសាងគោលនយោបាយសហគ្រាសខ្នាតតូច និងមធ្យម
- ចូលរួមរៀបចំ និងអនុវត្តន៍គម្រោងសម្រាប់អភិវឌ្ឍន៍វិស័យពាណិជ្ជកម្មនៅកម្ពុជា
- រៀបចំវេទិកា និងផ្សព្វផ្សាយអំពីគោលនយោបាយពាណិជ្ជកម្ម ជូនវិស័យឯកជន
- រៀបចំសន្និសិទថ្នាក់ជាតិលើគោលនយោបាយអភិវឌ្ឍន៍កសិ-ពាណិជ្ជកម្មកម្ពុជា

**<u>ដ.ទិសដៅការងារសន្តិសុខស្បៀង និងសន្និធិអាស៊ាន</u>**

- បន្តគ្រប់គ្រងសន្និធិស្តុកស្បៀងឲ្យបានល្អ ដើម្បីធានា និងស្ថេរភាពតម្លៃលើទីផ្សារ និងដឹកជញ្ជូនទាន់ពេលវេលាទៅតាមគោលដៅដែលរាជរដ្ឋាភិបាល បានកំណត់ជួយដល់ប្រជាជនរងគ្រោះដោយគ្រោះមហន្តរាយ
- ពង្រឹងទំនាក់ទំនងជាមួយបណ្តាប្រទេសដែលបានចុះហត្ថលេខាលើ អនុស្សារណៈយោគយល់គ្នាស្តីពីការនាំចេញអង្ករ និងស្វែងរកទីផ្សារអង្ករ និងទំនិញកសិផលបន្ថែម
- ខិតខំអនុវត្តនូវគោលនយោបាយ ស្តីពីការជំរុញផលិតកម្មស្រូវ និងនាំចេញអង្ករ ឲ្យបានសម្រេចគោលដៅ។

## ច.ទិសដៅការងារអនុវត្តគម្រោង

- ជំរុញការអនុវត្តគម្រោងទាំង១៥ ដែលមិនទាន់បានបញ្ចប់
- ត្រួតពិនិត្យ និងវាយតម្លៃចំពោះគម្រោងទាំង១២ ដែលបានបញ្ចប់
- រៀបចំឯកសារគតិយុត្តិសម្រាប់បន្តគម្រោង (TDSP )
- បន្តការគាំទ្រគម្រោងថ្មីទាំង៣ Bussiness Registration, SPS និង TTRI និងបន្តគាំទ្រគម្រោងITC របស់ក្រសួងពាណិជ្ជកម្ម
- កែសម្រួល និងធ្វើបច្ចុប្បន្នភាពនូវ (១.) ផែនការងារ (២.) ផែនការថវិការ (៣.) ផែនការលទ្ធកម្ម របស់គម្រោង TDSP ទាំងមូល
- រៀបចំទទួលបេសកកម្មត្រួតពិនិត្យរបស់ធនាគារពិភពលោក ដែលគ្រោងធ្វើឡើងនៅដើមខែតុលា ឆ្នាំ២០១៤ ខាងមុខនេះ។

## ឆ.ទិសដៅបណ្តុះបណ្តាល និងស្រាវជ្រាវពាណិជ្ជកម្ម

- រៀបចំផែនការយុទ្ធសាស្ត្រសម្រាប់ការស្រាវជ្រាវ និងបណ្តុះបណ្តាលជំនាញពាណិជ្ជកម្ម
- រៀបចំប្រព័ន្ធទិន្នន័យ និងចងក្រងឯកសារបណ្តុះបណ្តាល
- រៀបចំកម្មវិធីសិក្សា និងឯកសារបណ្តុះបណ្តាលពាណិជ្ជកម្ម
- បើកវគ្គបណ្តុះបណ្តាល និងផ្តល់វិញ្ញាបនបត្រជូនគ្រូបង្គោល
- ជ្រើសរើស និងបណ្តុះបណ្តាលក្រុមអ្នកស្រាវជ្រាវ
- ធ្វើការស្រាវជ្រាវលើប្រធានបទពាក់ព័ន្ធនឹងវិស័យពាណិជ្ជកម្ម
- ចុះអនុស្សារណៈយោគយល់ជាមួយដៃគូ ស្រាវជ្រាវ និងបណ្តុះបណ្តាល
- រៀបចំប្រព័ន្ធគ្រប់គ្រងព័ត៌មានវិទ្យាសំរាប់កម្មវិធីបណ្តុះបណ្តាល និង គ្រប់គ្រងរដ្ឋបាលរបស់វិទ្យាស្ថាន
- រៀបចំគោលនយោបាយ និងផែនការយុទ្ធសាស្ត្រសំរាប់ការបណ្តុះបណ្តាល និងការអនុវត្តភាពជាដៃគូជាមួយវិទ្យាស្ថានអន្តរជាតិនានាព្រមទាំងកម្មវិធីសិក្សា សម្រាប់ដំណើរការបណ្តុះបណ្តាលរបស់វិទ្យាស្ថាន
- រៀបចំវគ្គបណ្តុះបណ្តាលពាណិជ្ជកម្មរយៈពេលខ្លី រួមមាន៖ វគ្គសិក្សាស្តីពី ការគ្រប់គ្រងពាណិជ្ជកម្មទីផ្សារ និងការស្រាវជ្រាវ, ការយល់ដឹងអំពីអង្គការពាណិជ្ជកម្មពិភពលោក និងអាស៊ាន, ការចុះបញ្ជីរពាណិជ្ជកម្ម, ស្ថិតិពាណិជ្ជកម្ម, ការរៀបចំតាំងពិព័ណ៌ និងការគ្រប់គ្រង, ការគ្រប់គ្រងពាណិជ្ជកម្ម និងការអភិវឌ្ឍន៍, ការជំរុញពាណិជ្ជកម្ម, ច្បាប់វិនិយោគ និងច្បាប់ពាណិជ្ជកម្មសហគ្រាស, ការប្រាស័យទាក់ទងពាណិជ្ជកម្ម និងជំនាញក្នុងការចរចា, ច្បាប់ពាណិជ្ជកម្មអន្តរជាតិ និងច្បាប់កិច្ចសន្យា, ការអភិវឌ្ឍន៍សហគ្រាសធុនតូច និងមធ្យម និងវគ្គសិក្សា អំពីឧបករណ៍វិភាគទីផ្សាររបស់មជ្ឈមណ្ឌលពាណិជ្ជកម្មអន្តរជាតិ
- រៀបចំវគ្គបណ្តុះបណ្តាលរយៈពេលវែងរួមមាន វគ្គសិក្សា ស្តីពីភស្តុភារពាណិជ្ជកម្ម, កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី, គោលនយោបាយពាណិជ្ជកម្ម និងការចរចារពាណិជ្ជកម្ម
- រៀបចំវគ្គបណ្តុះបណ្តាលជាប្រចាំរួមមានវគ្គសិក្សា ស្តីពីកុំព្យូទ័រ និងប្រព័ន្ធព័ត៌មានវិទ្យា, ភាសាអង់គ្លេសសំរាប់ពាណិជ្ជកម្ម, ជំនាញគណនេយ្យ និងការគ្រប់គ្រងហិរញ្ញវត្ថុ។

# ផែនការសកម្មភាពពាណិជ្ជកម្មឆ្នាំ២០១៥

| ល.រ | | សកម្មភាព | អង្គភាពទទួលខុសត្រូវ | ពេលវេលា |
|---|---|---|---|---|
| **1.ការងារអធិការកិច្ច និងសវនកម្ម** | | | | |
| **1.1.អគ្គាធិការដ្ឋាន** | | | | |
| | 1.1.1 | អធិការកិច្ច ការងារគ្រប់គ្រង និងប្រើប្រាស់ទ្រព្យសម្បត្តិរដ្ឋ | អគ្គាធិការដ្ឋាន | កុម្ភៈ-វិច្ឆិកា |
| | 1.1.2 | អធិការកិច្ច ការងារគ្រប់គ្រង និងប្រើប្រាស់ថវិការដ្ឋ | អគ្គាធិការដ្ឋាន | មករា-វិច្ឆិកា |
| | 1.1.3 | អធិការកិច្ចលើពាក្យបណ្តឹងតវ៉ា និងវិវាទពាណិជ្ជកម្ម | អគ្គាធិការដ្ឋាន | កុម្ភៈ-ធ្នូ |
| | 1.1.4 | ពិនិត្យឡើងវិញ និងជំរុញការផ្ញើរបាយការណ៍ របស់បណ្តាអង្គភាព មកអគ្គាធិការដ្ឋាន | អគ្គាធិការដ្ឋាន | មករា-ធ្នូ |
| | 1.1.5 | តាមដាន និងវាយតម្លៃលទ្ធផលនៃការអនុវត្តន៍កែលម្អតាមអនុសាសន៍របស់ប្រតិភូអធិការកិច្ចដែលបានលើកឡើង | អគ្គាធិការដ្ឋាន | មករា-ធ្នូ |
| | 1.1.6 | លើកសកម្មភាព បំប៉នសមត្ថភាពមន្ត្រីនៃអគ្គាធិការដ្ឋាន | អគ្គាធិការដ្ឋាន | កុម្ភៈ-ធ្នូ |
| **1.2.នាយកដ្ឋានសវនកម្មផ្ទៃក្នុង** | | | | |
| | 1.2.1 | ធ្វើផែនការសវនកម្មប្រចាំឆ្នាំ២០១៥ | នា-សវនកម្មផ្ទៃក្នុង | មករា |
| | 1.2.2 | ធ្វើការសិក្សាលើហានិភ័យរបស់អង្គភាពត្រូវធ្វើសវនកម្ម ដើម្បីកំណត់វិសាលនៃការងារសវនកម្មឆ្នាំ២០១៥ | នា-សវនកម្មផ្ទៃក្នុង | មករា-ធ្នូ |
